# ល្បិចទល់មេឃ

០១. សម្លាប់មាន់បំភ័យស្វា
០២. បង្ក្រាបមុនដើម្បីឈ្នះ
០៣. ព្រួញមួយបាញ់បានសត្វពីរ
០៤. ចាប់ចោរ ត្រូវចាប់មេ
០៥. កម្បាំងមេឃឆ្លងសមុទ្រ
០៦. ដល់គ្រើយសើយតូច
០៧. ដឹងតែធ្វើពើ ( ធ្វើមិនដឹង )
០៨. គ្មាន តែអាចបង្កើតឲ្យមាន
០៩. ត្រីងៀតឆ្អៀតពង
១០. វាយពីលិច បញ្ឆោតពីកើត
១១. បញ្ឆោតខ្លា ចេញពីភ្នំ
១២. ខ្វីគាំបិតសម្លាប់មនុស្ស

ចំណេះដឹងគ្រប់វិនាទី

# សម្លាប់មាន់បំភ័យស្វា

ពីព្រេងនាយមកគេនិយាយតគ្នាថាៈស្វាជាសត្វឈ្លាសវៃបំផុតតែខ្លាចឈាមអ្នកដែលបង្ហាត់ស្វាជាដំបូងត្រូវតែចាប់មាន់មកសម្លាប់នៅនិងមុខវាឲ្យវាឃើញមេរៀនឈាមដែលកំពុងស្រក់តក់ៗ។ទើបចាប់ផ្តើមបង្ហាត់វាអ្នកដែលរកស៊ីចាប់ស្វាក៏ប្រើវិធីនេះដើម្បីបំភ័យស្វាដែរមិនថាស្វារឹងរូសប៉ុណ្ណាទេឲ្យតែឮសម្លេងមាន់ស្រែក“កាក“ឈាមមាន់បាញ់រូ,ស្វាឃើញភ្លាមពិតជាទន់ខ្លួនតែម្តង។ដែលហៅថា “សម្លាប់មាន់បំភ័យស្វា“ ក៏បានន័យថា“ សម្លាប់មួយបំភ័យមួយរយ“ ដែលមានន័យគំរាមកំហែងនេះគឺជាយុទ្ធវិធីជាមធ្យោបាយគ្រប់គ្រងសម្ហូហភាព។នៅពេលដែលមានយោបល់ ខ្វែងគ្នាសន្ធឹកសន្ធាប់ពេលដែលការងារត្រូវជួបការរាំងស្ទះនិងឧបសគ្គដើម្បីឈានដល់ការឯកភាពត្រូវអនុវត្តដាច់ខាតតាមច្បាប់ត្រូវប្រើវិធីដាច់ខាតបំផុតដើម្បីទប់ទល់មានពាក្យមួយឃ្លានិយាយថា “ បើមិនប្រើវិធីឃោរឃៅម្តេចនិងអាចសំដែងឲ្យឃើញចិត្តត្រាប្រណីរបស់ព្រះពោធិសត្វ“។

បង្ក្រាបសង្គមដែលច្របូកច្របល់ត្រូវតែប្រើច្បាប់ឲ្យតឹងរឹងបង្ក្រាបកងទ័ពដែលខ្វះវិន័យត្រូវតែប្រើទ័ណ្ឌកម្មដ៏ម៉ឹងមាត់។ខុងជឺសម្លាប់សាវ,ចិនយើងមួយកាំបិតនេះបានធ្វើឲ្យមន្ត្រីទាំងតូចទាំងធំបាក់បប់ខ្លបខ្លាចរាស្ត្របានរស់នៅយ៉ាងសុខសាន្តខុងម៉េងនៅពេលដែលសម្លាប់ម៉ាជីននិយាយថា ,ពីដើមស៊ុនវូដែលអាចគ្រប់គ្រងផែនដីបានគឺការប្រើច្បាប់ដ៏ម៉ឹងមាត់ពេលនេះគ្រប់ទិសទីកើតចលាចល ទាហាន,ជនខិលខូចមានគ្រប់ទីកន្លែងបើបោះបង់ច្បាប់ចោលម្តេចនិងបង្រ្កបជនខិលខូចបាន? បើមិនប្រើវិន័យតឹងតែងម្តេចនិងអាចបង្ក្រាបទាហានខិលខូចបាន? នេះហើយគឺជាយុទ្ធវិធីដើម្បីបង្ក្រាបភាពចលាចលគឺជាល្បិច(សម្លាប់មាន់បំភ័យស្វា) ដ៏អស្ចារ្យនេះឯង។ មនុស្សគឺអាចិកំបាំងណាស់សង្គមរឹតតែជឿនលឿនភាពក្រឡិចក្រឡុចរឹតតែសំបូរបែបម្នាក់ៗមានគំនិតរៀងខ្លួនមានផ្លូវដើរទីទៃពីគ្នាបើមិនធ្វើការកំណត់នូវព្រំដែនមួយប្រាកដជាបែងចែកមិនច្បាស់អ្វីដែលល្អត្រឹមត្រូវនិងអ្វីដែលមិនត្រឹមត្រូវបានទេមនុស្សកាន់តែអាក្រក់ឡើងៗសណ្តាប់ធ្នាប់សង្គមឲ្យបានរឹងមាំប្រជារាស្ត្ររស់នៅបានសុខសាន្តចំពោះមនុស្សដែលបង្កចលាចលបែបនេះត្រូវតែប្រើទ័ណ្ឌកម្មឲ្យបានធ្ងន់ធ្ងរបំផុតខ្ចីក្បាល មនុស្សមួយចំនួនឲ្យគេមើល។នេះហើយគឺ(មិនឃើញក្តាម្លួសមិនស្រក់ទឹកភ្នែកឃើញក្តាម្លួសពេលណាទើបយំមិនឈប់) អត្ថន័យសម្លាប់មាន់បំភ័យស្វាគឺនៅត្រង់នេះឯង។

ក្រោយសម្លាបសានហ្វូកសាងឡើងនគរចូវជាងថៃកុង ត្រូវការប្រមូលអ្នកចេះដឹងដើម្បីជួយកសាងនគរ។នៅនគរឈីមានមនុស្សម្នាក់ប្រកបដោយការចេះដឹងឈ្មោះវ៉ាង-អ៊ិត្រូវបានការសរសើរពីសំណាក់ប្រជារាស្ត្រនៅទីនោះជាងថៃកុងល្បីឈ្មោះក៏មានបំណងអញ្ជើញគាត់ឲ្យចេញមកជួយធ្វើកិច្ចការទៅសួរសុខទុក្ខបីដងសុទ្ធតែមិនត្រូវបានទទួល។

ស្រាប់តែជាងថៃកុងយកគេទៅសម្លាប់ចោលតែម្តងចូវ-កុង ចង់ជួយក៏មិនទាន់ដែរហើយក៏សួរជាងថៃកុងថា:វ៉ាងជាមនុស្សចេះដឹងខ្ពង់ខ្ពស់ម្នាក់មិនទាមទារចង់មានចង់បានសុខចិត្តផឹកស៊ីតែឯងធ្វើស្រែចិញ្ចឹមក្រពះ គឺពិតជារស់នៅស្ងៀមស្ងប់មិនសួរនាំពីរឿងមនុស្សលោក ហេតុអ្វីបានជាសម្លាប់គេចោល?

ជាងថៃកុងតបៈ

-ក្នុងសមុទ្រទាំងបួនគឺជាទឹកដីរបស់ព្រះអង្គអ្នកដែលដឹកនាំលើទឹកដីទាំងនោះគឺសុទ្ធសឹងជាមន្ត្រីរបស់ព្រះអង្គនៅពេលដែលនគរទើបទទួលបានសន្តិភាពម្នាក់ៗត្រូវតែមានភារៈកិច្ចជួយកសាងនគរគឺមានជំហរតែពីរពីរប៉ុណ្ណោះបើមិនគាំទ្រទេគឺប្រឆាំងមិនអនុញ្ញាតិឲ្យមានភាពស្ទាក់ស្ទើរឬអព្យាក្រិត្យឡើយអាកប្បកិរិយាមិនព្រមសហការណ៍របស់វ៉ាង, បើម្នាក់ៗយកគេធ្វើជាគំរូតើមានប្រជារាស្ត្រណា

ដែលអាចប្រើការបាននោះ? ហេតុនេះបានជាយើងសម្លាប់គេចោលគឺជាមេរៀនសំរាប់អ្នកដទៃ ។
ពិតជាអ៊ីចឹងមែនក្រោយពីសម្លាប់ហើយមន្ត្រីក្នុងវាំង ដែលប្រុងលាឈប់គ្រប់គ្នា ពិតជាលែងហ៊ាននិង
ធ្វើឫកពារបែបហំហាន ចង់សម្ងំលាក់ខ្លួនទៀតហើយ។
ហាង-ស៊ីងក្នុងរជ្ជកាលហានកើតក្នុងត្រកូលក្រខ្សត់ក្រោយពីបានស្តេចលីវ-ប៉ាង លើកឲ្យធ្វើ
ជាមេទ័ព្វត្រូវទទួលការមើលស្រាលពីរពួកមន្ត្រីចាស់ៗមានឃោនបល់ក្រោយខ្នងមិនចេះចប់ក្រោយ
ឡើងកាន់តំណែងក៏ប្រើច្បាប់តឹងតែងម៉ឺងម៉ាត់បំផុត។ថ្ងៃមួយត្រូវជុំគ្នាដើម្បីហ្វឹកហាត់កំណត់យាម
ប្រាំត្រូវតែជុំគ្នាហៅឈ្មោះចប់សព្វគ្រប់បាត់តែមេបញ្ជាការភីកាយម្នាក់គត់ដែលមិនទាន់ឃើញមក
ដល់ហាង-ស៊ីងក៏មិនសួរដេញដោលហើយក៏ចាប់ផ្តើមហ្វឹកហាត់ ថ្ងៃត្រង់បានកន្លងផុតទៅទើប
ឃើញភិកាយត្រឡប់មកវិញមកដល់មាត់ទ្វាច្រកចូលបន្ទាយ  រៀបដើរចូលទៅ តែត្រូវអ្នកយាមឃាត់ជាប់:
-លោកអគ្គមេបញ្ជាការហ្វឹកហាត់កន្លះថ្ងៃទៅហើយ គ្មានបញ្ជាមិនអនុញ្ញាតិឲ្យចូលទេ។ ភីកាយក្តៅឆេវះ
-អគ្គមេបញ្ជាការឬមិនមេនបញ្ជាការស្អីពិតជាអំពិលដុះពីអាចមិហ៊ានធ្វើផ្តេសផ្តាស់ផង! ល្អណាស់ឯង
ចូលទៅប្រាប់មួយម៉ាត់ទៅ! មួយសន្ទុះក្រោយមក សេនាកាន់ផ្លាកបញ្ជាកម ហើយស្រែកប្រាប់ថា៖
-សូមអញ្ជើញ!
-ភីកាយដើរចូលដោយឫកពារក្រអឺតក្រទមជួបហាង-ស៊ីងគ្រាន់តែលើកដៃហាក់ដូចជានៅមានកំហឹង។
ហាង-ស៊ីងសួរ:
-ទ័ពមានបទបញ្ជា ស្តេចហានក៏បានឡាយព្រះហត្ថដែរ ក្នុងនាមលោកជាមេបញ្ជាការ
ហេតុម្តេចបានជាមកយឺតពេល? ហើយក៏បែរមកសួរសេនា “ យាម “ ។
-ឥឡូវម៉ោងណាហើយ?
-ហួសពេលថ្ងៃត្រង់ហើយ ។ សេនាយាមឆ្លើយ៖
-ពេលនវគឺយាមមួយរសៀលហើយបទបញ្ជាកំណត់យាមប្រាំភ្លឺមកជួបជុំឥឡូវនេវឯងមក
យឺតពេល៧-៨យាមឯណ្ណោះ! គឺជាអំពើមើលស្រាលបទបញ្ជាររបស់កងទ័ព តាមច្បាប់ត្រូវសម្លាប់
ចោល...........ហាង-ស៊ីង និយាយយ៉ាងម៉ឺងមាត់ដាក់ភីកាយ ។
ភីកាយមិនចាប់ងារមណ៍ទេ នៅតែវែកញ៉ែកយ៉ាងចចេស មិនចាត់ទុក ហាង-ស៊ីង
ក្នុងកែវភ្នែកឡើយ ។
ហាង-ស៊ីង ក្តៅឆាវ ស្រែកបញ្ជាឲ្យសេនាឆ្វេងស្តាំចាប់ភីកាយចង ហើយឲ្យលុតជង្គង់
រួចសូត្រពីទោស កំហុស:
-ក្នុងនាមឯងជាមេទ័ព ភ្លេចថ្ងៃដែលទទួលបញ្ជាបានន័យថា៖ គឺភ្លេចលំនៅខ្លួន មិនគោរព
វិន័យកងទ័ព គឺភ្លេចសាច់សារលោហិត ពេលប្រយុទ្ធជាមួយសត្រូវ ឬក៏ភ្លេចរូបខ្លួនដែរ ? ក្នុង
នាមជាខ្សែលោហិតក្សត្រ ធ្វើបែប
នេះ បានគិតពីទំនាក់ទំនងឪពុកនិងកូនដែរឬទេ ?
ហៅទាហានផ្នែកនិតិកម្មមកសួរ៖
-ភិកាយមិនគោរពបញ្ជា ត្រូវទទួលទោសអ្វី?
ទាហានផ្នែកនិតិកម្មស្រែកខ្លាំងៗ៖
-មិនគោរពបទបញ្ជាដឹងពេលវេលាហើយមានចេតនាមកយឺតពេលគឺមលើស្រាលបញ្ជា
កងទ័ពត្រូវកាត់ទោសប្រហារជីវិតនៅនិងកន្លែង។
ពេលនេះភីកាយដឹងថាពិតជាធ្វើឲ្យកើតរឿងធំហើយភ័យព្រលឹងរត់ចេញពីខ្លួនបាត់
ប្រញ៉ាប់សម្លឹងមើលមុខឈី-ហ៊្វយចង់ឲ្យជួយនិយាយសុំការយោគយល់តែឈី-ហ៊្វយក៏
មិនហ៊ានចេញស្តីហើយក៏មិនអាចញពីបន្ទាយបានបានត្រឹមជ្រួលច្របល់ប៉ុណ្ណោះខាងក្រៅ
បន្ទាយមានអ្នកដឹងពីរឿងនេះក៏បំបោលសេះយ៉ាងលឿនទៅទូលស្តេចហានលីវ-ប៉ាង។លី-

# សម្លាប់មាន់បំភ័យស្វា

ប៉ាងភ្ញាក់ក្រញ៉ាងប្រញ៉ាប់បញ្ជាទៅលី-ស៊ីងយករាជសារ......... ទៅសុំការលើកលែងទោស។

លី-ស៊ីនជាមួយនិងកូនចៅបោះពួយសេះលឿនស្លេវដូចហោះដល់ច្រក់ទ្វាបន្ទាយភ្លាម
ក្រឡេកឃើញភីកាយកំពុងតែលុតជង្គង់រង់ចាំទទួលទោសក៏ស្រែកពីចម្ងាយ:
-មានសាររបស់ព្រះអង្គសូមផ្អាកការកាត់ទោសសិន! សេះទាំងពីរក៏បោលយ៉ាង
លឿនសំរុកចូលក្នុងបន្ទាយ តែត្រូវអ្នកយាមទ្វាឃាត់ជាប់ ទើបដឹកសំដៅទៅជួប ហាង-ស៊ីង ។
ហាង-ស៊ីង និយាយ ៖
-នៅក្នុងបន្ទាយមិនអនុញ្ញាតិឲ្យបំផាយសេះ លោកម្ចាស់លីដឹងពីវិន័យនេះច្បាស់ណាស់
ហេតុអ្វីបានជាប្រព្រឹត្តិល្មើសនិងបញ្ជាដោយចេតនា?
លី-ស៊ីនតប:
-គឺទទួលរាជបញ្ជារបស់ព្រះអង្គឲ្យមកកាន់ទីនេះ។
-ត្បិតតែទទួលរាជបញ្ជាឲ្យមកផ្អែកតាមច្បាប់នៅតែមានការប៉ះពាល់និយាយចប់ក៏
សួរទៅផ្នែកនិតិកម្ម:
-តើលោកម្ចាស់លីត្រូវទទួលទោសអ្វី?
-អ្នកដែលហ៊ានបំបោលសេះនៅក្នុងបន្ទាយត្រូវទទួលទោសពីបទមើលងាយ
បទបញ្ជាកងទ័ពគឺត្រូវតែកាត់ទោសប្រហារជីវិតនិងកន្លែង ដើម្បីបង្ហាញជាមេរៀនដល់
កងទ័ពទាំង៣ប្រភេទ។
ហាង-ស៊ីងនិយាយ:
-ដោយមានរាជសារនៅជាប់និងខ្លួនអាចឲ្យរួចផុតពីសេចក្តីស្លាប់ខ្លួនឯងបានតែ
ត្រូវតែសម្លាប់អ្នកបរសេះ ដើម្បីបញ្ជាក់ប្រសិទ្ធភាពរបស់បទបញ្ជាកងទ័ព ។
មួយសន្ទុះក្រោយភីកាយនិងអ្នកបរសេះត្រូវកាត់ក្បាលនៅនិងកន្លែង
តែម្តងចាប់ពីពេលនោះមកមេទ័ពកូនទាហ៊ានទាំងអស់ក៏លែងហ៊ានប្រព្រឹត្តល្មើសនិងវិន័យ
ទៀតហើយគោរពតាមការដឹកនាំរបស់ហាង-ស៊ីងគ្រប់ដប់អាស្រ័យហេតុនេះហើយបាន
ជាទ័ពរបស់ហាង-ស៊ីងអាចកំទេចស្តេចស៊ាង-យីឲ្យស្លាប់នៅទន្លេខ្មៅបាននិង បានជួយ
បើកផ្លូវ លីវ-ប៉ាង គ្រប់គ្រង់ទឹកដីនាពេលនោះ។
នៅសម័យចាន់-គួកយ៉ាងជាក៏ធ្លាប់ប្រើវិធីនេះសម្លាប់ជូន-ជៀកសាងនគរ
ឈីឡើងវិញដែរ។ សម័យសាម-កុក, លី-ម៉ុងបានសម្លាប់មិត្តរួមអាវុធម្នាក់ដែលមាន
ស្រុកកំណើតជាមួយគ្នាធ្វើឲ្យវិន័យកងទ័ពមានប្រសិទ្ធភាព។ឃើញថាល្បិចលកនេះ
គោលបំណងរបស់វានៅត្រង់“ កម្លា“ និងមានចរិតគៀបសង្កត់ឲ្យនៅស្ងប់ស្ងៀម ។
(ប្រ/ជ១) សម័យ ឈុន-ឈីវ,ស៊ុន-វូជី មានសៀវភៅក្បួនទ័ពដែលមាន១៣ជំពូក:
ក្រោយពីស្តេចអ៊ូទតចប់សរសើរថាពិតជាអស្ចារ្យកម្រមានហើយក៏ឲ្យអ៊ូ-ជីស៊ី
ទៅអញ្ជើញគាត់ជួយធ្វើកិច្ចការ ។
ពេលជួបមុខស្តេចអ៊ូក៏បានប្រាប់អំពីភាពទន់ខ្សោយរបស់កងទ័ពហើយសួរថា៖
តើធ្វើយ៉ាងណាទើបអាចពង្រឹងសម្ថភាពកងទ័ពប្រែក្លាយនគរឲ្យខ្លាំងបាន?
ក្រោយពីធ្វើការវិភាគទៅលើសភាពការណ៍ចប់សព្វគ្រប់
ហើយនិយាយថា៖ក្បួនទ័ព១៣ជំពូករបស់ទូលបង្គំមិនត្រឹមតែអាចអនុវត្តក្នុង
ជួរកងទ័ពបានប៉ុណ្ណោះទេតែក៏អាច បង្ហាត់ឲ្យស្រ្តីភេទ ប្រើការបានយ៉ាងពូកែទៀតផង។
ស្តេចអ៊ូសើចក្អាកក្អាយហើយមានបន្ទូល ៖
-យើងពិតជាមិនដែលឮថាអាចបង្ហាត់ស្រ្តីភេទឲ្យចូលសមរភូមិសម្លាប់សត្រូវ

# សម្លាប់មាន់បំភ័យស្វា

បានសោះ។ស្តេចអ៊ូមានបន្ទូលក្នុងន័យរបៀបមើលស្រាល ។
ស៊ុន-វូ តប៖
-បើព្រះអង្គមិនជឿអាចសាកល្បងចំពោះមុខតែម្តងបើមិនបានជោគជ័យ
ទទួលបង្គំសុខចិត្តទទួលទោស បានបោកប្រាស់ព្រះអង្គ ។
-ពិតមែនឬ? ស្តេចអ៊ូមានបន្ទូលៈល្អយើងរងចាំមើលសមត្ថភាពរបស់ឯង។
ហើយក៏ជ្រើសរើសនារីចំនួនបីរយនាក់នៅក្នុងរាជវាំង ប្រគល់ឲ្យទៅ ស៊ុន-វូ ធ្វើការហ្វឹកហាត់ ។
ស៊ុន-វូក៏បានសំណូមពរស្នើរសុំស្នំពីនាក់របស់ព្រះអង្គមកចូលរួមទទួលមុខងារជា
មេកងដើម្បីដឹកនាំ។ ស្តេចអ៊ូក៏យល់ព្រមតាមសំណូមពរហើយក៏ឲ្យទៅហៅស្នំ
ទាំងពីរអ៊ីវ-ជីនិងចរ-ជីមកគាល់។
រួចមានបន្ទូលតៅកាន់ស៊ុន-វូ ៖
-ស្នំដ៏ស្រស់ស្អាតទាំងពីរនាក់នេះ យើងស្រឡាញ់ជាងគេ។ តើអាចទទួលនាទី
ជាមេកងបានឬទេ ?
ស៊ុន-វូ តប៖
-ប្រាកដជាបានតែកិច្ចការក្នុងមានវិន័យតឹងតែងណាស់មានសរសើរហើយក៏មានពិន័យ
បែបនេះបទបញ្ជាទើបមានប្រសិទ្ធភាព ។ជាមួយគ្នានោះក៏បានតែងតាំងអ្នកទាំងពីរជា
មេកងហើយតែងតាំងអ្នកផ្សេងម្នាក់ទៀត កាន់ផ្នែកនិតិកម្មពីរនាកទៀតទទួលបន្ទុកផ្នែក
បទបញ្ជានិងជ្រើសរើសអ្នកដែលមានមាឌមាំប៉ុន្មាននាក់ផ្សេងទៀត ទទួលវាយស្គរ បញ្ជាទ័ព ។
ស៊ុន-វូបែងចែកនារីទាំងនោះជាពីរកងកងខាងឆ្វេងនិងកងខាងស្តាំអ៊ីវ-ជីទទួល
ខាងស្តាំចរ-ជីទទួលខាងឆ្វេង គ្រប់គ្នាបានបំពាក់ដោយអាវុធ ហើយប្រកាសពីវិន័យទ័ព ៖
-ទី១.ហាមមិនឲ្យច្របូកច្របល់ជួរពេលហ្វឹកហាត់,ទី២. ហាមមិនឲ្យជជែកគ្នា,
ទី៣.ហាមល្មើសវិន័យធ្វើសកម្មភាពដោយចិត្តឯង ។
ព្រឹកឡើងទាំងអស់គ្នាបានមកជួបជុំនៅទីលានហ្វឹកហាត់ស្តេចអ៊ូក៏អង្គុយទតពីរាជ
តំណាក់ខាងលើនារីបីរយនាក់ក្នុងឯកសណ្ឋានកងទ័ពដៃស្តាំកានដាវដៃឆ្វេងកាន់ខែលចែក
គ្នាឈរជាពីរជួរ។ស្តេចអ៊ូទតឃើញស្នំទាំងពីរជាទី
ស្រឡាញ់របស់ខ្លួនមានឫកពារយ៉ាងអង់អាចពិតជាគួរឲ្យពេញព្រះទ័យ ។
ស៊ុន-វូចាប់ផ្តើមហើយដាក់បញ្ជាឲ្យរៀបចំក្បួនបានយកទង់លឿងពីរប្រគល់ឲ្យទៅ
មេកងទាំងពីរបញ្ជាឲ្យជាអ្នកដឹកនាំកើរមុខនារីទាំងអស់ត្រូវដើរតាមពីក្រោយមេកងប្រាំនាក់
ជាផ្នែកដប់នាក់ចាក្រុមត្រូវដើរតាមឲ្យជាប់
បន្តរបន្ទាប់គ្នាមិនត្រូវឃ្លាតគ្នាហើយត្រូវស្តាប់សំលេងស្គថយក្រោយឬទៅមុខជំហានដាច់ខាត
មិនត្រូវច្របូកច្របល់ ។
សូត្រចប់បញ្ជាអ្នកទាំងអស់គ្នាឲ្យលុតជង្គង់រងចាំស្តាប់បញ្ជា។មួយសន្ទុះស៊ុន-វូបញ្ជា
មកម្តងទៀតៈ
-ពេលស្គរវាយលើកទី១.ទាំងពីរកងត្រូវងើបឈរឲ្យបានព្រមគ្នា, វាយស្គរលើកទី២.
កងឆ្វេងត្រូវស្តាំបែរឯកងស្តាំត្រូវឆ្វេងបែរ, ស្គ.លើកទី៣.ត្រូវចាប់ផ្តើមប្រយុទ្ធ ពេលឮសូរអាគាំង
ត្រូវដកថយជាបន្ទាន់ ។
គ្រន់តែចេញបញ្ជានារីទាំងអស់ខ្ទប់មាត់សើចស្ទេញស្ទាញ។អ្នកវាយស្គរាយការណ៍ថា៖
-ស្គទី១. បានវាយរួចទៅហើយ តែអ្នកខ្លះអង្គុយ រញ៉េរញ៉ៃគ្មានរបៀប ។
ស៊ុន-វូ ងើបពីជើងម៉ា ហើយនិយាយដោយម៉ឺងម៉ាត់៖
-មិនគោរពវិន័យមិនស្តាប់បទបញ្ជាជាកំហុសរបស់មេដឹកនាំឥឡូវសូត្របទបញ្ជា

# សម្លាប់មាន់បំភ័យស្វា

ឡើងវិញម្តងទៀតហើយពន្យល់ឲ្យបានច្បាស់លាស់។ផ្ទែកបទបញ្ជាក៏សូត្របញ្ជាឡើងវិញ
ម្តងទៀត។អ្នកវាយស្គរក៏ចាប់ផ្តើមវាយស្គរឡើងវិញតែនារី
ទាំងអស់នៅតែសើចលេងខ្សឹបខ្សៀរហើខ្លះផ្អៀងស្មាទៅឆ្វេង ខ្លះទៅស្តាំដូចកំពុងនាំគ្នា
គយគន់ផ្កាអ៊ីងចឹងដែរ ។
ស៊ុន-វូរលាស់ដៃអាវហើយងើបឈររួចទៅទូងស្គរខ្លួនឯងម្តងហើយឲ្យចាប់សូត្រ
បទបញ្ជាឡើងវិញម្តងទៀតតែចាប់ពីថ្នាក់ក្រោមមេកងគ្មាននណាម្នាក់ ដែលថាមិនសើច
ក្អាក់ក្អាយនោះទេសំលេងខ្សៀវខ្វាដូចចាបចូលសំបុក ។
ស៊ុន-វូ បើកភ្នែកសំលក់ត្មែរ ស្រែកគំហាក:
-ផ្ទែកនិតិកម្មនៅទីណា ?
-ចា!
-មិនគោរពវិន័យមិនស្តាប់បទបញ្ជាជាទោសកំហុសរបស់អ្នកដឹកនាំពេលនេះ
បានប្រកាសយ៉ាងម៉ឺងម៉ាត់បីដងទៅហើយ តែទាហានមិនស្តាប់តាម វិន័យត្រូវទទួលទោសបែបណា?
-សម្លាប់នៅនិងកន្លែង ។
-កងទ័ពមិនអាចសម្លាប់ទាំងអស់បានទេទោសកំហុសត្រូវធ្លាក់ទៅលើអ្នកដឹកនាំសេនា
ចាប់មេកងសម្លាប់ចោលភ្លាម ។
សេនាឃើញស៊ុន-វូកំពុងតែមានកំហឹងមិនហ៊ានប្រឆាំងទេក៏ចាប់ស្នំទាំងពីរចងយ៉ាងជាប់។
ស្តេចអ៊ូទតឃើញ ភ្ញាក់ក្រញ៉ាង បញ្ជាមនុស្សឲ្យប្រញ៉ាប់ទៅជួយដោយបញ្ជាថា ៖.
-យើងដឹងពីសមត្ថភាពបញ្ជាទ័ពរបស់លោកហើយតែអ្នកទាំងពីរគឺជាស្នំជាទីស្រឡាញ់
របស់យើងបើគ្មានអ្នកទាំងពីរយើងពិតជាសោយមិនឆ្ងាញ់ផ្ទុំមិនលក់ទេសូមយោគយល់ចំពោះ
យើងលើកលែងទោសឲ្យគេម្តងចុះ ។
ស៊ុន-វូបដិសេធ:
-ក្នុងកងទ័ពគ្មានពាក្យភូតកុហក់ទូលបង្គំត្រូវព្រះអង្គតែតាំងជាមេទ័ព មេទ័ពនើផ្ទាល់
ជាក់ស្តែងពេលខ្លះមិនអាចទទួលធ្វើតាមរាជបញ្ជាបានទេបើមិនគោរពវិន័យកងទ័ពហើយ
លើកលែងទោសបែបនេះតើទូលបង្គំអាចគ្រប់គ្រងកងទ័ពបានឬទេ ? សម្លាប់ !
មួយស្នុះក្បាលស្នំទាំងពីរត្រូវព្យួរឡើងយ៉ងខ្ពស់គ្មាននារីណាម្នាក់ដែលមិនញាក់សាច់
រណ្តំផ្អៀមនោះទេហើយនាំគ្នាលោតជង្គង់គ្រឹបទាំងភ័យខ្លាចដើម្បីរងចាំបញ្ជា ។
ឆ្លងកាត់ការសម្លាប់លើកនេះធ្វើឲ្យនារីទាំងអស់ខ្លបខ្លាចគ្រប់គ្នាការហ្វឹកហាត់ក៏មានដំណើរការ
ទៅមុខយ៉ាងលឿននិងត្រឹមត្រូវ ។ មានតែស្តេអ៊ូអង្គឯង ដែលនៅកលតែនឹកស្រណោះ
អាល័យមិត្តរួមអារុំចលើគ្រែដ៏ស្និទ្ធស្នាលទាំងពីរទឹកភ្នែកជោគថ្ពាល់ស្ទើរបាតបង់ស្មារតី។

# បង្ក្រាបមុនដើម្បីឈ្នះ

ល្បិច(វាយមុនឈ្នះ) ឬ(ធ្វើសកម្មភាពមុនដើម្បីបង្ក្រាប)គឺជាការិះរក
មធ្យោបាយដណ្តើមឱកាសឲ្យបានមុនគឺរហ័សជាងគូរប្រកួតមួយ
ជំហ៊ានតែមិនមែនបានន័យថាជាការប្រកួតប្រជែងដោយសន្តិវិធី
(អ្នកទៅដល់មុនឈ្នះ) នោះទេក៏ពុំមែនក្នុងស្មារតីព្រមព្រៀងគ្នា
(អ្នកទៅដល់មុនជាស្តេចអ្នកទៅដល់ក្រោយជាមន្ត្រី) ក៏ទេដែរ។
ពីព្រោះ(បង្ក្រាបមនុស្ស) ដើម្បីឈ្នះគឺត្រូវតែ(ធ្វើសកម្មភាពមុន)
ពេលនោះធម្មតាទេវាត្រូវតែមានការប្រយុទ្ធគ្នា ដ៏ស្វិតស្វាញមួយ
បើមិនជោគជ័យគឺបរាជ័យដូចច្នេះអ្វីដែលហៅថា: យុត្តិធម៌,
ការស្រឡាញ់, ធម៌មេត្តាឬការអាណិតអាសូរវាមិនអាចកើមានឡើង
នៅក្នុងចន្លោះរវាងយើងនិងសត្រូវជាដាច់ខាត។ ក្រឡេកមើលប្រវត្តិសាស្រ្ត
សម្លឹងមើលពិភពលោកស្ទើរគ្មានមនុស្សណាគ្មានមនុស្សណាម្នាក់
ដែលថាគ្មានគំនិតចង់" លេបផលម្នាក់ឯង" នោះទេ ពេលណាក្តី
ទីណាក៏ដោយ សុទ្ធតែមានរឿងបែបនេះកើតឡើង។ ឲ្យតែមានការដណ្តើម
ត្រូវមានការ(បង្ក្រាប)  ដណ្តើមធំ(បង្ក្រាបធំ) ដណ្តើមតូច" បង្ក្រាបតូច"
ទោះបីជាត្រូវបង្ហូរឈាមក៏ដោយចុះនិយាយរួម(របស់យើង, ត្រូវតែជារបស់យើង
របស់អ្នកឯង ក៏ត្រូវតែក្លាយជារបស់យើង)វត្ថុបំណងបែបនេះ  គឺផ្តើម
ចេញពី ប្រភព "អាត្មានិយម"  នោះឯង ។
អាត្មានិយម វាជាចរិតធម្មជាតិរបស់មនុស្ស ក៏ជាភាពស្មុគស្មាញ
ដែលបន្តរបន្សល់នៅក្នុងសង្គមប្រវត្តិណសាស្រ្តកន្លងមកដែលហៅថា៖
(មិនលំអៀងមិនអាត្មានិយម) វាគ្រាន់តែជាភាសារបោកប្រស់ និងជាសំដី
និយាយឲ្យពិរោះស្តាប់របស់មនុស្សដែលក្រោយពីបានបាយយ៉ាងពេញមាត់
ផឹកយ៉ាងពេញពោះតែប៉ុណ្ណោះការនិយាយឲ្យពិរោះស្តាប់ វាមិនធ្វើឲ្យខូច
ផលប្រយោជន៍ខ្លួនទេ តែវាអាចប៉ះពាល់ដល់អ្នកដទៃ។
ធ្វើសកម្មភាពមុនដើម្បីបង្ក្រាបវាជាវិធី" រហ័សវៃឃើត"
តែត្រូវវាយរបៀបណា?
គឺត្រូវមើលថា អ្នកដែលត្រូវវាយជាមនុស្សប្រភេទណាមានស្ថានភាពយ៉ាងម៉េច?
រឿងបែបនេះមាន កើតឡើងច្រើនណាស់ ឲ្យតែយក ចិត្តទុកដាក់តាមដាន
ហើយមានការសម្រេចចិត្តនិងស្មារតីឈានទៅ មុខពិជាអាចធ្វើបានយ៉ាងល្អ ។
ឱកាសដែលអាចប្រើប្រាស់ល្បិចកលនេះមានគ្រប់ពេលវេលាចំណែកនៅក្នុង
ប្រវត្តិសាស្រ្តដែល បានកត់ត្រាទុកភាគច្រើនសុទ្ធតែជា ប្រភេទរឿង
ដែលទាក់ទងនិងកិច្ចការយោធា ឬ កិច្ចការនយោបាយ ។ រឿងឆ្ងាយមិនបាច់និយាយ
ទីរហោឋានពេកមិនបាច់រំលឹក និយាយតែចំពោះអ្នកដែលយើងធ្លាប់ដឹងធ្លាប់ឮ
ដូចជាលី-ស៊ឺម៉េងដណ្តើមយកក្រុងវ៉ូម៉ែនអ៊ូ-ជីធៀនកំទេចស្តេចលី-លូវេជិនប្លន់រាជ
បល្ល័ងម្ចាស់ក្សត្រី។ ឈឺ-ស៊ីសម្លាប់គួង-ជូ,ខុង-ម៉េងប្រើបញ្ញាដណ្តើមយកខេត្តហាន
-ជុងស៊ី-ម៉ាកាយប្រើល្បិចចាប់ម៉ឹងតាក់ គឺសុទ្ធតែប្រើវិធី(រហ័សវៃឃើត) ដណ្តើម
យកជោគជ័យ។មានរឿងដ៏គួរឲ្យចាប់អារម្មណ៍មួយទៀតគឺ(ប៉ានឆាវបង្ក្រាបតំបន់ ស៊ី-អ៊ី) ។

# បង្រ្គាបមុនដើម្បីឈ្នះ

(ប្រវត្តិពិត) ប៉ាននាវនារជ្ជាកាលហា គឺជាយុវជនម្នាក់ដែលមានចិត្តអង់អាច និង
សេចក្ដីក្លាហាន ក្រោយពី" ក្រវាត់ជក" បំណាងចង់ធ្វើឲ្យខ្លួនល្បីឈ្មោះនៅនគរ
ក្រៅចង់សម្រេចកិច្ចការអ្វីមួយឲ្យវាល្បីល្បាញខ្ទរខ្ទាដល់ដល់ព្រះនគរ ។
មានម្ដងនោះស្ដេចហានបានតែងតាំងគេជាជំនួការអមជាមួយ
លោកគួ-ស៊ុនតំណាងរាជទៅស៊ី-អ៊ី(ក្នុងតំបន់ស៊ីងជាងបច្ចុប្បន្ន)
ពួកគេបានទៅដល់នគរជីន-សាននគរនេះជានគរជិតខាងជាមួយនគរ
សុង-លូជាចំណុចដែលអាណាចក្រកហាន និងនគរ សុង-
លូ កំពុងតែដណ្ដើមគ្នា ។ ស្ដេចនគរនេះព្រះនាមសីនៅក្រោមការគំរាមកំហែងរបស់នគរធំទាំងពីរស្ដេចសី
មិនអាចសម្រេចចិត្តបានថាគួរចងសម្ព័ន្ធ និងនគរណាមួយឡើយថ្ងៃនេះឃើញ
តំណាងរាជទូតនគរហានមដល់ស្ដេចសីទទួលយ៉ាងរាក់ទាក់និងជិតដល់បំផុត
ហើយគិតថា៖និងឆ្លៀតឱកាសនេះកសាងទំនាក់ទំនងជាមួយនគរហានតែម្ដង។
មិនបានប៉ុន្មានថ្ងៃផង ភាពរាក់ទាក់បែបនេះ ស្រាប់តែប្រែក្លាយទៅ
ជាសោះអង្គើយ។
ប៉ាន់-នាវឃើញសភាពបែបនេះយល់ថាវាខុសប្លែកពីធម្មតាក៏កើត
ការសង្ស័យរួចក៏និយាយទៅកានកូនចៅដែមកជាមួយ៖
-ពិតជាចម្លែកណាស់បងប្អូនចាប់អារម្មណ៍ទេមុននេះស្ដេចជីង-សាន
ទទួលពួកយើងរាក់ទាក់បំផុតឥឡូវស្រាប់តែផ្លាស់ប្ដូរមកសោះអង្គើយរឿងនេះ
ប្រាកដជាមានមូលហេតុអ្វីហើយខ្ញុំគិតថា៖ប្រហែលជាខាងនគរ សុង-
លូ បានបញ្ជូនរាជទូតមកដល់ទីនេះហើយ ឥឡូវពិតជាកំពុងធ្វើ
ការប្រកួតប្រជែង
ជាមួយពួកយើងខាងការទូត ដែលធ្វើឲ្យស្ដេចជីង-សានរារែកក្នុងព្រះទ័យ
មិនអាចសម្រេចចិត្តថាគួរតែដើរតាមផ្លូវណាតាមផ្លូវហានឬក៏ផ្លូវសុង-លូ?
ពិសេស ការប្រកាន់ឥរិយាបថរបស់ ពួកគេ អាចសំគាល់បានយ៉ាងងាយបំផុត ។
ប៉ាន-នាវបានធ្វើការវិភាគសភាពការណ៍បែបនេះអ្នកទាំងអស់គ្នាក៏ឯកភាព
តាមការយល់ឃើញរបស់គេដែរ ប៉ាន់-នាវ បន្តរ៖ -បើដូចច្នេះមែនពួកយើង
កំពុងតែចិតនៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់ហើយ។ ប៉ាន-នាវក៏ប្រញ៉ាប់ហៅ
អ្នកបំរើដែលជាជនជាតិ ហ៊ូនោះឲ្យចូលមកជួបរួចគំរាម៖ -យើងមានពាក្យខ្លះ
សួរឯងឯងត្រូវឆ្លើយឲ្យបានច្បាស់និងស្មោះត្រង់បំផុតយើងនិងឲ្យរង្វាន់ឯង
យ៉ាងពេញចិត្តបំផុត យើងនិងកាប់ឯងឲ្យដាច់ជាពីរកំណាត់ស្ដាប់បានទេ?
ប្រាប់មក! តើពួករាជទូតសុង-លូមកដល់ប៉ុន្មានថ្ងៃហើយ មានគ្នាប៉ុន្មាននាក់
ឥឡូវស្នាក់នៅកន្លែងណា? ជនជាតិហ៊ូនេះជាមនុស្សដំឡូងមូសស្រាប់
គ្រាន់តែត្រូវប៉ាន់-នាវ គំរាមប៉ុណ្ណឹងភ័យឡើងរួញខ្លួនដូចឧកឡឿ ក៏រៀបរាប់ប្រាប់
ប៉ាន-នាវ គ្មានចន្លោះ ។
ស្ដាប់ចប់ប៉ាន-វយល់ថាសភាពការណ៍ពេលនេះពិតជាធ្ងន់ធ្ងរទឹកឡើង
ដល់ច្រមុះភ្លើងឆេះដល់ចិញ្ចើមហើយក៏ប៉ុន្តែគេគ្មានតក់ ស្លុតបន្តិចបន្តួចឡើយ
ពេលនេះនៅជាមួយគេមានកម្លាំងទ័ពតែ៣៦នាក់ប៉ុណ្ណោះប៉ាន់-នាវ ប្រមូលផ្ដុំ
ពួកគេទាំងអស់ឲ្យជុំគ្នា......។ ហើយក៏បើកអង្គប្រជុំជាបន្ទាន់មួយជាតំបូង
គឺចាប់ជនជាតិហ៊ូនោះចងទុកមួយកន្លែងការពារកុំឲ្យទៅរាយការណ៍
បន្ទាប់មកក៏ក្រាលកន្ទេលអង្គុយផឹកផ្ទាល់ដីតែម្ដង ។

## បង្ក្រាបមុនដើម្បីឈ្នះ

កំពុងតែផឹកយ៉ងសប្បាយស្រាប់តែប៉ាន់-ឆាវងើបឈរឡើងរួចនិយាយ
ទៅកាន់អ្នកទាំងអស់គ្នាដោយក្ដីរំភើបៈ -ពួកយើងជាជនជាតិហានហេតុអ្វីបាន
ជានាំគ្នាមកដល់វាលខ្សាច់នេះ? គឺចង់សម្រេចកិច្ចការខ្លះដល់នគរប្ដូរ
យកផលប្រយោជន៍តិចតួចក៏ប៉ុន្តែពេលនេះពួកយើងត្រូវឡោមព័ទ្ធហើយទៅមុខ
ក៏មិនរួចថយក្រោយក៏មិនកើតពេលទើប មកដល់ស្ដេចជីងគួសមយ៉ាងណា
ចំពោះពួកយើងនោះទាំងអស់គ្នាដឹងស្រាប់ហើយប៉ុន្មានថ្ងៃនេះ ខាងសុង-លូ
ក៏បានបញ្ជូនរាជទូត មកដល់ដែរអាកប្បកិរិយារបស់គេក៏ផ្លាស់ប្ដូរទៅជា
សោះអង្គើយនេះសរបញ្ជាក់ឲ្យឃើញថាគេពិតជាមានគំនិតមិនល្អ
ចំពោះពួកយើងហើយបើសិនជាគេដើរមួយជំហ៊ានទៀតគឺចាប់បញ្ជូន
ពួកយើងទៅនគរសុង-លូពិតជារីវរធំហើយដល់ពេលនោះ ពួកយើង ពិតជា
ស្លាប់គ្មានដីកប់សូម្បីតែសាកសពក៏ត្រូវឆ្កែចចកហែកស៊ីដែរស្ថានភាព
ពេលនេះកានតែធ្ងន់ធ្ងរឡើងៗ បងប្អូនទាំងអស់គ្នាជួយគិតមើល
តើធ្វើយ៉ាងណាទើបអាចរួចផុតពីមាត់ខ្លាបាន?
ឮនិយាយបែបនេះ អ្នកទាំងអស់គ្នាក៏សម្លឹងមើលមុខគ្នា ក្នុងចំណោមនោះម្នាក់និយាយ៖
-រឿងរ៉ាវដល់ថ្នាក់នេះទៅហើយ ទុកឲ្យលោកម្ចាស់ជាអ្នកសម្រេចទៅចុះ ។
-ត្រូវ ! ពួកយើងដើរតាមលោកម្ចាស់ទាំងអស់គ្នា! និយាយព្រមតែម្ដង ។
ប៉ាន់-ឆាវ បន្តរៈ
-ពេលនេះមានតែផ្លូវពីរប៉ុណ្ណោះត្រូវជ្រើសរើសឬមួយក៏រត់ឬមួយក៏ប្រយុទ្ធ
តែបើរត់ក៏រត់រកសេចក្ដីស្លាប់ដែរ ព្រោះថាយើងមានគ្នាតែជាង៣០នាក់ប៉ុណ្ណោះ
សួរថាតើអាចរត់ទៅដល់ទីណា? ខ្លាចមិនទាន់ទាំងបានពាក់កណ្ដាលផ្លូវផង
ត្រូវសម្លាប់បាត់អស់ទៅហើយខ្ញុំយល់ថាមានតែបធ្យោបាយមួយប៉ុណ្ណោះ
គឺត្រូវតែប្រយុទ្ធអ្នកណាវៃមុនពិតជាឈ្នះ បើយើងមិនចូលរូងខ្លាម្ដេចនិងចាប់
ខ្លាបានទាំងអស់គ្នាយល់ស្របទេ?
-យល់ព្រម !
-ល្អយើងដឹងថាពួករាជទូតសុង-លូមានគ្នាប៉ុន្មាននាក់ហើយស្នាក់នៅទីណា។
យប់នេះយើងចាត់ការតែម្ដងពេលនោះ ពួកវានិងស្លន់ស្លោរ ព្រោះឥឡូវនេះ
ពួកវាកំពុងបានចិត្តសម្បើមដែណាស់ មិនស្មានថាពួកយើងមានការសម្រេច
ចិត្តនិងសកម្មភាពបែបនេះទេដូច្នេះ ពិតជាគ្មានការប្រុងប្រយ័ត្នចំពោះការ
វាយឆ្មក់របស់ពួកយើងឡើយទំរាំតែដឹងគឺវាចប់កិច្ចការបាត់ទៅហើយពេល
ដោះស្រាយពួកអាចោលម្សៀតនេះ ចប់ហើយ  ស្ដេចជីង ពិតជាយល់ព្រមដើរ
តាមពួកយើងដោយស្លាប់ចិត្តមិនខានបែបនេះក្ដីបំណងរបស់ពួកយើងមិន
បានជោគជ័យហើយឬ?   ម្នាក់នោះក៏ហារមាត់និយាយ៖
 រឿងនេះវាធំដុំណាស់វាប៉ះពាល់ដល់ទំនាក់ទនងការទូតយកល្អគួរតែពិភាក្សា
ជាមួយលោកម្ចាស់គួរជាមុនសិន
 –ឈើយ! ប៉ាន់-ឆាវ ក្ដៅឆេវនិយាយទាំងក្ដៅក្រហាយ៖ – គ្រោះល្អ,គ្រោះអាក្រក់
ជោគជ័យឬបរាជ័យគឺសម្រេចគ្នានៅក្នុងយប់នេះឯង លោកម្ចាស់គួរជា
អ្នករៀនសូត្រមានចរឹតទន់ខ្សោយបើគេដឹងរឿងនេះពិតជានៅធ្វើសង្គ្រាម
ត្រជាក់មិនខានឲ្យតែចូលរឿងចរចារពិភាក្សាពិតជាយប់វែង សុប៉ិនច្រើន
ហើយចៃដន្យផែនការរបស់ពួកយើងត្រូវលេចឮទៅក្រៅមិនរីវរធំទៅហើយ?

# បង្ក្រាបមុនដើម្បីឈ្នះ

ហើយក៏បែរមុខមកកាន់អ្នកទាំងអស់គ្នា រួចនិយាយ៖
អ្នកទាំងអស់គ្នាយល់ថាត្រូវឬទេហេតុអ្វីយើងត្រូវយកជីវិតរបស់ខ្លួនទៅផ្ញើ
លើជនម្នាក់ដែលមិនហ៊ានទាំងអារករមាន់ផងនោះ? ដល់តំណាក់កាលចុង
ក្រោយនេះទៅហើយនៅសង្ឃឹមថាអាចចរចារបានឬយ៉ាងម៉េច?
ត្រូវ! ស្រែកឯកភាពទាំងអស់គ្នាតែម្តង -សម្រេចចិត្តតាមលោកម្ចាស់
ប្រយុទ្ធប្តូរស្លាប់រស់ជាមួយពួកវាឲ្យដឹងស ខ្មៅម្តង។ ទាំងអស់គ្នាក្តាប់ដៃ
ខាំមាត់ទឹកចិត្តអង់អាចឡើងដល់កំរិតរួចក៏ប្រញ៉ាប់ប្រញ៉ាល់ផ្លាស់ប្តូរ
សម្លៀកបំពាក់ទាញអាវុធមកកាន់គ្រប់ដៃ  រង់ចាំទទួលបញ្ជាចេញដំណើរ ។
មិនយូរប៉ុន្មាន មេឃក៏ងងឹតភាពងងឹតនៅពេលយប់មើលអ្វីក៏ឃើញតែស្នុងៗ
ប៉ុណ្ណោះ សន្ទឹកខ្យល់បក់រួៗក្លួចខ្យាច់ហើរមកប៉ះពេញមុខកូនប្រុសដ៏អង់អាច
ក្លាហានមួយក្រុមនេះបានលបលួចចូលទៅដល់ជំរុំស្នាក់អាស្រ័យ  របស់ពួករាជទូតសុង-លូ,
ប៉ាន់-ឆាវបានបែងចែកកម្លាំងត្រៀមប្រយុទ្ធជាស្រេចទាំង៣៦នាក់ចែកចេញ
ជាពីរក្រុម ១០នាក់លាក់ខ្លួន  នៅខាងក្រៅដៃកាន់ស្គរគ្រប់គ្នា ដល់ពេលនោះ
ត្រូវ "វាយកម្លា" ។  ប៉ាន់-ឆាវ ក៏ខ្សឹបប្រាប់ពួកគេ៖ -ឲ្យតែឃើញក្នុងជំរុំមាន
ភ្លើងឆេះត្រូវប្រឹងវាយស្គរនិងស្រែគំហកកុំឈប់ឲ្យសោះរហូតទាល់តែទទួលបាន
ជោគជ័យទាំងស្រុងចាំឈប់ ។
ក្រៅពីនេះសល់គ្នាជាងម្ភៃនាក់ដោះអាវអាក្រាត់ផ្នែកខាងលើទាំងអស់គ្នាដៃ
កាន់កាំបិតក្រោមការដឹកនាំរបស់ប៉ាន់-ឆាវប្រៀបបាន  និងខ្លាកំណាចចុះពីភ្នំ
សម្រុកចូលជំរុំពួកសុង-លូតែម្តងដុតជំរុំបណ្តើរស្រែកបណ្តើរជួបសេះកាប់ផ្ទង
ស្ទាបប៉ះមនុស្ស មានអាវចាក់រឹបពេលនេះពួករាជទូតសុង-លូទាំងអស់កំពុងតែដេក
សុបិននៅក្នុងភួយនៅឡើយស្រាប់តែត្រូវសម្លេងវាយប្រហារស្រែកឲ្យភ្ញាក់
ស្លន់ស្លោរពេកក្រៃក្រឡេកទៅឃើញមនុស្សគ្មានពាក់អាវមួយក្រុមកាប់ឆ្វេង

ចាក់ស្តាំឮសំឡេងស្គរលាន់ឮដូចរន្ទះសម្លេងសម្លាប់កងរំពងជ្រែកយប់ងងឹត
ចង់បោលតែគ្មានផ្លូវរត់ ចង់ប្រយុទ្ធក៏រកអាវុធមិនឃើញ នៅពីមុខជាខ្លាកំណាច
នៅពីក្រោយគឺភ្លើងដ៏សន្ធោ សន្ធៅ ហេតុនេះហើយ ដូចសត្វជ្រូកដែលធ្លាយទ្រុង
ខ្លះរត់ទៅលិច ខ្លះបោលទៅកើត ខ្លះត្រូវស្លាប់ដោយភ្លើងឆេះ ខ្លះត្រូវសម្លាប់
ដោយកាំបិត តែកន្លះនាក់ក៏រត់មិនរួចដែរ មនុស្សជាវមួយរយនាក់ត្រូវស្លាប់
អស់គ្មានសល់។
ដល់ព្រឹកឡើង ប្រមូលកម្លាំងត្រួតពិនិត្យ ឃើញត្រូវរបួសប៉ុន្មាននាក់ដែរ
តែនៅគ្រប់ចំនួនទាំងអស់ ពិតជាទៅគ្នា៣៦នាក់ មកវិញ១៨គូមែន។
រួចរាល់អស់ហើយ ទើបយករឿងនេះទៅរាយការណ៍ឲ្យលោកម្ចាស់ គួ-ស៊ុន
មិនខុសមែនគ្រាន់តែឮភ្លាម ភ្ញាក់ក្រញ៉ាំងផ្លាស់ប្តូរទឹកមុខតែម្តង ។
ប៉ាន-ឆាវ យល់ពីចិត្តគំនិតរបស់គេ ក៏បបួលទាំងអស់គ្នាស្រែកព្រមគ្នាថា៖
-ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់លោកម្ចាស់ យើងបានសំរេចភារៈកិច្ចដ៏ត្រចះ
ត្រចង់ដលនគរ ។ ក្រោយពីបានស្រែកអបអរមក ទើបលោកម្ចាស់គួរផ្លាស់ប្តូរ
ទឹកមុខមកជាសប្បាយរីករាយវិញ ។
ប៉ាន់-ឆាវ ក៏ដឹកនាំអ្នកទាំងអស់គ្នា ទៅកាន់រាជតំណាក់ស្តេច ជិង-សាន
រួចបោះក្បាលពួករាជទូតសុង-លូ ទៅដីព្រូសបង្ហាញជិង ស្តេចជិង-សាន

## បង្ក្រាបមុនដើម្បីឈ្នះ

ត្រូវធ្វើឲ្យភ័យឡើងស្លេកមុខលោះព្រលឹង
សេនាឆ្វេងស្ដាំក៏បញ្ឈរ
ភ្នែកស្លាក់វាចារគ្រប់គ្នាដែរ ។
តែប៉ាន់-ឆាវ គ្មានអំនួតបន្តិចណាទេ គេប្រើពាក្យទន់ភ្លន់ទៅលួងលោម
និងផ្សព្វផ្សាយជំហរនយោបាយរបស់រាជការហានដល់ពួកគេ ហេតុនេះស្ដេចជិង
ក៏យល់ព្រមទាំងកាយសប្បាយទាំងចិត្តស្លាប់ទាំងគំនិតដើរតាម ផ្លូវនគរហាន
នាពេលនោះតទៅ ៕

# ព្រួញមួយបាញ់បានសត្វពីរ

ព្រួញមួយបាញ់បានសត្វពីរ បានន័យថា៖ ក្នុងពេលតែមួយប្រើមធ្យោបាយតែមួយអាចផ្តួលសត្រូវឲ្យបរាជ័យ ចាប់ពីពីរនាក់ឡើងទៅ ឬក៏អាចទទួលផលប្រយោជន៍ចាប់ពីពីរឡើងទៅ។

ការប្រើប្រាស់ល្បិចកលហ៍នេះ មិនធម្មតាទេ ហើយក៏មិនងាយស្រួលដែរ ព្រោះថាល្បិចនេះ គឺយើងត្រូវប្រឈមមុខនិងគូរសត្រូវជាច្រើននាក់ឲ្យតែខ្វះការប្រុងប្រយ័ត្ន ឬធ្វេសប្រហែសតែបន្តិចពិតជាត្រូវជួបគ្រោះអាសន្នធំហើយ ហេតុនេះមុននិងក្រោយនៃកិច្ចការត្រូវតែព្យាយាមរង់ចាំឲ្យបាននូវបរិយាកាសនិងពេលវេលាដែលសមស្រប ។

គោលគំនិតនិងសកម្មភាពរបស់មនុស្សដែលបែកឆ្វេងមានច្រើនសន្ធឹកសន្ធាប់ណាស់ គឺព្រោះតែផលប្រយោជន៍ និងកេរ្តិ៍ឈ្មោះប៉ុណ្ណោះ។ ហេតុតែត្រូវការកេរ្តិ៍ឈ្មោះ គ្រប់គ្នាត្រូវតែខំប្រឹងដណ្តើមនៃការប្រជែងពិតហើយត្រូវតែមានអ្នកឈ្នះនិងអ្នកចាញ់ អ្នកឈ្នះពិតជាសប្បាយហើយមុខខ្លាញ់ អ្នកចាញ់និងក្រៀមក្រំហើយសើចសេះឬក៏ត្រូវរងគ្រោះរបួសទាំងសងខាង។

ពេលអនុវត្តល្បិចកលហ៍នេះត្រូវផ្អែកលើគោការណ៍ ដូចនេះត្រូវស៊ើបឲ្យដឹងនូវស្ថានភាព ចិត្តគំនិត លក្ខខ័ណ្ឌនៃជីវភាពបរិយាកាសជុំវិញរបស់បដិបក្ខឲ្យបានច្បាស់លាស់ ធ្វើការប្រៀបផ្ទឹមចំណុចដូចគ្នា បើគូរបដិបក្ខជាមនុស្សដែលស្រឡាញ់កេរ្តិ៍ឈ្មោះ គួរតែផ្តល់ការសរសើរឲ្យបានច្រើនតែបើជាមនុស្សលោភលន់ "ទ្រព្យសម្បត្តិផលប្រយោជន៍" គួរធ្វើចិត្តឲ្យទូលាយតែបើសិនជាគូរបដិបក្ខត្រូវការទាំង "កេរ្តិ៍ឈ្មោះ" ចង់បានទាំង"ផលប្រយោជន៍" ក្រៅពីការសរសើរ និងធ្វើចិត្តឲ្យទូលាយ ជៀសមិនផុតពីបញ្ចុះពេជ្របន្ថែមលើចញ្ចៀនដែលពាក់នោះឡើយ។

នេះហើយដែលហៅថា៖ ធ្វើតាមចិត្តឲ្យតាមចង់គោលបំណង គឺមិនឲ្យគូរបដិបក្ខកើតការសង្ស័យ តែបើទោះជាមានការសង្ស័យ ក៏មិនដល់ថ្នាក់ពាក់មុខយក្សដាក់គ្នាភ្លាមៗដែរ ធ្វើបែបនេះ គេហៅថាការចៀនត្រីឲ្យឆ្អិនតាមសម្រួលរង់ចាំដល់ពេលវេលា ដែលសមស្របនិងទុំជោរហើយបញ្ចេញស្នៀតពិសពុល រកលេសបង្កើតបញ្ហាអុជអាលឲ្យភាគីទាំងប៉ុន្មាន កើតការក្តៅក្រហាយដាក់គ្នារុញឲ្យប្រយុទ្ធយកស្លាប់រស់តែម្តងពេលនោះ យើងអាចអង្គុយគងអន្ទាក់ខ្លា មើលខ្លាខាំគ្នារង់ចាំរើសយកឆ្អឹង ព្រលាត់យកស្បែកខ្លាដោយត្រជាក់ចិត្ត ។

មនុស្សដែលឆ្លាតបំផុត ក្រោយសម្លាប់មនុស្សហើយ អាចឲ្យក្បាលដែលធ្លាក់ទៅដីចេះស្រែកថា(អរគុណ) ចំពោះខ្លួនទៀតផង។

(ប្រវត្តិជាក់ស្តែង) ក្នុងសម័យឈុវ-ឈីវ (មុនគ.ស.៧៧០ដល់៤៧៦) ជនមានអំណាចខ្លាំងនៅក្នុងនគរឈី មានបីរូប មួយឈ្មោះធៀន-ខាយជាង, ពីរឈ្មោះកូវ-ជីយឺប៉ី, បីឈ្មោះកុង-ស៊ុនជា ជនទាំងបីទទួលការស្រឡាញ់យ៉ាងខ្លាំងពីព្រះរាជានៃនគរ អ្នកទាំងបីបានសុំគ្នាធ្វើជាបងប្អូនធម៌ ហើយបានប្រសិទ្ធនាមខ្លួនឯងថា៖ (អ្នកក្លាហានទាំងបីនៃអាណាចក្រឈី) ពួកគេសម្អាងលើសិទ្ធិអំណាចដើររាតត្បាត តាមអំពើចិត្ត  ក្នុងកែវភ្នែករបស់ពួកគេគ្មានចាត់

ព្រួញមួយបាញ់បានសត្វពីរ
ទុកអ្នកណាស្មើឡើយ សូម្បីតែនៅចំពោះមុខ ព្រះភ័ក្រព្រះអង្គ ក៏សឹងប្រើពាក្យហៅ" យើង-ឯង" ទៅហើយ។
ពេលនោះមន្ត្រីបះបោរឈឺន-អ៊ូយី,លៀង-ឈីវជី ។ល។ បានឆ្លៀតឱកាសទិញទឹកចិត្តពួកទាំងបីនេះ ដើម្បីរួមគំនិតក្បត់ផ្តួលរំលំរាជបល្ល័ង្គ ដណ្តើមអំណាច។
លោកឧបរាជអាន់ពី ពិតជាទាស់ភ្នែកណាស់ ដោយឃើញថា ស្ថានភាពអាក្រក់បែបនេះ ចេះតែរីករាលដាលធំឡើងៗ ដែលពិតជានឹងផ្តល់គ្រោះថ្នាក់ដល់នគរ លោកមានការព្រួយបារម្ភគ្រប់ពេលវេលា លោកឧបរាជយល់ច្បាស់លាស់ថា៖ កម្លាំងខ្លាំងរបស់ពួកទាំងនេះ គឺបិតនៅលើកម្លាំងទ័ពមេទ័ពទាំង៣ គឺអាត់៣ ច្រើនលើកហើយដែលលោកឧបរាជមានបំណងកំចាត់ពួកទាំងនេះចោល តែពួកនេះកំពុងទទួលការស្រឡាញ់ពីព្រះអង្គព្រះអង្គ ពិតជាមិនយល់ស្របតាមឡើយ បារម្ភថា អាចនិងស្រោចគល់វិញទៀតផង ។
មានថ្ងៃមួយនោះព្រះរាជាលូ-ចាវកុង ដែលជានគរជិតខាងបានដឹកនាំមន្ត្រីមួយចំនួនដែលរួមមានលោកស៊ឺ-លី និងស៊ូ-ស៊ុនជូ ។ល។ មកសួរសុខទុក្ខនិងសុំចូលគាល់ព្រះរាជានៃនគរឈី ព្រះរាជាក៏បញ្ជាឲ្យរៀបចំពិធីជប់លៀងមួយដើម្បីទទួលភ្ញៀវ ហើយក៏បានអញ្ជើញលោកឧបរាជ អាន-ពី និងសព្វមុខមន្ត្រីចូលរួមពីធីផងដែរ។ ដើម្បីបង្ហាញនូវកិត្យានុភាព ក្នុងនោះក៏មានជនខ្លាំងទាំង៣ក្នុងឯកសណ្ឋាជាមេទ័ពយ៉ាងសង្ហា នៅកំដរឆ្វេងស្តាំទៀតផង។
ការជល់កែវបីជុំបានកន្លងផុតទៅ លោកឧបរាជអាន់ ក៏សុំយោបល់ពីព្រះរាជា ៖ ក្រាបទូលព្រះអង្គ ផ្លែសេដាមាសនៅក្នុងសួនមានទុំខ្លះហើយកម្រនិងមានឱកាសដែលមានពីធីបែបនេះណាស់ តើអាចបេះខ្លះដើម្បីយកមកជូនភ្ញៀវដែរឬទេ? ក្រាបទូល?
ព្រះរាជាក៏យល់ព្រម ហើយចាត់អ្នកយាមសួនទៅបេះ តែលោកឧបរាជឃាត់ហើយនិយាយថា៖
ក្រាបទូលព្រះអង្គ ផ្លែសេដាមាសគឺជាផ្លែឈើទិព្វដ៏មានតម្លៃចាំបាច់ទូលបង្គំទៅបេះដោយផ្ទាល់ដៃចុះ ធ្វើដូចច្នេះទើបសក្តិសមនូវតម្លៃរបស់វា។ មួយសន្ទុះក្រោយសេដាមាសមួយចំនួនក៏បានបេះមកដល់ហើយយក ទៅដាក់លើតុផ្លែសេដាមាសមួយៗធំប៉ុនចានគម ក្រអូបឈ្ងុយឈ្ងប់គួរឲ្យស្រក់ទឹកមាត់។
ពេលនោះព្រះរាជាសួរ៖-មានតែប៉ុន្មានផ្លែហ្នោងទេឬ ?
លោកឧបរាជឆ្លើយ៖
-ក្រាបទូល នៅសល់ប៉ុន្មានផ្លែទៀតដែរតែមិនទានទុំ មានទុំតែ៦ផ្លែនេះប៉ុណ្ណោះ ។
ព្រះរាជាទាំងពីរអង្គ ក៏យកមួយម្នាក់មកសោយ ហើយសរសើរថាពិតជាឆ្ងាញ់អស្ចារ្យមែន ។
ព្រះរាជានគរឈី មានបន្ទូលទៅកាន់លោក ស៊ូ-សុនជូ៖
-នេះជាផ្លែសេដាមាស ដែលកម្រមាន លោកម្ចាស់ស៊ូមានឈ្មោះបោះសម្លេងគ្រប់ទិសទីមានគុណបំណាច់ ចំពោះចំណងមិត្តភាពរវាងនគរទាំងពីរ យើង ប្រទានឲ្យលោម្ចាស់មួយផ្លែ ។ លោកម្ចាស់ស៊ូលុតជង្គង់គ្រឹបហើយតបៈ
-ទូលបង្គំម្តេចនឹងស្មើលោកឧបរាជអាន់នោះ? ផ្លែឈើទិព្វនេះគួរតែប្រទានឲ្យគាត់ទើបស័ក្តិសម ។

## ព្រួញមួយបាញ់បានសត្វពីរ

ព្រះរាជាញញឹមហើយមានបន្ទូល៖

-បើអ្នកទាំងពីរចេះតែរុញគ្នាទៅវិញទៅមកបែបនេះ ណ្ហើយយើងប្រទានម្នាក់មួយផ្លែទៅចុះ ។

ពេលនេះនៅសល់ផ្លែសេដាមាស់ពីរតែប៉ុណ្ណោះ លោកឧបរាជអាន-យី យល់ថា ឱកាសមកដល់ហើយ ក៏សុំការអនុញ្ញាតិពីព្រះរាជាផ្សព្វផ្សាយដល់សព្វមុខមន្ត្រីឲ្យគេទាំងឡាយ លើកអំពីគុណបំណាច់រៀងៗខ្លួនកន្លងមក ចំពោះអ្នកដែលមានគុណបំណាច់ច្រើនលើសគេ និងត្រូវបានប្រទានផ្លែសេដាមាសនេះឲ្យបរិភោគ ។

ពេលនោះមេទ័ពកុង-ស៊ុនជា ងើបក្រេះបង្ហាញខ្លួនភ្លែតចេញវាចារដោយអំនួត និយាយឡើងបែកពពុះមាត់: -កាលពីឆ្នាំមួយនោះ ខ្ញុំបានទៅបរបាញ់សត្វជាមួយព្រះអង្គនៅភ្នំតុងសាន ហើយបានសម្លាប់ខ្លាកំណាចដ៏ធំមួយដោយផ្ទាល់ដៃ ការពារបានអាយុជីវិតរបស់ព្រះអង្គ តើគុណបំណាច់នេះធំឬមិនធំ ?

លោកឧបរាជ អាន់ ប្រញ៉ាប់តបភ្លាម:

-ការពារអាយុជីវិតព្រះអង្គ គុណបំណាច់នេះ ពិតជាធំធេងត្រូវតែទទួលការប្រទាន! មេទ័ព កុង-ស៊ុនជា ទទួលផ្លែសេដាមាសមកទំពារ យ៉ាងខែងរែង ព្រមទាំងវាសភ្នែកសម្លឹងជុំវិញខ្លួនមួយត្រួសដោយក្រសែភ្នែកអំនួត។

ពេលនោះមេទ័ពកូវ-ជីយី ក៏ដណ្តើមងើបឈរហើយនិយាយ៖

-សម្លាប់ខ្លាមានអីគួរឲ្យអស្ចារ្យ? ឆ្នាំមួយនោះនៅក្នុងរលកខ្វរខ្មាញ់នៃទន្លេវ៉ាងហ៊ឺ យើងត្រូវលេចអណ្តែតជាច្រើនយោជន៍ តែយើងនៅតែយើង នៅអាចសម្លាប់អណ្តើកយក្សដ៏ធំមួយក្បាលរំដោះព្រះអង្គផុតពីសេចក្តីស្លាប់ តើគុណបំណាច់នេះយ៉ាងម៉េចដែរ ?

ពេលនោះព្រះអង្គក៏មានបន្ទូល ៖

-ពិតជាពិបាកនឹងធ្វើឲ្យដូចណាស់ ពេលនោះបើសិនជាគ្មានលោកមេទ័ពទេមនុស្សមួយទូកច្បាស់ជាត្រូវលិចស្លាប់ទាំងអស់គ្នាមិនខាន។ហើយក៏ប្រទានផ្លែសេដាមាស និងស្រាដល់មេទ័ព កូវ ទៀតផង ។

ស្រាប់តែដូចខឹងទុកពីកាលណាមេទ័ពធៀន-ខាយជាង ហាក់មួម៉ៅក្តៅក្រហាយក្នុងខ្លួនពោលទាំងមួហ្មង:

-យើងធ្លាប់ទទួលបញ្ជាឲ្យវាយនគរយី ចាប់បានឈ្លើយសឹករាប់រយពាន់នាក់បង្ខំឲ្យនគរយីចុះចាញ់ ល្បីកក្រើករំពងដល់នគរជិតខាងធ្វើឲ្យបាក់បបខ្លបខ្លាចនាំគ្នាមកថ្វាយសួយសារអាករជាបន្តបន្ទាប់ ប្រែក្លាយនគរទៅជាមេសម្ព័ន្ធ តើបែបនេះអាចរាប់ថាជាគុណបំណាច់បានដែរឬទេ? អាចទទួលការប្រទានបានឬទេ? និយាយចប់ក៏វាសភ្នែក សម្លឹងជុំវិញ ហាក់បង្ហាញឲ្យឃើញថាគូនកនខ្លួនមិនអាចស្មើនិងខ្លួនបានឡើយ ។

លោកឧបរាជអាន់ ក៏ប្រញ៉ាប់ប្រញ៉ាល់ទូលព្រះរាជា ៖

-ក្រាបទូលព្រះអង្គ តាមការរៀបរាប់គុណបំណាច់របស់លោកមេទ័ពធៀន ពិតជាធំធេងជាងលោកមេទ័ពកុង-ស៊ុនជា និងកូវ-ជីយី

## ព្រួញមួយបាញ់បានសត្វពីរ

ដប់ដង ឯណោះ តែគួរឲ្យស្តាយណាស់ផ្លែសេដាមាស បានប្រទាន អស់ទៅហើយតើអាចប្រទានស្រាមួយកែវ ជំនួសសិនចាំពេល ផ្លែសេដាមាសទុំចាំប្រទានសងជាក្រោយតើយ៉ាងម៉េចដែរក្រាបទូល ។

ព្រះអង្គដឹងថាមេទ័ពធៀន កំពុងអាក់អន់ចិត្តខ្លាំងណាស់ ក៏ខំប្រឹងប្រែងជួយលួងលោមដោយមានបន្ទូលថា៖

-គុណបំណាច់របស់លោកមេទ័ពធៀន ពិតជាធំធេងជាង អ្នកណាទាំងអស់ ស្តាយតែលោកមេទ័ពមានប្រសាសន៍ក្រោយ គេទៅហើយ......។ ពេលនេះ មេទ័ពធៀន-ខាយជាង ស្លឹកមុខ ហ៊ឹងស្លឹកត្រចៀកស្តាប់អីក៏លែងចូលដែរ ក្តាប់ដាវខឹងឡើងញ័រដៃ ហើយស្រែកដោយខឹងសម្បា៖

-សម្លាប់ខ្លាប្រហារអណ្តើកមានអីគួរឲ្យអស្ចារ្យ? ដើម្បីព្រះនគរ យើងធ្លាប់ធ្វើដំណើររាប់រយពាន់យោជន៍ ប្រឡូកក្នុងសមរភូមិ ទទួលបានជោគជ័យរាប់មិនអស់ តែបែរជាមិនបានទទួលការយកចិត្ត ទុកដាក់ទៅវិញហើយថែមទាំងត្រូវទទួលការអាម៉ាស នៅចំពោះមុខសព្វមុខមន្ត្រីនៃនគរទាំងពីរ ត្រូវគេសើចយំ តើមានមុខមាត់ឯណារស់តទៅទៀត? សឹងមិនទាន់ចប់ប្រយោគ អូសដាវខ្វាក ដាច់បំពង់ករស្លាប់មួយរំពេច ។

មេទ័ពកុង-ស៊ុនជា ភ្ញាក់ក្រញ៉ាំងដូចគេធាក់ទាញដាវ លោតភ្លែក ចេញមកក្រៅហើយនិយាយដោយការអៀនខ្មាស:

-ពួកយើងមានគុណបំណាច់តិចតួច បែរជាទទួលការប្រទាន ចំណែកលោកមេទ័ពធៀន មានគុណបំណាច់ធំធេង តែមិបាន ទទួលការប្រទានផ្លែសាដាមាសទៅវិញ គិតឲ្យសព្វទៅពិជាគួរ ឲ្យអៀនខ្មាស់ណាស់....។វាសដាវភ្លែត ក៏បញ្ចប់ជីវិតតែម្តង ។

កូវ-ជីយី ក៏លោតចេញមកដែរ ពោលទាំងក្តីរន្ធត់:

-យើងទាំង៣ គឺជាបងប្អូនធម៌ និងគ្នាបានស្បថសច្ចារហើយថា នឹងរួមសុខទុក្ខស្លាប់រស់ជាមួយគ្នា ពេលនេះអ្នកទាំងពីរ បានស្លាប់បាត់ទៅហើយ តើខ្ញុំម្តេចនឹងអាចលួចរស់ម្នាក់ឯងទៅកើត ?

ចប់សំដី-ក្បាលក៏ដាច់ធ្លាក់ដែររឿងរ៉ាវកើតឡើងតែមួយ ពព្រិចភ្នែកប៉ុណ្ណោះព្រះរាជាចង់ខាត់ក៏មិនទាន់ដែរ ។

ចាប់ពីពេលនោះមក ទើបលោឧបរាជអាន់ អាចកំចាត់ពួក ប៉ះបោលបានដោយគ្មានឧបសគ្គ សម្រេចបាននូវគោលបំណង តបស្នងសងគុណដល់នគរ។ នេះហើយការប្រើល្បិចបាញ់ព្រួញមួយ បានសត្វពីរដល់វាងវៃរបស់លោកឧបរាជអាន់ពី៕

# ចាប់ចោរ ត្រូវចាប់មេ

ពាក្យថា "ចាប់ចោរត្រូវចាប់មេ" តាមសុភាសិតមួយសរសេរថា៖ យឹតធ្នូត្រូវយឹតឲ្យខ្លាំង ប្រើព្រួញត្រូវប្រើព្រួញវែង បាញ់មនុស្សត្រូវបាញ់សេះជាមុន ចាប់ចោរត្រូវចាប់មេ។ បានន័យថា ៖ បើសិនធ្វើកិច្ចការអ្វីមួយ ត្រូវតែដាក់ចិត្ត អនុវត្តតាមលំដាប់លំដោយនៃកិច្ចការ ក៏ប៉ុន្តែបើប្រើជាល្បិចកលដើម្បីយកចាញ់ឈ្នះ គឺមិនដូច្នោះទេ ក្នុងពេលប្រយុទ្ធ ចាំបាច់ត្រូវតែវាយសំដៅចំណុចសំខាន់របស់សត្រូវ ឬបញ្ជាការរបស់សត្រូវ ឲ្យតែអាចកំទេចបានមេដឹកនាំរបស់សត្រូវហើយ ពេលនោះអង្គការចាត់តាំងនោះ ប្រៀបបាននិងសត្វពស់ដែលគ្មានក្បាល សភាពជ្រួលច្របល់និងកើតមានឡើង...។

ដែលហៅថាមេដឹកនាំ គឺសំដៅលើជនមានអំណាចពិតប្រាកដ និង មានឥទ្ធិពលលើគ្រប់គ្នា បើគ្មានល័ក្ខខ័ណ្ឌ បែបនេះទេ ទៅបីជាគេមានតួនាទីធំប៉ុណ្ណា ក៏គ្មានប្រយោជន៍ដែរ។ ដូចជា ក្នុងជំនាន់ សាមកុក ស្តេចឡឹកី ដឹងតែពីរឿងស្រីស្រា ព្រះនាមអាតូវ ធំបានប្រយោជន៍អ្វី? បានអំណាចនៅដៃហើយ បែរជាបន្ថែមបន្ទុកនគរទៅវិញ ដឹងតែពីចំណាយចាយមិនដឹងមុខមិនស្មើនិង ជូកឹលៀង (ខុង ម៉េង) ដែលជាថ្នាក់ក្រោម ជាអ្នកទទួលបន្ទុករ៉ាប់រងសុខទុក្ខរបស់នគរ តែងជាចំណុច " ស៊ីបឬប្រហារ " របស់នគរជាសត្រូវ។

មេដឹកនាំ គឺជាបេះដូងនៃអង្គការចាត់តាំងមួយ គឺជាដួងវិញ្ញាណនៃអង្គការប្រមូលផ្តុំនោះ អាច " ចាប់មេ "បាន ពិតជាអាចធ្វើឲ្យអង្គការចាត់តាំងនោះ ច្របូកច្របល់ បំផ្លាញបាននូវសកម្មភាព និងបណ្តាញខ្សែរយៈ...យ៉ាងហោចណាស់ ក៏អាចធ្វើឲ្យផ្ទៃក្នុងមានការប្រែប្រួលដែរ។

មធ្យោបាយ (ចាប់មេ) មានការប្រែប្រួលរាប់មិនអស់  មិនថាប្រើបញ្ញាឬអាវុធ (ឲ្យតែអាចសម្រេចបាន តាមគោលបំណង) ធម្មតាទេ ត្រូវតែប្រើ (មធ្យោបាយមិនរើសមុខ) ទោះបីត្រូវប្រើវិធីឆក់ប្លន់ក៏ដោយចុះ។ ដូចជា ជំនាន់ សាមកុក ឆាវឆាវ ប្រើល្បិចចាប់បង្ខំស្តេច ដើម្បីបង្ក្រាបដល់បណ្តាស្តេចក្រាញ់។ ឈើនក្លែងផ្លាកបញ្ជា មាស១២ កោះមេទ័ពស្មោះត្រង់ យៀកហ្វី មកវិញដើម្បីសម្លាប់។ នេះហៅថាការប្រើល្បិចរស់រវើក គឺមិនត្រូវអនុវត្តដោយឬកស្លូតនោះទេ ចង់និយាយថា អ្នកណាក៏ចេះលេងល្បែងសៀកដែរ តែបច្ចេកទេស និងការប៉ិនប្រសប់ គឺ ខុសនិយាយរួមគោលបំណងនៅត្រង់ចាប់ " មេ " ។

ដូច្នេះ ទោះបីជាត្រូវប្រើល្បិចកលហ៍ឆ្គិនភ្នែកបោកប្រាស់បែបណាក៏ដោយឲ្យតែអាចសំរេចតាមគោល បំណង គឺជាការស្រេច ។

# ចាប់ចោរត្រូវចាប់មេ

" ចាប់មេ " ចាត់ទុកថាជាចំណោទមួយ តើត្រូវទៅចាប់របៀបណា?
ពិតហើយ គឺត្រូវប្រើល្បិចគ្រប់បែបយ៉ាងទាំងអស់ (កំបាំងមេឃឆ្លងសមុទ្រ)
(បញ្ឆោតខ្លាចេញពីភ្នំ) ឬក៏ (ល្បិចស្រីស្រស់) ។ល។ និយាយរួម
គឺត្រូវតែប្រើល្បិចទៅតាមចរិតមនុស្ស ពិនិត្យ និងអនុវត្តតាម
សភាពការណ៍ជាក់ស្តែង។
ដើម្បីទប់ទល់ជាមួយ " មេ " ដែលជាអ្នកក្លាហាន
គ្រាប់មីននិងដុំអំបោះ មានប្រសិទ្ធភាពដូចគ្នា កេរ្តិ៍ឈ្មោះ
និងផលប្រយោជន៍សំខាន់ដូចគ្នា ពិសេសគឺ "ស្រីស្រស់"
គឺមានអានុភាពខ្លាំងជាងគ្រាប់បរិមាណូទៅទៀត
ប្រើល្បិចស្រីស្រស់ចាំបម្រើ " ប្រសើរជាងប្រើក្បួន "
ព័ទ្ធចាប់ដោយកម្លាំង " បានឃើញហើយថា មានបទពិសោធន៍ជាច្រើន
ក្នុងប្រវត្តិសាស្ត្រកន្លងមក ដែលបានកត់ត្រាថា៖ អ្នកក្លាហាន
តែងចូលចិត្តស្រីស្រស់ ឬអ្នកក្លាហានស្លាប់ក្រោមកន្ទុយក្បិន។
ឧទាហរណ៍ ដើម្បីចាប់ស្តេច អ៊ូហ្វាន់ឆុង បានប្រើសម្រស់នាង ស៊ីស៊ី
ទៅអូសទាញ ដើម្បីដណ្តើមរាបល្ល័ង្កពីស្តេច ឈុនស៊ីន
លីយាន បានបញ្ចុះបញ្ចូលប្អូនស្រីខ្លួនទៅធ្វើជាស្នំរបស់ស្តេច ឈុនស៊ីន
របៀបនេះគេហៅថា ចាប់ " មេ " ដោយប្រើយុទ្ធ វិធីទន់ភ្លន់
បំណងរបស់វានៅត្រង់ចាប់ " ខួរក្បាល " វិធីនេះប្រើក្នុងកិច្ចការ
នយោបាយមានច្រើនសន្ធឹកសន្ធាប់ ណាស់ នៅផ្នែកយោធា
ការប្រើវិធី(ចាប់មេ) នេះ រិតតែចាំបាច់ទៅទៀត។
នៅរជ្ជកាលម៉េង ពេលដែលស្តេចយីងជុង ទើបឡើង
សោយរាជ្យ ពួកជនជាតិហ៊្វ ក៏បានចាប់ផ្តើមឈ្លានពាន
នៅតាមព្រំដែនដែរ នៅក្រោមការចាប់បង្ខំរបស់មន្ត្រីក្បត់ វ៉ាងជិន
ស្តេចម៉េងត្រូវបង្ខំព្រះកាយចេញធ្វើសឹកដោយផ្ទាល់
តែត្រូវជនជាតិហ៊្វ ដែលដឹកនាំដោយមេទ័ពយាស៊ាន
ប្រើសង្គ្រាមបណ្តាក់ កំទេចអោយបរាជ័យយ៉ាងធ្ងន់ធ្ងរ
ចំពោះកងទ័ពម៉េង ចាប់ស្តេច យីងជុង គឺបាន " ចាប់មេ "
ជាស្រេច ជាបន្តរបន្ទាប់ជនជាតិហ៊្វបានធ្វើការគំរាម
កំហែងចំពោះរាជការម៉េង និងបានចាប់បង្ខំស្តេច យីងជុង
ធ្វើជាឧបករណ៍ទៅបង្ក្រាបគ្រប់ទិសទី ធ្វើឲ្យរាជការម៉េង
ឈឺក្បាលពេកក្រៃ ចាញ់ដីដោយសារចំណាប់ខ្មាំងនេះ
ចង់ចរចារដោយសន្តិវិធី គឺពិតជាគ្មាន សង្ឃឹមទាល់តែសោះ
ចង់ប្រយុទ្ធក៏រអារ ព្រោះ " មេ " នៅក្នុងដៃរបស់សត្រូវ
បែបនេះរហូតដល់ស្តេចថ្មីឡើងសោយ រាជ្យ
(ព្រះនាមជីងចុងជាអ្នកស្នងរាជ) ទើបធ្វើការវាយបកឲ្យ
ពួក ហ៊្វ បរាជ័យចាប់បង្ខំពួកនោះអោយដោះលែង
ស្តេច យីងជុង ដែលគ្មានន័យ តែនៅមានតំលៃខ្លះ
ឲ្យវិលត្រឡប់មកវិញ។

# ចាប់ចោរត្រូវចាប់មេ

ចម្លែក ពិតជាចម្លែកម្ចាស់ទន្លេម្ដេចក៏អាចយកប្រពន្ធកើត?
ពិតជាមានអាថ៌កំបាំងអីហើយ អ្នកទាំងអស់ គ្នានិយាយឲ្យ
បានក្បោះក្បាយបន្តិចមើល !
លោកម្ចាស់ ស៊ីម៉ុន បាននិយាយដោយភ្ញាក់ផ្អើល ។
មនុស្សម្នាក់ក្នុងចំណោមនោះនិយាយៈ
លោកម្ចាស់ទន្លេគឺជាអ្នកតាទន្លេ ល្បីនិយាយតៗគ្នាថា
អ្នកតានេះស្រឡាញ់ស្រីដែលស្អាតណាស់ ជារៀងរាល់ឆ្នាំ
ទាល់តែថ្វាយស្រីស្រស់ស្អាតមួយរូបជាដង្វាយ
ទើបអាចធានាទឹកភ្លៀងបានល្អប្រសើរ បើមិនដូច្នេះទេ
អ្នកតាទន្លេពិតជាខឹង និងបង្កើតជាទឹកជំនន់ ធ្វើឲ្យលិចលង់
ផលស្រូវ,តំណាំ,ផ្ទះសម្បែង,សត្វពាហៈនៈជាមិន ខាន។

លោកម្ចាស់ស៊ី សួរបន្តរៈ

តើជាស្នាដៃរបស់អ្នកណា?

គឺជាស្នាដៃរបស់ជនមួយក្រុមដែលមានអំណាច
ឃុបឃិតជាមួយពួកសន្តិសុខនិងពួកអភិជនមួយចំនួន
ឆ្លៀតពេលដែលប្រជារាស្ត្រកំពុងជួបការលំបាក
ដោយមូលហេតុនៅទីនេះ តែងកើតមានគ្រោះធម្មជាតិ
ជាញឹកញាប់ផងនោះ គួបផ្សំនិងការប្រើអំណាច
តើមានអ្នកណាទៅដែលហ៊ានមិនអនុវត្តតាម ?
ប្រាក់កាសដែលពួកវាកៀបសង្កត់ យកបានពីប្រជារាស្ត្រ
ប្រាប់ថាជាការបង់ពន្ធ ក្រៅពីយកតិចតួចទៅដាក់ក្នុង
ឃ្លាំងរាជការ សល់ប៉ុន្មាន ពួកវាយក មកចែកគ្នា ទុកក្នុង
ហោប៉ៅរៀងៗខ្លួន និងទុកខ្លះធ្វើជាការចំណាយដល់អ្នកតាទន្លេ
ដែលត្រូវការប្រពន្ធ។ បានន័យថាៈ គ្មានប្រជារាស្ត្រណា
ហ៊ានតវ៉ាទេគឺស្រេចតែពួកវាធ្វើអ្វីតាមតែអំពើចិត្តបែបនេះទៅ
ម៉ែនទេ?
អា! អ៊ំចាស់ម្នាក់ថ្លែរ សាកគិតមើលចុះ នៅក្រោមលេសច្បាប់
និងការកៀបសង្កត់នៃអំណាចបុគ្គល តើអ្នកណាទៅដែលហ៊ាន
ហារមាត់តវ៉ានោះ? ម្យ៉ាងទៀតពួកគេចេះនិយាយបានល្អណាស់
លើកហេតុផលបានល្អណាស់ ថាធ្វើនេះសុទ្ធតែ ដើម្បីប្រជារាស្ត្រ
ទាំងអស់ ។ល។ រៀងរាល់រដូវពេលចុះស្ទូង ពួកក្រុមនោះ តែងតែ
ចេញដើររកនារីរូបស្អាតគ្រប់ទីកន្លែង ឲ្យតែឃើញនារីណារាងស្អាត
ក៏តាំងថា ពិតជាសក្តិសមធ្វើជាប្រពន្ធរបស់អ្នកតាទន្លេ
ចំពោះឪពុកម្តាយណា ដែលមិនយល់ព្រមឲ្យកូនទៅ ក៏ប្រឹងរកលុយ
រកកាក់សូក អង្វរឲ្យទៅរកអ្នកផ្សេងវិញទៅ អ្នកដែលគ្មាន
លុយកាក់សូក មានបញ្ជូនកូនឲ្យទៅតាមដំណើរតែម្តងទៅ
(ដោយក្តីឈឺចាប់បំផុត) បានហើយ ពួកគេនឹងនាំក្មេងស្រីនោះទៅ
ស្នាក់នៅឯមាត់ទន្លេ ជម្រះកាយប្តូរសម្លៀកបំពាក់
ហើយជ្រើសរើសថ្ងៃល្អ តុបតែងនារីនោះឲ្យសមសួន

## ចាប់ចោរត្រូវចាប់មេ

រួចចង នៅលើក្បូនដែលធ្វើអំពីស្មៅ ហើយបណ្តែតតាមទឹក
អណ្តែតបានបន្តិច ក្បូនស្មៅនោះក៏លិចបាត់ទៅ
បានន័យថានារីនោះបានក្លាយទៅជាប្រពន្ធរបស់អ្នកតាទន្លេហើយ
មូលហេតុនេះហើយ បានជាអ្នកស្រុកដែលមានកូនក្រមុំ
បាននាំគ្នារើរត់ចេញពីទីនេះ ទៅរស់នៅកន្លែងដ៏ទៃ
ដូចនេះហើយ បានជាមនុស្សនៅទីនេះ កាន់តែតិចទៅៗ ។
លោកម្ចាស់ស៊ី ស្តាប់បណ្តើរជ្រួញចញ្ចើមបណ្តើរក៏សួរបន្តរ ៖
 សភាពការណ៍ទឹកជំនន់នៅទីនេះយ៉ាងម៉េចដែរ ?
 មិនជាអ្វីទេតាំងពីរៀបការប្រពន្ធ ថ្វាយអោយអ្នកតាទន្លេ
 ជារៀងរាល់ឆ្នាំមក ទីនេះមិនដែលកើតមានគ្រោះទឹកជំនន់ទេ
 តែបើតាមការពិតស្ថានភាពដីនៅទីនេះខ្ពស់ គ្មានប្រភពទឹក
 ហើយក៏គ្មានទឹកជំនន់ដែរ តែបើមាន គឺគ្រោះរាំងស្ងួតទៅវិញទេ។
ល្អណាស់ លោកម្ចាស់ស៊ីបញ្ចប់សំដីជាចុងក្រោយ។
បើបានជាអ្នកតាទន្លេស័ក្តិសិទ្ធិបែបនេះទៅហើយ មេត្តាកុំភ្លេចថា
នៅពេលដែលអ្នកតារៀការគូស្រករថ្មី សូមទៅប្រាប់ខ្ញុំឲ្យដឹងផង។
ពិធីរៀបគូរស្រករថ្មីឲ្យអ្នកតាទន្លេ ក៏មកដល់ថ្ងៃកំណត់
ពួកតាៗប៉ុន្មាននាក់ ក៏រត់ទៅប្រាប់លោកម្ចាស់ ស៊ី
ឲ្យចូលរួមតាមការផ្តាំផ្ញើរ។
ថ្ងៃនេះគឺជាថ្ងៃដ៏អធឹកអធម លោកម្ចាស់ស៊ីបានរៀបចំខ្លួន
យ៉ាងពិសេស ក្នុងសម្លៀកបំពាក់ជាមន្ត្រីរាជការទៅចូលរួម
ប្រជារាស្ត្រក្នុងស្រុកទាំងមូលក៏បានទៅចូលរួមយ៉ាងកុះករ
អ្នកស្រុកក្បែរគ្នាឮដំណឹង ក៏បាននាំគ្នាមក ចូលរួមយ៉ាង
ពពាក់ពពូនដែរ មនុស្សរាប់ពាន់អ្នកបានមកជុំគ្នាក្បែរមាត់ទន្លេ
ពិតជាអ៊ូអរមែន ។(ថៅមហា) ដែលជាអ្នកមានម្នាក់ បានគ្រាហ៍មេធ្មប់
ដែលជាម្ចាស់ពិធីចេញមក គឺជាយាយចំណាស់ម្នាក់ ដែលមាន
ទឹកមុខពោរពេញទៅដោយភាពអំនួត ខាងក្រោយគាត់
គឺជាសិស្សនារីមានគ្នាជាងម្ភៃនាក់ ក្នុងសំលៀកបំពាក់ដ៏ហ៊ឺហារ
ដៃកាន់កន្សែងនិងជើងពានសម្រាប់អុជធូប ហែរហមតាម
ពីខាងក្រោយ។
លោកម្ចាស់ស៊ីក៏ចាប់ផ្តើមសំនួរះ
 សុំនាំស្រីក្រមុំដែលបំរុងរៀបការឲ្យអ្នកតាទន្លេនេះ
 អោយយើងមើលមុខបន្តិចបានឬទេ ?
យាយធ្មប់មិនតបវិញទេ តែធ្វើជាសញ្ញាឲ្យកូនចៅនាំប្រពន្ធថ្មី
របស់អ្នកតាទន្លេ ឃើញថាក្នុងសម្លៀកបំពាក់ធម្មតា ហើយមិន
ឃើញជាស្អាតត្រង់ណាសោះ ថែមទាំងធ្វើទឹកមុខអោយជូរហ្វូញ
ក៏និយាយទៅកាន់កូនចៅ ដែលឈរអម សងខាងយាយធ្មុប:
 អ្នកតាទន្លេគឺជាអ្នកតាដ៏ស័ក្តសិទ្ធ ប្រពន្ធរបស់លោកត្រូវតែ
ជានារីដ៏ស្រស់ស្អាតទើបស័ក្តសម នារីនេះ មានរូបរាង
មិនស្អាតទាល់តែសោះ មិនសមធ្វើជាប្រពន្ធរបស់អ្នកតាទន្លេទេ

# ចាប់ចោរត្រូវចាប់មេ

ឥឡូវសូមលោកយាយធ្មប់ មេត្តាធ្វើដំណើរទៅប្រាប់ដំណឹងដល់អ្នកតាទន្លេផងថាៈ យើងនឹងរកនារីដ៏ស្រស់ស្អាតមកថ្វាយ តែសូមលើថ្ងៃថ្វាយទៅថ្ងៃក្រោយវិញ។
និយាយចប់ ក៏បញ្ជាអោយសេនាការពារឆ្វេងស្ដាំ ចាប់យាយធ្មប់ បោះផ្លូងទៅក្នុងទន្លេតែម្ដង អ្នកជុំ វិញភ្ញាក់ក្រញ៉ាងស្លេកមុខគ្រប់គ្នា ចំណែកលោកម្ចាស់ស៊ី អង្គុយធ្វើហីដូចគ្មានកើតរឿងអីសោះ មួយសន្ទុះក្រោយ និយាយៈ យាយចាស់ធ្វើការមិនស្វាហាប់ ទាល់តែសោះ គ្រាន់តែឲ្យទៅជូនដំណឹងប៉ុណ្ណឹងសោះ យូរណាស់ដែរហើយ នៅតែមិនឃើញត្រឡប់មកវិញទៀត គួតែបញ្ជូនកូនចៅដែលមាំទាំ ឲ្យទៅតាមមើលក្រែរហ័សទាន់ចិត្តជាង។
និយាយចប់ ក៏បញ្ជាអោយសេនាចាប់នារីដែលនាំមុខគេបោះផ្លូងទៅក្នុងទន្លេទៀត។ មិនយូរប៉ុន្មានក៏ និយាយទៀតៈ យ៉ាងម៉េចអីចេះ សូម្បីតែកូនចៅដែលឲ្យទៅតាមក្រោយ ក៏មិនឃើញត្រឡប់មកវិញដែរ ចំជាយ៉ាប់ មែន ឲ្យម្នាក់ទៅទៀតមើល! បន្តបន្ទាប់នារីបីនាក់ត្រូវបានទម្លាក់ទៅក្នុងទឹកទន្លេ តែពុំឃើញម្នាក់ណាត្រឡប់ មកវិញសោះ។
អូ ! ត្រូវហើយ លោកម្ចាស់ស៊ីធ្វើដូចជាទើបនឹកឃើញរឿងអីៈ

ពួកនាងៗគឺជាស្រីភេទ ពិតជាមិនចេះធ្វើការទេ អញ្ចឹងគួរតែឲ្យមនុស្សប្រុសទៅម្ដង។ ហើយក៏ចង្អុលសំដៅជនអ្នកមាន ដែលហែរហមតាមមេធ្មប់  ជននោះបំរុងនឹងនិយាយអង្វរទៅហើយ តែលោកម្ចាស់ស៊ីបែជាស្រែកគំហកយ៉ាងខ្លាំងដូចរន្ទះ ៖

ត្រូវគោរពតាមបញ្ជា ឆាប់ទៅឆាប់មកវិញ!

មិនឲ្យឆ្លើយវិញទាន់ទេ សេនាក៏ចាប់លើកជននោះ បោះផ្លូវទៅក្នុងទន្លេបែកទឹកខ្វាយពេលនោះ អ្នកមើល ម្នាក់ៗពិតជាភ្ញាក់ផ្អើលខ្លាំងណាស់ អ្នកនៅឈរជិតធ្វើភ្នែកស្លឹ  លានអណ្ដាតថ្លៃ ឯអ្នកមើលពីចំងាយខ្សឹបខ្សៀវដាក់គ្នាឲ្យរងំ។
លោកម្ចាស់ស៊ីទាញអាវតំរង់មួកបន្តិច ហើយក៏ធ្វើគារវកិច្ចយ៉ាងគោរពសំដៅទឹកទន្លេ រួចក៏នៅរងចាំដោយស្ងប់ស្ងៀម កន្លងបានមួយសន្ទុះ គាត់ហើបមាត់វាចារហាក់ដូចជារអ៊ូរទាំៈ

លោកអ្នកមាននេះពិតជាមិនបានការ រាល់ថ្ងៃដឹងតែពីរឿងគាបសង្កត់ឆក់ប្លន់កេងប្រវ័ញ្ចពីប្រជារាស្ដ្រ ឃុបឃិតជាមួយមន្ត្រីខិលខូច កិច្ចការតូចតាចប៉ុណ្ណឹងក៏ធ្វើមិនកើតដែរ ពិតជាចោរម្សៀតមែន។
ណ្ហើយ! ប្រហែលជាគាត់អាយុច្រើនធ្វើការមិនកើត ពួកក្មេងៗអស់ឯងទៅធ្វើការងារនេះឲ្យយើងម្ដងមើល។ ហើយចង្អុលសំដៅពួកកម្លោះៗក្រុមការពារ ។ គ្រាន់តែ ឃើញដៃចង្អុលសំដៅមក ពួកនោះភ័យប៉ះសក់ ព្រលឹងរត់ចេញពីខ្លួន ហើយស្វាយមុខ ស្លេកមាត់គ្រប់គ្នា ញើសហូរជោគខ្នង នាំគ្នាលុតជង្គង់ក្រឹប មុជងើបក្បាលបុកនិងដី សុំក្ដីអាសូរ ទឹកភ្នែកហូរជោគថ្ពាល់ ដូចជាត្រូវគេធ្វើបាបសម្បើមណាស់។
ណ្ហើយ! ចាំមួយសន្ទុះទៀតសិនក៏បាន! លោកម្ចាស់ស៊ី
និយាយម្នាក់ឯង។ មួយយាមបានកន្លងផុតទៅ លោក ម្ចាស់ស៊ី

## ចាប់ចោរត្រូវចាប់មេ

ដកដង្ហើមវែង ហើយបែរមុខសំដៅបងប្អូនទាំងអស់ ដែលមក
ចូលរួមក្នុងពិធី រួចនិយាយ៖

ទឹកទន្លេហូរខ្ជួខ្ជាញ់ ហូរទៅមិនត្រឡប់ តើមានអ្នកតាទន្លេ
មកពីណា? យើងព្រមានឲ្យហើយ បើសិនជា មានការស្លាប់កូន
ចៅប្រជារាស្ត្រ ដោយវិធីនេះទៀត ពួកឯងទាំងអស់គ្នាត្រូវតែទទួល
ខុសត្រូវទាំងស្រុង ។

អគុណលោម្ចាស់ ពួកខ្ញុំសុទ្ធតែត្រូវគេបោកប្រាស់ទេ សុទ្ធតែធ្វើតាម
បញ្ជារបស់យាយធ្មប់នោះទាំងអស់។ ពួកគេឆ្លើយព្រមគ្នា។

ចោរម្សៀត! លោម្ចាស់ស៊ីធ្វើទឹកមុខមាំហើយនិយាយស្តីប្រដៅ៖
មនុស្សណាដែលធ្វើការជាមួយមនុស្សអាក្រក់នោះ ?
ថ្ងៃនេះយើងលើកលែងទោសឲ្យពួកឯងម្តង
ទុកឱកាសឲ្យពួកឯងកែខ្លួនធ្វើជាមនុស្សល្អឡើងវិញ ។

អគុណលោម្ចាស់!

មេឃាតករប្រឌិតរឿងអ្នកតាទន្លេ បានស្លាប់បាត់ទៅហើយ
ដូច្នេះបើថ្ងៃក្រោយ អ្នកណារំលឹកពីរឿងអ្នកតាទន្លេចង់បាន
ប្រពន្ធទៀត អ្នកនោះត្រូវទៅជូនដំណឹងឲ្យអ្នកតាទន្លេមុនគេ។
បន្ទាប់មក លោមេស្រុកក៏បញ្ជាអោយរឹបអូសទ្រព្យសម្បត្តិ
ដែលមកពីការកែងប្រវ័ញ្ចឆក់ប្លន់ពីប្រជារាស្ត្រ សងទៅ
ឲ្យម្ចាស់គេវិញ ចំណែកសិស្សនារីទាំងនោះក៏ផ្សំផ្គុំឲ្យ
ពួកកម្លោះចាស់ទាំងនោះទៅ រឿងអាស្រូវបែបនេះ
ក៏ត្រូវបានបញ្ចប់។ អ្នកស្រុកអ្នកភូមិដែលរត់គេច ក៏បានវិល
ត្រឡប់មកកាន់ស្រុកកំណើតវិញជាបន្តបន្ទាប់ រស់នៅយ៉ាង
សុខសាន្តតរៀងទៅ។ លោកម្ចាស់ស៊ី ក៏បានសិក្សាស្រាវជ្រាវ
ភូមិសាស្ត្រដីនៅទីនោះ លើកទឹកចិត្តដល់បងប្អូន ឲ្យជីកប្រឡាយ
កាយប្រឡង់ សង់ទំនប់ ធ្វើទ្វារទឹកចំនួន១២ខ្សែ ចូលស្រោច
ស្រពវាលស្រែ ដោះស្រាយបាននូវគ្រោះរាំង ស្ងួត។
ចាប់តាំងពីពេលនោះមកប្រជារាស្ត្រនៅទីនោះ
ក៏បានរស់នៅក្នុងភាពសុខសាន្តរៀងរហូតមក ៕

ដល់ត្រើយសើយតួច

# កំបាំងមេឃឆ្លងសមុទ្រ

(កំបាំងមេឃឆ្លងសមុទ្រ) និង(ញ៉ុកត្រចៀកពេលលួចកណ្ដឹង) មិនដូចគ្នាទេ ញ៉ុកត្រចៀកពេលលួចកណ្ដឹង គឺមានបំណងបោកប្រាស់អ្នកដទៃ ពេលដែលអនុវត្តទៅមិនបានសម្រេច បែរជានាំគ្រោះថ្នាក់ដល់ខ្លួនឯងវិញ ចំណែក(កំបាំងមេឃឆ្លងសមុទ្រ) គឺជាល្បិចដែលមានការរៀបចំគម្រោងការល្អិតល្អន់ គឺទិសដៅច្បាស់លាស់ ដើម្បីទៅប្រលែងលេងនឹងអ្នកដទៃ។ (កំបាំងមេឃឆ្លងសមុទ្រ) តាមសុភាសិតនិយាយថា៖ ឆ្លងផុតសមុទ្រ នឹងក្លាយជាទេវតា គឺមានន័យបែបនេះឯង ។ មនុស្សម្នាក់ ដែលត្រូវទទួលការគៀបសង្កត់ ឬក៏បិតក្នុងបរិយាកាសមិនអំណោយផលមានបំណងដណ្ដើមយកភាពម្ចាស់ការ ផ្លាស់ប្ដូរពីគ្រោះកាចមកសុខសាន្តវិញនោះ គឺងាយនឹងកើតមានគំនិតបែប (កំបាំង មេឃឆ្លងសមុទ្រ) នេះណាស់ ពីព្រោះល្បិចកលនេះ គឺប្រើប្រាស់នៅពេលសត្រូវភ្លេចខ្លួនធ្វេសប្រហែសតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ហើយវាមិនប្រាកដជាមានការគំរាមគំហែង ឬផ្ដល់គ្រោះដោយផ្ទាល់ដល់គូរសត្រូវនោះទេ ល្បិចនេះងាយស្រួលក្នុងការអនុវត្ត ហើយក៏ងាយស្រួលក្នុងការទទួលផលដែរ ។ ពិតមែនតែលទ្ធផលរបស់ល្បិច(កំបាំងមេឃឆ្លងសមុទ្រ) និង(ញ៉ុកត្រចៀកពេលលួចកណ្ដឹង) មិនដូចគ្នា តែផ្ដើមចេញពីការបោកប្រាស់ដូចគ្នា(កំបាំង) បានសម្រេចបានន័យថា៖ ឆ្លងផុតសមុទ្រនឹងក្លាយជាទេវតា។(កំបាំង) មិនបានសម្រេច នឹងក្លាយជា (អណ្ដើកក្នុងស្នូក) ។

បើនិយាយពីឈឺនខ្ញៃ វិញដើម្បីអនុវត្តនយោបាយឲ្យស្ដេច សុង ការជូ សារភាពក៏បានប្រើផ្លាកបញ្ជាមាស លួចកោះហៅឲ្យមេទ័ពយៀកហ្វី ត្រឡប់មកវិញដោយស្ងាត់ ដោយមានបំណងសម្លាប់មេទ័ពដ៏អង់អាចនេះចោល នេះគឺជាស្នាដៃ(កំបាំងមេឃឆ្លងសមុទ្រ) តែដោយធ្វើទៅលាក់ការមិនជិត ធ្វើឲ្យក្ដៅក្រហាយដល់ប្រជារាស្ត្រ ជាពិសេសនៅពេលដែល ហាងស៊ឺជុង សួរថា៖ តើយៀកហ្វី ប្រព្រឹត្តខុសរឿងស្អី?

ឈិនខៃបែជាឆ្លើយថា៖ រឿងនេះ ប្រហែលជា......។

ពេលនោះ ហាង ស៊ឺជុង វែកមុខអាក្រក់របស់ ឈិនខៃ ភ្លាម ដោយស្រែកថា៖ ប្រហែលជាអាចធ្វើឲ្យ សត្រូវខ្លបខ្លាច? ព្រោះតែមួយឃ្លានេះ ឈិនខៃ(កំបាំងមេឃ) មិនបានពាក្យបីមាត់(ប្រហែលជា) ក្លាយជាភស្តុតាង (ញ៉ុកត្រចៀកពេលលួចកណ្ដឹងទៅវិញ) ទោះបីជាទីបំផុត ឈិនខៃ បារិៈរកមធ្យោបាយ សម្រេចគោលបំណងរបស់ខ្លួនបានក៏ដោយ តែក៏ត្រូវមនុស្សជំនាន់នោះ ជេរថា ចោរក្បត់ជាតិ(កំបាំងមេឃ) ក៏មិនបានសម្រេច(សមុទ្រ) ក៏ឆ្លងមិនដល់ត្រើយ ។

អាស្រ័យហេតុនេះ នៅពេលដែលអនុវត្តល្បិចកលនេះ ត្រូវពិនិត្យឲ្យបានច្បាស់លាស់ ពិចារណាឲ្យបានជិតដល់ ធ្វើឲ្យបានរហ័ស អនុវត្តឲ្យបានដោយលាក់ការណ៍បំផុត បើមិនដូច្នេះទេពិតជាស្រោចគល់ហើយ ។

(ប្រវត្តិពិត) ក្នុងសម័យឈុនឈីវ ព្រះរាជបុត្រចុងអឺ នៃនគរជីន ក្រោយពីត្រូវព្រះមាតាចុងនិរទេសព្រះកាយ ចេញពីព្រះនគរមក ក៏ត្រាច់ចរនៅខាងក្រៅ ហើយក៏បានរៀបអភិសេកជាមួយព្រះនាងឈីជៀង រាជបុត្រី នៃនគរឈី រស់នៅក្នុងជីវភាពសំបូរ និងសុខសាន្ត។ អ្នកដែលរត់ភៀសខ្លួនហែរហមតាមព្រះអង្គ មានមន្ត្រីធំៗ ចំនួន៩រូប ម្នាក់ៗមានទេព្យកោសលរៀងៗខ្លួន ជានិច្ចជាកាល មិនភ្លេចពីបំណងរំដោះព្រះនគរវិញឡើយ ពួកគេគ្រប់គ្នាសុខចិត្ត លះបង់ប្រពន្ធកូន ស្រុកកំណើត ហែរហមមុខក្រោយ គឺពិតជាផ្ញើក្ដីសង្ឃឹមលើព្រះអង្គចុងអឺ នេះឯង ។

## ដល់ត្រើយសើយតូច

ក៏ប៉ុន្តែ ៧ឆ្នាំបានកន្លងផុតទៅហើយ ព្រះរាជបុត្រ ចុងអី ដែលបានរស់នៅក្នុងបឹងសុបិន យ៉ាងសុខស្រួល ទាំងយប់ទាំងថ្ងៃទៅហើយនោះ ពុំបាននឹកគិតដល់រឿងរំដោះព្រះនគរនោះទេ សូម្បីតែបន្តិច.......។

ក្នុងចំណោមនោះ មន្ត្រីធំម្នាក់ឈ្មោះចាវសាន់ បាននិយាយទៅកាន់ទៅមន្ត្រីធំទាំង៨ថា ៖

ពួកយើង ដែលស៊ូទ្រាំរត់គៀសខ្លួនមកតាមព្រះអង្គ គោលបំណងសំខាន់ គឺចង់ពឹងពាក់នគរក្រៅ ដើម្បីជួយរំដោះនគរយើង ក៏ប៉ុន្តែមើលស្ថានភាពនគរឈើនសព្វថ្ងៃនេះ ច្របូកច្របល់ខ្លាំងណាស់ ដោះស្រាយតែបញ្ហាខ្លួនឯងមិនចេញផង មានកំម្លាំងឯណា មកជួយពួកយើង? យកល្អគួរតែនាំគ្នាស្រួតចាកចេញពីទីនេះ ទៅនគរផ្សេងទៀត ដើម្បីរិះរកមធ្យោបាយជាថ្មី។ សម្រេចបែបនេះហើយ ពួកគេនាំគ្នាសុំចូលគាល់ព្រះអង្គ ដើម្បីសុំព្រះរាជយោបល់ តែរងចាំរយៈពេល១០ថ្ងៃ ហើយនៅមិនបានជួបទៀត។

យួនសឺន(មន្ត្រីម្នាក់ក្នុងចំណោម៩នាក់) ពិតជាទ្រាំលែងបានហើយ ក៏ពោលពាក្យទាំងមួហ្មង៖

តើបែបនេះ បានន័យថាម៉េច? ដើមឡើយយល់ថា ព្រះអង្គ គឺជាមនុស្សដែលអស្ចារ្យ ទើបលះបង់ប្រពន្ធកូន ស្រុកកំណើត មិនស្តាយស្រណោះ មិនគិតពីការនឿយហត់សព្វបែបយ៉ាង រត់លូនតាមព្រះអង្គ ដឹងអីឥឡូវនេះ ព្រះអង្គនៅកំដរមហេសីថ្មីគ្មានឃ្លាតមួយជំហាន ភ្លេចទាំងពួកយើងលែងខ្វីនឹកនាពីរឿងព្រះនគរ ៧ឆ្នាំបានកន្លងទៅហើយ គ្មានឃើញព្រះអង្គមានសកម្មភាពអ្វីបន្តិចទាល់តែសោះ ពេលនេះគ្រាន់តែសុំគាល់ព្រះអង្គ រង់ចាំ១០ ថ្ងៃទៅហើយ មិនទាំងឃើញស្រមោលផង តើបែបនេះអាចសម្រេចកិច្ចការធំដែរឬទេ ?

ឃើញ យួនសឺន និយាយបែបក្តៅក្រហាយ ហ៊ូក្វួយ ប្រញ៉ាប់ឃាត់៖

ទីនេះមិនមែនជាកន្លែងគួរនិយាយគ្នាទេ សូមអ្នកទាំងអស់គ្នាមកតាមខ្ញុំ។

និយាយចប់ពួកគេក៏នាំគ្នា ចេញតាមច្រកទ្វាខាងកើត ទៅដល់កន្លែងមួយហៅថា ចំការមន ដែលជាព្រៃមនដុះស៊ុបទ្រុបក្រាស់ខ្មីប ស្ទើរតែមើលមិនឃើញពន្លឺថ្ងៃ ពួកគេនាំគ្នាអង្គុយដំកង់ ចាវសាន ក៏ចាប់ផ្តើម និយាយ៖តើរឿងនេះ លោកម្ចាស់ហ៊ូ មានយោបល់យ៉ាងណាដែរ ?

ហ៊ូក្វួយ តប៖

បញ្ហាព្រះរាជបុត្រ យាងឬមិនព្រមយាងចាកចេញពីនគរឈើ វាជារឿងផ្ទាល់ខ្លួនរបស់ព្រះអង្គឯងប៉ុណ្ណោះ តែសំខាន់ទៅឬមិនទៅ វាជារឿងរបស់ពួកយើង ឲ្យតែពួកយើងសម្រេចគ្នាថាទៅ រៀបចំផែនការឲ្យបានសមស្រប ប្រុងប្រៀបខ្លួនគ្រប់ពេលឲ្យបានល្អ រង់ចាំតែព្រះអង្គយាងចេញមក គឺអញ្ជើញព្រះអង្គយាងទៅបរបាញ់តែម្តង ឲ្យតែផុតពីឃ្លោងទ្វាររាជធានី គឺចាប់បង្ខំឲ្យព្រះអង្គឲ្យរួមដំណើរជាការស្រេច  ដល់ពេលនោះ ទោះបីព្រះអង្គមិនចង់យាងទៅក៏មិនកើតដែរ អស់លោកថាទៅមើល តើមធ្យោបាយបែបនេះ អាចទៅរួចទេ អង្គប្រជុំទាំងមូល បានយល់ព្រមតាមគម្រោងការនោះ ហើយក៏នាំគ្នាចាកចេញដោយក្តីរីករាយ ដោយនឹកស្មានថាទីដ៏ស្ងាត់កំបាំងនេះពិតជាគ្មានអ្នកណាដឹងឡើយ។

ក៏ប៉ុន្តែ ជាសំណាងអាក្រក់ ពួកគេមិនដឹងថា នៅពេលដែលពួកគេកំពុងពិភាក្សាគ្នាយ៉ាងផុលផុសនោះ រាល់កិច្ចការពិភាក្សាទាំងអស់ ត្រូវនារីបេះមនជាង១០នាក់ ស្តាប់ឬគ្មានចន្លោះ ពួកនាងៗទាំងនោះ គឺជាស្ទំបំរើរបស់ព្រះនាងឈីជាង ថ្ងៃនេះពេលកំពុងតែបេះមន ស្រាប់តែឃើញមនុស្សមួយក្រុមដើរ ចូលមកអង្គុយដំកង់ពិភាក្សាគ្នា

## ដល់ត្រើយសើយតូច

ពួកនាងៗ ក៏ឈប់បេះមនហើយសម្ងំលួចចាំស្តាប់តែម្តង ពេលត្រឡប់ទៅវិញ ក៏បានយករឿងដែលស្តាប់ឮទាំងប៉ុន្មាន ទូលព្រះនាងឈីជាង គ្មានចន្លោះ។ ក្រោយព្រះសណ្តាប់ចប់ ព្រះនាងក៏មានបន្ទូលព្រមានពួកនាងៗទាំងនោះ

កុំនិយាយផ្តេសផ្តាសឲ្យសោះ ពិតជាគ្មានរឿងបែបនេះទេ ហើយក៏គ្មានរឿងបែបនេះកើតឡើងដែរ។

មានព្រះរាជបន្ទូលចប់ ក៏បញ្ជាឲ្យសេនាចាប់ពួកនាងៗទាំងអស់ យកទៅឃុំខ្លួននៅក្នុងបន្ទប់សម្ងាត់មួយ ពេលពាក់កណ្តាលអធ្រាត ក៏ចាត់កម្លាំងទៅសម្លាប់ពួកនាងៗទាំងអស់ចោលដើម្បីបំបិទមាត់ ។

បន្ទាប់មក ព្រះនាងក៏បានយករឿងនេះទៅទូលព្រះរាជបុត្រចុងអឺះ

ក្រាបទូលព្រះអង្គ ថ្ងៃនេះមន្ត្រីដែលហែរហមតាមព្រះអង្គទាំង៩រូប បាននាំគ្នាទៅប្រជុំពិភាក្សាគ្នាជាសម្ងាត់នៅឯចំការមន ដោយមានបំណងយាងព្រះអង្គឲ្យចាកចេញពីទីនេះទៅនគរវដទៃ ប៉ុន្តែការពិភាក្សាទាំងនេះ បានត្រូវស្រីបំរើទៅបេះមនស្តាប់ឮទាំងអស់ ទូលបង្គំខ្លាចពួកនាងៗទាំងនោះមាត់មិនជិតនិយាយលិចឮ ទៅខាងក្រៅនាំសៅហ្មង ទូលបង្គំក៏បានឲ្យ សេនាសម្លាប់ពួកនាងៗទាំងនោះចោលអស់ហើយ យកល្អព្រះអង្គគួរតែរៀបចំខ្លួនចេញដំណើរទៅជាមួយពួកគេទៅ........។

ព្រះរាជបុត្រព្រះសណ្តាប់ហើយ ក៏ជ្រួញចិញ្ចើមបន្តិច ដកដង្ហើមឮសូរឃ្លូហើយមានបន្ទូលៈ

ហ៊ឺ! ជីវិតមនុស្ស គ្មានទាមទារអ្វីក្រៅពីចង់បានរស់នៅដោយក្តីសុខស្រួល សុខសាន្តនោះទេ ចាំបាច់អី តិចចង់រត់ទៅលិច គេចទៅកើតនោះ? រឿងដែលបានកន្លងហួស ឲ្យវាហួសទៅចុះ ចាំបាច់រំលឹកវាឡើងវិញ? ពេលនេះការរស់នៅដូចសព្វថ្ងៃនេះ យើងពេញចិត្តណាស់ទៅហើយ យើងគិតថាយើង នឹងរស់នៅទីនេះជារៀងរហូត មិនទៅណាទៀតទេ.......។

ស្តាប់ហើយ ព្រះនាងមានបន្ទូលវិញដោយហ្មឹងមាត់ៈ

ព្រះអង្គ ការពិតប្រជារាស្ត្រជឹង កំពុងរង់ចាំព្រះអង្គទៅដឹកនាំ ឬមួយក៏សូម្បីតែរាជបល្ល័ង្ក ក៏ព្រះអង្គ មិនចង់បានដែរ? ចុះគំនំឈាមរបស់សាច់សារលោហិត ឬមួយព្រះអង្គមិនចង់សងសឹក? ទុក្ខវេទនារបស់ប្រជារាស្ត្រ ឬមួយព្រះអង្គក៏មិនឈឺឆ្អាល? ផលប្រយោជន៍របស់នគរក៏...........។

បានហើយ! បានហើយ! ឈប់និយាយតទៅទៀតទៅ ។

ព្រះរាជបុត្រខ្វាល់តូងមានបន្ទូលបន្តរះ

យើងមិនចូលចិត្តពាក្យសម្តីទាំងអស់នេះទេ យើងមិនចូលចិត្តជីវិតរស់នៅដែលត្រាច់ចបែបនេះទេ ទីនេះជាផ្ទះរបស់យើង ទោះចង់និយាយយ៉ាងណាក៏យើងមិនទៅណាដែរ ។

ព្រឹកព្រលឹមនេះ មន្ត្រីទាំង៩បានសុំចូលគាល់ព្រះអង្គ ដើម្បីយាងព្រះអង្គចេញទៅបរបាញ់តាមគម្រោង ពេលនេះ ព្រះរាជបុត្រមិនទាន់ងើបពីផ្ទុំផង កំពុងតែនៅននៀលលើព្រះស្មែងយ៉ាងខ្ជិលច្រអូស ឮថាពួកគេទាំងនោះមកហើយ សែនធុញទ្រាន់ក្នុងព្រះទ័យ ក៏បញ្ជាឲ្យសេនាទៅប្រាប់ថា ថ្ងៃនេះមិនស្រួលព្រះកាយ មិនបានឲ្យចូលគាល់ទេ ។

ឃើញសកម្មភាពដូច្នេះ ព្រះនាងឈីជាង លួចដេរក្នុងពោះ(កំជិលផេះ) ហើយក៏បានឲ្យអ្នកជំនិត ទៅហៅហ៊្វូគួយម្នាក់គត់ ឲ្យមកគាល់ដោយស្ងាត់

## ដល់ត្រើយសើយតូច

កំបាំងនៅក្នុងបន្ទប់សម្ងាត់ ក្រោយដេញពួកសេនាឆ្វេងស្តាំចេញអស់
ទើបព្រះនាងសាកសួរពីបំណងដែលមន្ត្រីទាំងអស់មកសុំគាល់ព្រះអង្គ ។
ហ៊្វឺគួយ ក៏ទូលថា៖ ក្រាបទូលព្រះនាង ធម្មតាកាលណាបើគ្មានកិច្ចការ
ព្រះអង្គតែងតែសព្វព្រះទ័យយាងចេញទៅបរបាញ់ កន្លងទៅនេះ ព្រះអង្គដូច
ជាកម្របានចេញទៅណាស់ ខ្លាចក្រែងនាំឲ្យអវៈយវៈទាំងបួនចុះខ្សោយ
ប៉ះពាល់ដល់វិជ្ជាគុណថែមទៀត ទើបបានជាពួកទូលបង្គំមកយាងព្រះអង្គ
ចេញទៅបរបាញ់ ក្រៅពីនេះ គ្មានបំណងអ្វីផ្សេងទៀតទេ ក្រាបទូល ។
 ព្រះនាងឈីជាងញញឹមបន្តិច ហើយមានចេតនាធ្វើឲ្យសំនួរចាកប្រធានៈ
 គោលដៅបរបាញ់លើកនេះ បម្រុងទៅដល់ទីណា? នគរសុង? នគរឈីន?
ឮមួយក៏នគរឈ្វ? ភ្ញាក់ដូចត្រូវគេធាក់មួយជើង ហ្វ៊ឺគួយ គិតក្នុងចិត្ត(ហេតុអ្វីបាន
ជាព្រះនាងដឹង) ក៏ប៉ុន្តែ នៅធ្វើឫកជាហ្នឹងធឹងឆ្លើយថា៖
បរបាញ់សត្វមិនទៅឆ្ងាយដល់ម្លឹងពេកទេ ក្រាបទូល ។
 ណ្ហើយ! ខ្ញុំជាអ្នកនិយាយទៅចុះ។ ព្រះនាងមានព្រះសុវណ្ណនីដោយហ្នឹងម៉ាត់៖
 ខ្ញុំដឹងថា អ្នកទាំងអស់គ្នា យកលេសយាងព្រះអង្គទៅបរបាញ់សត្វ
ហើយក៏ឆ្លៀតឱកាសចាប់បង្ខំព្រះអង្គឲ្យយាងទៅតែម្តង មែនឬមិនមែន?
ឮសំដីប្រាកដបែបនេះ ហ្វ៊ឺគួយ ភ័យស្លន់ស្លោមិនដឹងដោះស្រាយបែបណា
 រឿងនេះ............។
 រំពេចនោះ ស្រាប់តែព្រះនាងឈីជាង ងើបព្រះកាយឈរដោយក្តីក្លាហាន
ហើយមានព្រះសុវណ្ណនីថា៖ មិនបាច់រឿងនេះ រឿងនោះទេ បញ្ហានេះខ្ញុំយល់
ច្បាស់ណាស់ សូមលោកម្ចាស់ហ្វ៊ឺ ទុកចិត្តចុះ កុំភ័យខ្លាចឲ្យសោះ ខ្ញុំពិតជាយល់
ពីសន្តានចិត្តស្មោះត្រង់របស់អ្នកគ្រប់គ្នាចំពោះព្រះអង្គ អ្វីដែលអ្នកទាំងអស់គ្នា
បម្រុងនឹងធ្វើនេះ ក៏ដើម្បីអនាគតរបស់ព្រះអង្គ ហើយក៏ដើម្បីប្រជានុរាស្ត្រនៃ
នគរជីងទាំងមូលផងដែរ។ ម្សិលមិញ ខ្ញុំបានក្រើនរំលឹកដល់ព្រះអង្គច្រើនលើក
ច្រើនសារហើយដែរ តែព្រះអង្គដូចជាមិនភ្ញាក់រលឹកទាល់តែសោះ មួយម៉ាត់ណា
ក៏មានបន្ទូលថា៖ មិនព្រមចាកចេញពីទីនេះជាដាច់ខាត។ ឮព្រះនាងមានបន្ទូល
បែបនេះ ហ្វ៊ឺគួយ ទើបធូរទ្រូង ហើយវាចា ៖
 ឧត្តមគិតរបស់ព្រះនាង គួរឲ្យគោរពកោតសរសើរណាស់.......។
 ព្រះនាង ឈីជាង បន្តរ ៖
 ខ្ញុំដឹងថា ទោះបីយ៉ាងណា មុននិងក្រោយ ក៏គង់តែអស់លោត្រូវតែនាំ
ព្រះអង្គយាងចេញពីទីនេះដែរ ចេះទៅចុះ យប់នេះ ខ្ញុំរកមធ្យោបាយបង្អក
ស្រាព្រះអង្គឲ្យស្រវឹង រួចពួកអស់លោកនាំគ្នាចាត់ការយាងព្រះអង្គចេញទៅ
ទាំងយប់តែម្តងទៅ តើយ៉ាងម៉េចដែរ ល្អឬទេ ?
 ធ្វើបែបនេះ ល្អគឺវាល្អហើយ ក៏ប៉ុន្តែព្រះនាង.....។ ហ្វ៊ឺគួយ អលឯក
ព្រះនាងមានព្រះសុវណ្ណនីកាត់៖
 កុំបាច់ជួយបារម្ភពីរឿងខ្ញុំអី ដើម្បីព្រះអង្គ អស់លោកគ្រប់គ្នាហ៊ានលះបង់
ប្រពន្ធកូនស្រុកកំណើត តើខ្ញុំ មិនអាចលះបង់អ្វីខ្លះដើម្បីស្វាមីទេឬ? ព្រះអង្គ
គឺម្ចាស់នៃនគរជីង ជារបស់រួមនៃប្រជានុរាស្ត្រជីង តើហេតុអ្វី ខ្ញុំត្រូវយកធ្វើជា
កម្មសិទ្ធិដាច់មុខ? បើដូច្នេះមែន ប្រាកដជាធ្វើឲ្យមនុស្សជាច្រើនអស់សង្ឃឹមហើយ ។
 ព្រះនាង....? ហ្វ៊ឺគួយ ពិតជារំភើបគ្មានវាចារនឹងថ្លែង ។

ដល់ត្រើយសើយតូច

ព្រះនាងមានព្រះសុវណ្ណនីបន្តរះ
បានហើយ ពួកអស់លោកទៅប្រុងប្រៀបរៀបចំឲ្យហើយទៅ កុំនៅស្ងួញសាញ មើលតែមនុស្សស្រី។
ហ៊្វិគួយ ក៏ក្រាបបង្គំលា ហើយក៏ប្រាប់គ្រប់គ្នាឲ្យបានដឹង ចែកផ្លូវគ្នាធ្វើកិច្ចការ ដែលត្រូវធ្វើរៀងៗខ្លួន ចាវសាន និង អ្នកដទៃ ក៏បានចាកចេញពីរាជធានីដោយ ស្ងាត់កំបាំងទៅរងចាំនៅខាងក្រៅ ហ៊្វិគួយ និងឃួនស៊ី បានយកកូនរទេះទៅលាក់ ទុកឯមុខតំណាក់ រង់ចាំដំណឹងពីព្រះនាងឈីជាង......។
យប់នេះ ព្រះនាង បានរៀបចំពិធីជប់លៀងមួយយ៉ាងពិសេសថ្វាយស្វាមី ឃើញ ហាក់ដូចជាចម្លែកព្រះអង្គក៏សួរះ
ម្ចាស់អូនធ្វើបែបនេះ មានន័យថាម៉េច?
ព្រះនាងឈីជាងក៏មានព្រះសុវណ្ណនីប្រាប់ថា៖
ទូលបង្គំដឹងថា ព្រះអង្គត្រូវមានដំណើរយាងចេញទៅទីឆ្ងាយ ទើបរៀបចំពិធីនេះ ថ្វាយព្រះអង្គ ដើម្បីជាការជូនដំណើរ។ ឮព្រះនាងមានព្រះសុវណ្ណនីបែបនេះ ព្រះអង្គចុងអី ទៅជាស្រឡាំងកាំងហើយមានបន្ទូលះ
បងធ្លាប់ប្រាប់អូនពីកាលណា? ហ៊ឺ! ជីវិតមនុស្សមានតែប៉ុន្មានសិបឆ្នាំប៉ុណ្ណោះ បើអាចរស់បានហើយចាំបាច់អីតិចចង់ទៅនេះ តិចចង់ទៅនោះធ្វើអ្វី?
ក៏ប៉ុន្តែ មន្ត្រីដែលហែរហមតាមព្រះអង្គ ដាច់ខាតត្រូវតែទៅ តើព្រះអង្គមិនព្រម យាងទៅតាមពួកគេទេ ឬ? ព្រះនាងឈីជាងចុងសួរបន្ថែម។ ស្រាប់តែព្រះរាជបុត្រ ប្តូរទឹកមុខ ផ្អាកសោយសុរា ព្រះភ័ក្ត្រហាក់ដក់ជាប់កំហឹងតិចៗ ងើយសំឡឹងមើល មេឃឡើងភ្លឹកមិនចេញវាចារ។ មួយសន្ទុះ ព្រះនាងសើចញឹមៗ ហើយសួរះ
ព្រះអង្គ ពិតជាមិនដាច់ចិត្តទៅចោលទូលបង្គំមែនឬ? មិនកុហកទូលបង្គំទេមែនទេ?
អ្នកណាកុហកព្រះមហេសី កូនប្រុសដើមទ្រូងប្រាំហត្ថ ថាមិនទៅ គឺមិនទៅហើយ ចង់យកកាំបិតមកផ្ទង់ជាប់បំពងករ ក៏មិនទៅដែរ។ ព្រះរាជបុត្រមានបន្ទូលបណ្តើរ វាសដៃវាសជើងបណ្តើរ ហាក់ចង់បង្ហាញឲ្យ ឃើញនូវតួរអង្គជាប្រុសដើមទ្រូងប្រាំហត្ថ ម៉ាត់ណាគឺម៉ាត់ហ្នឹង ។
អីយ៉ា! ប្តីសម្លាញ់ខ្ញុំមែនទែនហើយតើណ៎! ។ មានព្រះសុវណ្ណនីបណ្តើរ សើចបណ្តើរ ហើយក៏ផ្ទួលខ្លួនទៅក្នុងទ្រូងរបស់ព្រះអង្គ បញ្ចេញឫកពារម្ងិកម្ងក់ ។
តាមពិត អូនមានបំងសាកល្បងចិត្តបងតែប៉ុណ្ណោះ អ្នកណាទៅដែលដាច់ចិត្តឲ្យប្តីបែក ពីខ្លួននោះ ? ហើយពួកគាកញ្ញាស់អស់នោះក៏ចឹងដែរ ចេះមានគំនិតចង់បំបែកបំបាក់ប្តី ប្រពន្ធគេទៅកើត ប្រាប់ព្រះអង្គទៅចុះ ស្រាមួយគុនេះ បើព្រះអង្គដាច់ខាតត្រូវយាងទៅ ទូលបង្គំប្រាកដជាឃាត់ព្រះអង្គមិនជាប់ឡើយ ហើយស្រានេះ ចាត់ទុកជាកាជូនដំណើរ ផ្ទុយទៅវិញបើព្រះអង្គមិនយាងទៅទេ ស្រានេះចាត់ទុកថា៖ គឺជាការអបអរចំពោះ ស្នេហាយើងទាំងពីរ ដែលគ្មានថ្ងៃណានឹងបែកគ្នា អ៊ឺ យល់ឬនៅ ពិតជាល្ងង់មែន!
មានព្រះសុវណ្ណនីបណ្តើរ ព្រះនាងអង្អែលថ្ពាល់ព្រះអង្គថ្នមៗបណ្តើរ ពិតជារំភើបមែន ធ្វើឲ្យអារម្មណ៍ព្រះអង្គ អណ្តែតអណ្តូងស្រវាំងអស់ព្រះនេត្រ នេត្រាទាំងបួនក៏ទង្គិចគ្នា ហើយក៏សើចក្អាកក្អាយព្រមគ្នាតែម្តង ភាពល្អកល្មើនបែបនេះ ពិតជាគួរឲ្យច្រណែនមែន។ មួយកែវហើយមួយកែវទៀត ព្រះនាងឈីជាងនៅចាំចាក់ស្រាថ្វាយព្រះអង្គមិនឈប់ ទីបំផុត ព្រះអង្គក៏ស្រវឹងដួលលែងដឹងខ្លួនតែម្តង។ ភ្លាមនោះ ព្រះនាងឈីជាង ក៏យកភួយ ដណ្តប់ឲ្យព្រះអង្គយ៉ាងរួសរាន់ ហើយឲ្យដំណឹងទៅ ហ៊្វិគួយ ដែលនៅរង់ចាំ

ដល់គ្រើយសើយតូច

នៅខាងក្រៅជាបន្ទាន់ រំពេចនោះហ្វៀគួយ និងឃួនស៊ីន ក៏ប្រញ៉ាប់ប្រញ៉ាល់ចូលមកក្នុងព្រះតំណាក់ ចាប់លើកបីព្រះអង្គទាំងភ្ញួយយកចេញទៅដាក់ក្នុងរទេះយ៉ាងត្រឹមត្រូវរួចក៏លើរំពាក់វៃសេះ" ផាច់" កង់រទេះក៏ចាប់ផ្ដើមវិលទៅមុខៗ ព្រះនាងឈរទ្រើងនៅមុខព្រះតំណាក់ លើកដៃក្រវីមួយៗជាសញ្ញានៃការលាគ្នា រំពេចនោះ បេះដូងរបស់ព្រះនាងហាក់ទទួលអារម្មណ៍ឈឺផ្សា ទឹកនេត្រា ក៏ស្រាប់តែហូរកាត់ថ្ពាល់ធ្លាក់ទៅដី ពិតជាស្រណោះអាល័យគ្មានថ្ងៃនិងបំភ្លេចបានឡើយ ៕

# ដល់ត្រើយសើយតួច

ដល់ត្រើយសើយតួច បានន័យថា៖ កិច្ចការអ្វីមួយ ដែលរួមគ្នាធ្វើបានជោគជ័យ មានបំណងចង់ដណ្តើមយកផលតែម្នាក់ឯង ហ៊ានទាត់ចោលរាល់មិត្តភ័ក្ត្រ សហការី ដែលធ្លាប់បានតស៊ូជាមួយគ្នាកន្លងមក។

ដល់ត្រើយសើយតួច ផ្ទុយស្រឡះពី ក្លែងជ្រូកដើម្បីស៊ីខ្លា ល្បិចដល់ត្រើយសើយតួចគឺឆ្លៀតឱកាសពេលដែលទទួលបានជោគជ័យហើយ យកកូនចៅគូកនរបស់ខ្លួនទៅសម្លេះចោល។ ចំណែក(ក្លែងជ្រូកដើម្បីស៊ីខ្លា) គឺរិះរកមធ្យោបាយអូសទម្លាក់អ្នកនៅពីលើឆាកឲ្យធ្លាក់ដី ។ បើធ្វើការប្រៀបធៀបទៅឃើញថា៖ ល្បិច(ក្លែងជ្រូកដើម្បីស៊ីខ្លា) ពិតជាគ្រោះថ្នាក់ ចំណែកល្បិច(ដល់ត្រើយសើយតួច)ពិតជាងាយស្រួល។

មន្ត្រីហ្វាន់ឆុង រិះគន់ស្តេចយៀកវ៉ាងថា៖ មនុស្សនេះ ក វែង មាត់ចាបមាត់ព្រាប អាចរួមទុក្ខជាមួយ តែមិនអាចរួមសុខជាមួយគ្នាបានឡើយ។ ពីព្រោះ លោកមើលធ្លុះនូវសភាពការក្នុងរាជការដ៏អាក្រក់នេះ ហេតុនេះ ក្រោយពីរួមដៃគ្នាកំទេចនគរអ៊ូ បានជោគជ័យហើយ លោកក៏លួចរត់ចេញពីរាជវាំង លាក់ខ្លួនពួនអាត្មាដូរឈ្មោះផ្លាស់ត្រកូល ដើរត្រាច់ចរ រកស៊ីគ្រប់ទិសទី ជាសំណាងដែរដែលបានដើរកំសាន្តស្គាល់គ្រប់ទិសទីកន្លែង ចំណែកមិត្តរួមអាវុធរបស់លោក ឈ្មោះវិន-ជុង ព្រោះតែការលោភលន់បុណ្យសក្តិទ្រព្យសម្បត្តិ ចៀសមិនផុតពីការមន្ទិលសង្ស័យរបស់ស្តេចយៀក ទីបំផុតក៏ទទួលវាសនាជាខ្មោចក្រោមផ្លែដាវរបស់ស្តេចយៀកទៅ។

លីវ-ប៉ាង ក្រោយពីទទួលបានជោគជ័យ បានអំណាចរឹងមាំហើយ ក៏ស្រាប់តែកើតចិត្តច្រណែននឹងអ្នកល្អ អោរនឹងអ្នកពូកែ ហើយប្រើវិធីលឿនដូចព្រួញសម្លាប់កូនចៅ មនុស្សទីមួយដែលត្រូវសម្លាប់ គឺមេទ័ព ហាងស៊ី ដែលធ្លាប់បានប្តូរស្លាប់ប្តូររស់ បោសសំអាតពួកក្រុមប្រឆាំង ចោរព្រៃ បន្ទាប់មកបានធ្វើការសម្លាប់យ៉ាងចំហរ ចំពោះមន្ត្រីដែលមានគុណបំណាច់បានកាត់ក្បាល ភឹង-យៀក សម្លាប់យីងពូ យុំខ្លួនសៀវហ៊ីសូម្បីតែ ឈីង-ទី លីងហ្វយ ដែលធ្លាប់ដើរផឹកស៊ីស្រីញីជាមួយគ្នាក៏ស្ទើរក្លាយជាខ្មោចក្រោមផ្លែដាវរបស់លីវ-ប៉ាង ដែរ។ ចាង-លៀង គិតថា៖ ថ្ងៃណាមួយសំណាងអាក្រក់នេះពិតជាធ្លាក់ដល់វេនខ្លួនមិនខាន ដឹងខ្លួនមុនទាន់ ក៏បានសុំ លាឈប់ពីតំណែងទៅបួសងព្រៃជ្រៅ ទើបមានសំណាងជៀសផុតពីសេចក្តីស្លាប់បាន។

នៅមានទៀតដូចជា ជូ-យានចាង ដែលមានដើមកំណើតចេញពីលោកសង្ឃខ្លាំងដៃជាង លីវ-ប៉ាង ទៅទៀត ។ ក្រោយពីឡើងសោយរាជ្យជាស្តេចម៉េងមកបានធ្វើការកាប់សម្លាប់ដល់មន្ត្រីទាហាន ដែលធ្លាប់បាន ចូលរួមប្រយុទ្ធជាមួយខ្លួនក្នុងពេលដណ្តើមទឹកដី ថ្ងៃនេះ ប្រទានសក្តិ ថ្ងៃស្អែកប្រទានក្តីមរណ: មួយប៉ព្រិចភ្នែកប៉ុណ្ណោះ។ បានធ្វើការសម្លាប់យ៉ាងរង្គាល នៅក្នុងប្រវត្តិសាស្ត្រចិន ពិតជាសក្តិសមទទួលឯកត្តកម្មខាងសម្លាប់បាន។ នេះហើយដែលហៅថា(ដល់ត្រើយសើយតួច) នោះ។

អ្នកដែលប្រើល្បិចនេះ ដោយសន្តិវិធីជាងគេ អាចរាប់ថា ជាព្រះអង្គ ចាវវ៉ាំងយីង ទៅចុះដោយគ្រាន់តែប្រើ "ពិធីជប់លៀងស្រាយអំណាចទ័ពប៉ុណ្ណោះ" ។

(ប្រវត្តិជាក់ស្តែង) ព្រះរាជាសុង ព្រះនាម ចាង-វ៉ាំងយីង ក្រោយពីបានឡើងគ្រងរាជ្យដោយសារដណ្តើមអំណាច បានពីមនុស្សដែលជិតដាច់ខ្យល់មក។ បានតែងតាំង

## ដល់គ្រើយសើយតួច

ចាវភ្វ ជាទីប្រឹក្សាពិសេស រាល់កិច្ចការតូចធំរបស់ព្រះនគរ តែងធ្វើការពិភាក្សាជាមួយជានិច្ច។ ពេលនោះ កងទ័ពពិសេស(ទ័ពសំរាប់ការពាររាជធានី) ដែលដឹកនាំដោយមេទ័ព ស៊ឺ-សូវស៊ីង, វ៉ាង-ស៊ីនឈី, ការ-វៃតឹក ។ល។ សុទ្ធសឹងជាមនុស្សជំនិតរបស់ស្តេចចាវ ពួកគេមានសិទ្ធិអំណាចយ៉ាងខ្លាំងក្លា នៅក្នុងជួរកងទ័ព។

ចាវ ភ្វឃើញថា ពួកគេហាក់ដូចជាមានសិទ្ធិអំណាចខ្លាំងជ្រុលបន្តិចហើយ បារម្ភថា អាចមានការគំរាមកំហែងដល់រាជបល្ល័ង្ក ក៏បានឲ្យយោបល់ដល់ស្តេចចាវ ទូលពីភាពគ្រោះថ្នាក់នៃរឿងនេះ គឺចាំបាច់ត្រូវតែរកវិធីកាត់បន្ថយសិទ្ធិអំណាចរបស់ពួកគេ ។

ស្តេច ចាវ ព្រះសណ្តាប់ចប់ក៏មានព្រះរាជបន្ទូលថា៖

លោកម្ចាស់ទុកចិត្តចុះ ពួកគេសុទ្ធតែជាមនុស្សរបស់យើង ដាច់ខាតគឺមិនក្បត់យើងទេ ។ ទូលបង្គំជឿថា ពួកគេពិតជាស្មោះត្រង់នឹងព្រះអង្គ តែទូលបង្គំ បារម្ភតែកូនចៅរបស់ពួកគេតែប៉ុណ្ណោះ ថ្ងៃណាមួយស្រាប់តែកើតចិត្តលោភលន់ ពេលនោះខ្លាចថា សូម្បីតែខ្លួនគេក៏មិនអាចបញ្ជាលើខ្លួនឯងបានដែរ ។

ព្រះសណ្តាប់ទៅហាក់ដូចជាភ្ញាក់ដែរ ស្តេចចាវ គិតឃើញថា កៅអីស្តេចដែលខ្លួនកំពុងអង្គុយនេះបានមករបៀបណានោះហើយ នៅក្នុងប្រវត្តិសាស្ត្រមានឧទាហរណ៍ច្រើនណាស់ ដែលភ្ញៀវក្លាយមកជាម្ចាស់ តើធ្វើយ៉ាងណាទៅដែលអាចដណ្តើមយកអំណាចពីមិត្តរួមអាវុធរួមប្រយុទ្ធប្តូរស្លាប់រស់បានមកវិញនោះ? ពិតជាបញ្ហាដែលឈឺក្បាលមែន។

តែស្តេចចាវ ពិតជាស្តេចដែលមានល្បិចកលអស្ចារ្យ មានព្រះបញ្ញាញាណដ៏សែនឈ្លាសវៃ ព្រះអង្គមិនចង់យកគម្រាប់តាមការសម្លាប់យ៉ាងទាន់ហន់ចំពោះកូនចៅដូចលីវ ប៉ាងនោះទេ។ ស្តេចចាវ ត្រូវការឲ្យនយោបាយ និងអំណាចរបស់ខ្លួនរឹងមាំហើយក៏ចង់បានពាក្យពេជន៍ល្អៗចារក្នុងប្រវត្តិសាស្ត្រផងដែរនិយាយឲ្យខ្លី គឺអំណាចនៅលើដៃខ្លួន ចំពោះពួកទាំងនេះ គឺសុទ្ធជាមាន់ដែលនៅក្នុងទ្រុង ជាត្រីដែលនៅលើជ្រុញប៉ុណ្ណោះ បំណងសំខាន់ គឺចង់ឲ្យពួកគេប្រគល់អំណាចកងទ័ពមកវិញតែប៉ុណ្ណឹង វាគ្រាន់តែថា តើទាមទារអំណាចមកវិញដោយទុកមនុស្សឲ្យរស់ ឬក៏ឲ្យស្លាប់តែប៉ុណ្ណោះ។

ស្តេចចាវ ចេះចាប់រុយដោយប្រើស្ករប្រសើរជាងចាប់រុយដោយប្រើថ្នាំបំពុល ដោះស្រាយដោយបញ្ញាប្រសើរជាងដោះស្រាយដោយអាវុធ ហេតុនេះហើយស្តេចចាវ ក៏ចាប់ប្រើវិធីគួរសមមុនចាំប្រើកម្លាំងជាក្រោយ បើមិនព្រមផឹកស្រាអញ្ជើញទេទៅ សំលៀងកាំបិតគម្រាមជាក្រោយក៏មិនយឺតពេលដែរ។

យប់មួយនាខែ៧ ស្តេចចាវបានរៀបចំពិធីជប់លៀងមួយ ហើយបានអញ្ជើញជាពិសេស ចំពោះលោកមេទ័ពស៊ឺ សូវស៊ីង, វ៉ាង ស៊ិនឈី, ការ វៃតឹក និងរាល់មេបញ្ជាការនៃទ័ពពិសេសទាំងអស់។ពេលដែលកំពុងតែផឹកស៊ីយ៉ាងសប្បាយ ស្តេចចាវ ក៏ហាក់ដូចជានឹកឃើញរឿងអ្វីមួយស្រាប់តែដកដង្ហើមវែងហើយមានព្រះរាជបន្ទូល៖

រាត្រីនេះ យើងទាំងអស់គ្នាបាននៅជួបជុំផឹកស៊ីជាមួយគ្នាយ៉ាងសប្បាយ ក៏ប៉ុន្តែអ្នកណាទៅដឹងថាថ្ងៃក្រោយ តើអាចមានឱកាសបែបនេះទៀតដែរឬទេ?

មេទ័ព ស៊ឺ ហាក់ចម្លែកនឹងបន្ទូល ក៏សួរពីមូលហេតុ ។ ស្តេចចាវក៏មានបន្ទូលបន្ត៖

អាយ! អ្នកទាំងអស់គ្នា មិនដឹងថាធ្វើស្តេចពិបាកយ៉ាងណានោះទេ រាល់ថ្ងៃរស់នៅក្នុងសភាពភិតភ័យជានិច្ច សោយមិនឆ្ងាញ់ ផ្ទំមិនស្កប់ គឺតែងតែភ័យខ្លាចគេមកដណ្តើមរាជបល្ល័ង្កគ្រប់ពេលវេលា មិនស្មើអស់លោក ដែលបានរស់នៅដោយសេរី មិនភិតភ័យ មិនខ្វាយខ្វល់អ្វីទាំងអស់នោះឡើយ។

មេទព័ ស៊ឺ ក៏តបវិញ៖

## ដល់ត្រើយសើយតួច

បច្ចុប្បន្នព្រះនគរបានសន្តិភាពហើយ ឬមួយក៏នៅមានជនណាថ្លើមធំមានបំណងចង់ក្បត់?
គឺពិតជារកសេចក្ដីស្លាប់ដោយខ្លួនឯងហើយ ។
ស្ដេចចាវ ព្រះសំណើចយ៉ាងពិសពុលះ
យើងពិតជាជឿជាក់ភាពស្មោះត្រង់របស់ពួកអស់លោក ក៏ប៉ុន្ដែក្រែងថ្ងៃណានោះ កូនចៅ
របស់អស់លោក កើតក្ដីលោភលន់ដាច់ខាត់បង្ខំឲ្យអស់លោកឡើងធ្វើស្ដេចពេលនោះ
ជឿថាសូម្បីតែអស់លោកខ្លួនឯង ក៏មិនអាចបញ្ជាលើខ្លួនឯងបានដែរ។
ព្រះរាជបន្ទូលមានភាពសាមញ្ញធម្មតា ប៉ុន្ដែសម្រាប់មេទ័ពទាំងអស់ គឺប្រៀបបាន
នឹងរន្ទះបាញ់ខែចេត្រតែម្ដង ទាំងអស់គ្នាភ្ញាក់ក្រញ៉ាងដូចគេធាក់មួយជើងផ្លាស់ប្ដូរទឹកមុខ
គ្រប់គ្នាហើយប្រញ៉ាប់ប្រញ៉ាល់លុតជង្គង់គ្រឹបព្រមគ្នាដូចបានណាត់ទុក ថ្វាយបង្គំស្ដេច ចាវ
សុំព្រះរាជយោបល់៖
ទូលបង្គំទាំងអស់គ្នាពិតជាល្ងង់ខ្លៅពុំដឹងធ្វើយ៉ាងណាទើបគាប់ប្រសើរនោះទេ
គ្រាន់តែដឹងថាទូលបង្គំទាំងអស់គ្នាពិតជាស្មោះត្រង់នឹងព្រះអង្គគ្មានគំនិតអាក្រក់
បន្តិចណាឡើយ សូមព្រះអង្គយល់ដល់ពួកទូលបង្គំដែលធ្លាប់បានហែរហមព្រះអង្គ
តាំងពីដើមរៀងមក សូមព្រះមេត្តាចង្អុលបង្ហាញផ្លូវដែលត្រូវដើរដល់ពួកទូលបង្គំផង
ពួកទូលបង្គំធានាថាពិតជាស្ដាប់ និងធ្វើតាមព្រះរាជបញ្ជារបស់ព្រះអង្គទាំងអស់។
ឃើញសភាពបែបនេះ ស្ដេចចាវ ពិតជាពេញចិត្ត តែធ្វើជាបង្ហាញទឹកព្រះភក្រ័គួរឲ្យ
សោកសង្រេង ហើយមានព្រះរាជបន្ទូល៖ មួយជីវិតរបស់មនុស្សប្រៀបបាននឹងសុបិន។
តែប៉ុន្មានសិបឆ្នាំប៉ុណ្ណោះ ធ្មេចបើកៗគឺកន្លងផុតទៅហើយអស់លោក បានលះបង់
ជីវិតនិងពេលវេលាដើម្បីកិច្ចការព្រះនគរក្នុងប្រវត្តិសាស្ត្រ ក៏បានក៏បានចារពីស្នាដៃ
ដែរហើយ ទាំងកេរ្ដិ៍ឈ្មោះនិងកិត្តិយស អស់លោកបានទទួលអស់ហើយមែនទេ?
រាប់ថាជាតិនេះ មិនរស់នៅឲ្យធ្ងន់ផែនដីនោះទេ ជីវិតចុងក្រោយឲ្យតែបានរស់នៅ
ដោយរុងរឿង រស់នៅដោយភាពស្ងៀមស្ងាត់ ពិតជាល្អប្រសើរណាស់។
មានព្រះរាជបន្ទូលដល់ត្រឹមនេះក៏វាសព្រះនេត្រទតមើល៍អ្នកទាំងអស់គ្នាមួយត្រួស
ឃើញអ្នកទាំងអស់គ្នានៅគ្មឹងដូចអ្នកតាថ្មក៏តាំងបញ្ចេញឫកពាររបៀប(ឆ្មាឃុំអាណិតកណ្ដុរ)
ហើយមានបន្ទូលបន្តរ ៖
អ្ហើយ! យើងអង្គុយនៅលើរាជបល្ល័ងនេះ ពិតជាគ្មានលទ្ធភាពដោះខ្លួនបានទេ
កិច្ចការមួយហើយមួយទៀតទាំងក្នុងទាំងក្រៅ មិនខុសដូចពាក្យគេនិយាយមែន
១ឆ្នាំ៣៦៥ថ្ងៃ ថ្ងៃណាក៏រវល់និងកើតទុក្ខដែរ ចង់ធ្វើឬ?
កិច្ចការច្រើន មិនចេះចប់មិនចេះហើយ បើមិនធ្វើ ពិតជាធ្វើឲ្យប្រជារាស្ត្រអស់
សង្ឃឹមដោយសារតែរឿងនេះ យើងផ្ទុំមិនលក់រៀងរាល់រាត្រី ពិតមែនតែជាស្ដេចផែនដី
តែអ្វីដែលជាការលំបាកគ្មានអ្នកក្រៅណាអាចយល់បានឡើយ។ ហេតុនេះហើយ
បានជាយើងមិនចង់ឲ្យអស់លោកទាំងអស់គ្នាដែលប្រៀបបានជាបងប្អូនទទួលរង
កម្មបែបនេះតទៅទៀតទេ! ចំពោះយើងពិតជាគ្មានលទ្ធភាពដោះខ្លួនបានទេ
ចំណែកអស់លោក មិនទាន់ហួសពេលនៅឡើយ យើងគិតនេះ គឺដើម្បីសេចក្ដីសុខ
របស់អស់លោកតែប៉ុណ្ណោះ ជាការប្រសើរអស់លោកគួរតែបោះបង់ចោលការងារ
ទាំងនេះទៅរឿងអ្វីក៏កុំរវល់ ទៅរស់នៅយ៉ាងសុខសាន្តជាប្រជារាស្ត្រ ចង់ដេក
ដល់ថ្ងៃថាំងគូថ ក៏គ្មានអ្នកណាថាឲ្យដែរមិនចាំបាច់ពេលខ្លះអត់ងងុយងើបពាក់
កណ្ដាលអធ្រាតដើម្បីប្រជុំ។ល។ ការរស់នៅដោយស្ងៀមស្ងាត់ មិនឮសម្លេងកាំបិត
លំពែងប៉ះកកទង្គិចគ្នា ពិតជាមានសេចក្ដីសុខណាស់ សូម្បីនៅឋានទេវតាក៏មិន

# ដល់ត្រើយសើយគូថ

ស្មើឋានមនុស្សលោកក៏កម្រនឹងរក បានបើសិនជាអស់លោកយល់ព្រមតាមសំណូមពរនេះ យល់ដល់ដល់ការរាប់អានគ្នាកន្លងមក លាឈប់ពីមុខតំណែងយើងនឹងប្រទានដល់អស់លោកនូវមាសប្រាក់យ៉ាងច្រើនគ្រប់គ្នា លាឈប់ពីមុខតំណែងទៅរស់នៅស្រែចំការសោយសុខជីវិតចុងក្រោយ ចំពោះយើងពិតមែនតែថ្ងៃក្រោយមិនអាចជួបមុខអស់លោកបានញឹកញាប់ ក៏ប៉ុន្តែឲ្យតែអស់លោកបានសេចក្តីសុខយើងសប្បាយព្រះទ័យណាស់ទៅហើយ តើអស់លោកយល់យ៉ាងណាដែរ?

គ្រប់គ្នាជាមេទ័ពដែលកំពុងមានអំណាចយ៉ាងពេញដៃ និងខែងវែងនោះ ក្រោយពីស្តាប់ព្រះរាជបន្ទូលដែលទន់ភ្លន់ តែបង្កប់នូវភាពបង្ខំបែបនេះចប់ក៏ឈប់សួរដេញដោលរកពីមូលហេតុអ្វីទៀតហើយ ពិតមែនតែក្នុងចិត្តម្នាក់ៗមួយម៉ឺនមិនយល់ព្រម ក៏ប៉ុន្តែក្នុងទីនេះ ក្នុងកាលៈទេសៈនេះនិងនឹកឃើញចរិកបោកប្រើរបស់ស្តេចចាវកន្លងមក និងនឹកឃើញមេរៀនដល់ត្រើយសើយគូថក្នុងប្រវត្តិសាស្ត្រកន្លងមកគ្មានពាក្យអ្វីក្រៅពីស្រែកថា៖ អរគុណព្រះអង្គ សូមព្រះអង្គមានអាយុម៉ឺនឆ្នាំ។ គ្រប់គ្នាដឹងថាឲ្យតែរក្សាបានក្បាលមិនរត់ចោលស្មាវាជាសំណាងណាស់ទៅហើយ នៅថ្ងៃទីពីរគ្រប់គ្នាក៏បានធ្វើលិខិតលាឈប់ជាបន្តបន្ទាប់………។ ដោយហេតុនេះប្រើពេលតែមួយរាត្រីប៉ុណ្ណោះ ស្តេចចាវបាន ដណ្តើមអំណាចទ័ពមកក្នុងដៃ ដោយសន្តិវិធីកៅអីស្តេចចាវ រិតតែរឹងមាំអាចសោយឆ្វាញ់ផ្ទុំលក់ដោយគ្មានកង្វល់ ។

នេះហើយហៅថា៖ (ដល់ត្រើយសើយគូថនោះ)៕

# ដឹងតែធ្វើពើ ( ធ្វើមិនដឹង )

(ដឹងតែធ្វើមិនដឹង) តាមន័យរបស់វាគឺ ដឹងច្បាស់ប្រាកដពីរឿងនោះហើយ តែមានចេតនាធ្វើពើមិន ដឹង។ អាកប្បកិរិយាបែបនេះ ច្រើនជាអំពើរបស់អ្នករៀនខាងទស្សនៈវិជ្ជា សុភាសិតចិនមួយសរសេរថា៖ មិនចេះធ្វើភ្លើធ្វើថ្លង់ មិនអាចធ្វើអាអ៊ុង (អាអ៊ុង បានន័យថាលោកម្ចាស់) ហើយក៏ជាទង្វើរការពារខ្លួន គោលបំណងនៅត្រង់ជៀសឲ្យផុតពីការខុសនិងត្រូវ ។

ប៉ុន្តែ បើប្រើជាល្បិចកលវិញនោះ មិនត្រឹមតែសម្រាប់ការពារខ្លួនប៉ុណ្ណោះទេ។ ល្បិចកលហ៍ គឺយកមកប្រើសម្រាប់ទប់ទល់នឹងអ្នកដទៃ។ បើសិនជាមានគំនិតគេចវេសពីការពិត តើម្តេចនឹងអាចពុះពារឧបសគ្គដែលរារាំងចំពោះមុខ កសាងផ្លូវអនាគតសម្រាប់ខ្លួនបាននោះ? ។

ជាការពិត ចំពោះកិច្ចការអ្វីមួយ ដឹងហើយអាចធ្វើពើជាមិនដឹង ពុំមែនជារឿងងាយស្រួលនោះទេ។ ចាំបាច់ត្រូវតែមានការអប់រំខ្ពស់ ទើបអាចធ្វើទៅកើត។ ហេតុតែមានការបែងចែកមនុស្សឈ្លាស់វៃ និងល្ងង់ខ្លៅនោះ គឺបិតនៅត្រង់(ដឹង)ឬ(មិនដឹង) អាច(ធ្វើពើ)ឬ(មិនអាចធ្វើពើ) នោះឯង។ ជនល្ងង់ខ្លៅ មិនអាចវាស់ជម្រៅរបស់អ្នកចេះដឹងបាន តែងតែនិយាយថា៖ ពួកគេទាំងអស់នោះ ជាមនុស្សគ្រោះថ្នាក់ លាក់ពុតហើយក្រឡិចក្រឡុច ធ្វើអ្វីក៏ដោយ រកយល់មិនបានទាល់តែសោះ ត្រង់(រកយល់មិនបាន)នេះហើយដែលជាចំណុចពិសេសរបស់អ្នកចេះនោះឯង។ នេះហើយហៅថា (អ្នកចេះធ្វើភ្លើ) នោះឯង  ជាអំពើដែលមនុស្សសាមញ្ញមិនអាចយល់បាន។

សូមលើកឧទាហរណ៍មួយ ដើម្បីធ្វើការពិចារណា តើដឹង តែអាចធ្វើពើមិនដឹង គឺជាសកម្មភាពរបស់ជនល្ងង់ខ្លៅឬទេ? ក្នុងសម័យ ឈុន-ឈីវ ស្តេចឆ បានរៀបចំពិធីជប់លៀងដ៏ធំមួយដល់មន្ត្រីតូចធំទាំងអស់ ហើយឲ្យឈ្មោះថា(ពិធីជប់លៀងសន្តិភាព)។ អាស្រ័យហេតុនេះ មន្ត្រីតូចធំនៅក្នុងរាជវាំងទាំងស្នំឯក ជី-ស៊ឺន បានចូលរួមជបលៀងសប្បាយទាំងអស់គ្នា ប្រុសស្រីប្រជ្រៀតគ្នា ម្ហូបឆ្ងាញ់ស្រាឈ្ងុយ មានចម្រៀងរបាំលេង និងរាំកំដរ ពិតជាអឹកធឹក អមដោយតន្ត្រីកន្ត្រាក់អារម្មណ៍ឮ រហូតប្រលប់នៅតែខៀវខ្វារនៅឡើយ ។

ងងឹតហើយ ស្តេចឆ បានបញ្ជាឲ្យដុតទៀនផឹកបន្តរ នៅពេលយប់ទៀត ថែមទាំងហៅស្នំដ៏ស្រស់ស្អាតនិងជាទីស្រឡាញ់បំផុតគឺ ស៊ី-ជី និង ម៉ែ-ស៊ី ឲ្យមកផ្លាស់ប្តូរវេនគ្នាចាក់ស្រាជូនដល់ភ្ញៀវទាំងអស់ទៀតផង ស្រាប់តែខ្យល់ចម្លែកមួយបក់វ៉ឹប ទៀនទាំងអស់ត្រូវបក់ឲ្យរលំ ក្នុងបន្ទប់ងងឹតស្លុប ឆ្លៀតឱកាសនោះ ភ្ញៀវម្នាក់ក្នុងចំណោមនោះ បានលូកដៃភ្លែត លួចអង្អែលដៃដ៏ស្រស់ស្រលូនរបស់ស្នំ ស៊ី-ជី។ ស៊ី-ជី ប្រញាប់រលាស់ដៃឆ្វេងដែលត្រូវលួចអង្អែលចេញភ្លាម ដៃស្តាំក៏លូកទៅទាញបណ្តាច់ខ្សែចងមួករបស់ជននោះ ហើយប្រញាប់ប្រញាល់ត្រលប់មកកន្លែងវិញ រួចខ្សឹបទូលស្តេចឆ ថា៖

-អំបាញ់មិញ ទូលបង្គំទទួលរាជបញ្ជាទៅចាក់ស្រាជូនភ្ញៀវ ស្រាប់តែមានមនុស្សម្នាក់ ឆ្លៀតមើលងាយទូលបង្គំ ទូលបង្គំបានទាញបណ្តាច់ខ្សែចងមួករបស់វា សូមព្រះអង្គ ប្រញាប់ឲ្យគេដុតទៀនបំភ្លឺឡើង អ្នកណា គ្មានខ្សែចងមួក គឺជាអ្នកហ្នឹងហើយ។

ព្រះសណ្តាប់ចប់ ស្តេចឆ ប្រញាប់ប្រញាល់បញ្ជាដល់អ្នកបំរុងនឹងអុជទៀន ឲ្យផ្អាកវិញសិន ហើយមានព្រះរាជបន្ទូលខ្លាំងៗ៖

-ពិធីជប់លៀងរបស់យើងយប់នេះ គឺត្រូវផឹកស្រវឹងទាំងអស់គ្នា ដូច្នេះ សូមអស់លោកដោះមួកចេញផឹកអោយអស់ដៃម្តង។

ហេតុនេះ សេនាមន្ត្រីទាំងអស់ ក៏បានដោះមួកចេញ ពេលនោះទើបស្តេចឆ បញ្ជាអោយអុចទៀនបំភ្លឺ ឃើញថាទាំងអស់គ្នាបានដោះមួកចេញអស់ហើយ មើលមិនដឹងថា អ្នកណាជាអ្នកប្រព្រឹត្តអំពើអំបាញ់មិញនោះឡើយ។

# ដឹងតែធ្វើពើ ធ្វើមិនដឹង

ចប់កម្មវិធី នាងស៊ី-ជី បន្ទោសស្តេចឆ ថាមិនជួយរកមុខអ្នកមើលងាយនោះឲ្យនាង ស្តេចឆ បែជាសើច ហើយមានព្រះរាជបន្ទូលថាៈ

-នាងមិនដឹងទេឬ? ពិធីជប់លៀងលើកនេះ គោលបំណងគឺត្រូវតែផឹកឲ្យណាណី សប្បាយឲ្យអស់ដៃ ដឹងទេថា ក្រោយផឹកមនុស្សនឹងស្រវឹង ពេលស្រវឹងពិតជារពឹសមាត់រពឹសដៃ គឺជារឿងធម្មតារបស់អ្នកផឹក បើសិនជា ចាប់ទោសអូសដំណើរគេឲ្យចេញមក ពិតជាធ្វើឲ្យរំខានដល់ពិធី វាមិនផ្ទុយនឹងបំណងដើមនៃពិធីនេះទៅហើយ? ស៊ី-ជី ស្តាប់ហើយ ទើបកោតសរសើរពីព្រះបញ្ញាញាណដ៏ឈ្លាសវៃរបស់ស្តេចឆ ។

ក្រោយមក ស្តេចឆ វាយនគរជីន មានមេទ័ពម្នាក់ បានដឹកនាំទ័ពរាប់រយនាក់តែម្នាក់ឯង វាយបើកផ្លូវឲ្យទ័ពទាំង៣ បានសម្លាប់ទ័ពសត្រូវ ដណ្តើមបានច្រកការពារ សម្រុកចូលរាជធានីនៃនគរជីន ធ្វើឲ្យស្តេចឆ ល្បីរន្ទឺពេញផែនដី មនុស្សនេះហើយ គឺ ថាង-ជៀវ ជនដែលឆ្លៀតឱកាសរលត់ទៀន ហើយទៅលូចអង្អែលដៃរបស់ស្នំ ស៊ី-ជី នោះឯង។

នៅមានរឿងនិទានមួយទៀត ដែលកើតឡើងកាលសម័យសាមកុក។ ពេលសង្គ្រាមនៅឈឺ-ពី, ចូវ-យី បានប្រើល្បិច(ដឹងតែពើធ្វើមិនដឹងនេះ) ប្រលែងលេងជាមួយនឹងជើងឆើតល្បីខាងក្រឡិចក្រឡុច ចាវ-ឆាវ ទីបំផុតក៏ ប្រើភ្លើងមួយបាច់ ដុតទាល់តែ ចាវ-ឆាវ ភ័យរត់បាត់ព្រលឹងព្រលះពីក្នុងខ្លួន ។

(ប្រវត្តិពិត) ចុងឆ្នាំនៃសម័យ តុង-ហាន ចាវ-ឆាវ ដែលពូកែខាងច្បាំង និងប្រសប់ខាងប្រើល្បិច បានចាប់បង្ខំស្តេច ដើម្បីដាក់បញ្ជាដល់គ្រប់ស្តេចក្រាញ់បានសម្លាប់ តុង-ចាវ ចាប់ លី-ពូ កំទេច អាយ-ចាវ ទន្ទ្រានយកខេត្ត លី-ចូវ ដេញលីវ-ប៉ី រត់ផាស់ក្រញ៉ាំបាត់ព្រលឹងធំ។ ពង្រាយទ័ពឯទន្លេឆាវ-ជាង ផ្សព្វផ្សាយថាៈ នឹងវាយយកតំបន់ ជាង-ណាន បម្រុងយកភាពខ្លាំងដូចភ្នំបាក់ បង្ខំឲ្យស៊ុន-ឈាន សារភាព។ ស៊ុន-ឈាន នៃគុង-អ៊ូ នៅក្រោមការលើកទឹកចិត្តរបស់ ចូវ-យី ក្រោមការអុជអាលរបស់ខុង-ម៉េង ស្រាប់តែរៀបចំទ័ពតបតទៅវិញ គឺនៅប្រឈមមុខដាក់គ្នាឯម្ខាងទន្លេ។ ពេលនោះចាវ-ឆាវ មានទ័ពរាប់រយម៉ឺន ចំណែក ចូវ-យី មានទ័ពប្រាំ ប្រាំមួយម៉ឺនប៉ុណ្ណោះ គឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បំផុត មិនខុសពីយកសត្វកណ្តុប
ទៅទប់នឹងកង់រទេះ
យកពងមាន់ទៅជល់និងថ្មឡើយ កុំថាឡើយវាយសម្រុក សូម្បីតែការពារខ្លួនក៏ពិបាកដែរ។ ចូវ-យី ដឹងថាក្នុកិច្ចការយោធា ម្ចាស់ការ គឺជាការគោលការណ៍មូលដ្ឋានចាំបាច់បំផុត លោកដឹងយ៉ាងច្បាស់ទៀតថា កងទ័ពភាគ ខាងជើង មិនពូកែសង្គ្រាមជើងទឹកនោះទេ គិតថា ត្រូវតែរិះរកមធ្យោបាយ
កំចាត់មេបញ្ជារ
ទ័ពជើងទឹករបស់ ចាវ-ឆាវ គឺឆាយ-ម៉ាវ និង ចាង-យ៉ឺង ជាមុន(ពីរនាក់នេះពីមុនគឺជាកូនចៅរបស់ លីវ-ពាវ ហើយបានរត់ទៅចុះចូលជាមួយនិង ចាវ-ឆាវ) តែមិនដឹងមានមធ្យោបាយអ្វី។

កំពុងតែពិភាក្សាគ្នានៅក្នុងជំរុំ ឮខាងក្រៅស្រែកប្រាប់ថាៈ ជាង-កាន់
ដែលជាអ្នកស្រុកកំណើតជាមួយ
មកសួរសុខទុក្ខ។ ចូវ-យី ក៏សើចដាក់មេទ័ពគ្រប់គ្នា ហើយនិយាយៈ

-អ្នកបញ្ចុះបញ្ចូលរបស់ ចាវ-ឆាវ មកដល់ហើយ។ ហើយក៏ផ្តាំផ្ញើរទៅមេទ័ពទាំងអស់ ត្រូវធ្វើយ៉ាងនេះ ឬធ្វើយ៉ាងនោះ  គ្រប់គ្នាស្តាប់ហើយក៏បែកទៅធ្វើតាមនាទីរៀងៗខ្លួន។
ចូវ-យី ចាប់ទាញអាវឲ្យសមរម្យ ហើយដើរចេញទៅទទួល គ្រាន់តែជួបមុខក៏សួរតែម្តងៈ

-ជឺ-យី (ឈ្មោះក្រៅរបស់លោក ជាំង-កាន់) ឆ្លងទន្លេមកសួរសុខទុក្ខ មិនមែនមកក្នុងនាម ចាវ-ឆាវ មកបញ្ចុះបញ្ចូលយើងឲ្យសារភាពទេ មែនទេ? ជាង-កាន់ ឮនិយាយបែបនេះក៏ស្រឡាំងកាំងហើយតបៈ

-ឯងនេះពិតជាពូកែសង្ស័យមែន យើងមកនេះដោយសារតែបែកឯងយូរណាស់ហើយ

# ដឹងតែធ្វើពើ ធ្វើមិនដឹង

បានជាមកសួរសុខ

ទុក្ខឯងហ្នឹង នឹកឃើញយ៉ាងម៉េច បានជាថាយើងជាអ្នកមកចរចារនោះ? ចូវ-យី សើច:

-ចម្រៀងដែលច្រៀងអាចដឹងពីទឹកចិត្ត នៅក្នុងស្ថានភាពដ៏តឹងតែបែបនេះ.......។

មិនរង់ចាំឲ្យនិយាយចប់ទេ ជាង-កាន់ ក៏តបវិញដោយអាក់អន់ចិត្ត។

-បើឯងមានចិត្តសង្ស័យមិត្តភ័ក្រ្តបែបនេះ ណ្ហើយ! លាសិនហើយ!

ចូវ-យី ចាប់ទាញស្មាគេជាប់ សើចហើយនិយាយ:

-គ្រាន់តែនិយាយលេងសើចប៉ុណ្ណឹង ក្នុងនាមមិត្តភ័ក្រ ប្រកាន់ដែរឬ? បានជាលោកបងមកនេះ មិនមែន ជាអ្នកបញ្ចុះបញ្ចូល តំណាងឲ្យចាវ-ឆាវ ទេនោះ នៅសម្រាកលេងទីនេះបានយូរថ្ងៃបន្តិច ចាំត្រឡប់ទៅវិញ ។

-មិនចាំឲ្យ ជាំង-កាន់ វែកញែកទាន់ទេ ក៏អូសគេឲ្យចូលក្នុងជំរុំ ក្រោយពីសួរសុខ ទុក្ខទៅវិញទៅមកហើយ ចូវ-យី ក៏បញ្ជាឲ្យមេទ័ពទាំងអស់ ចូលមកជួប ជាង កាន់ ហើយក៏ទាញតុ ទាញជើងម៉ា រៀបចំពិធីជប់លៀងតែម្តង រួចនិយាយទៅកាន់មេទ័ពទាំងអស់:

-លោកជាង ជាមិត្តភ័ក្រដ៏ល្អបំផុតរបស់យើង និងមានស្រុកកំណើតជាមួយគ្នា ពិតមែនតែ មកពីជាងប៉ី (ភាគខាងជើង) តែពុំមែនក្នុងនាមចាវ-ឆាវ នោះទេ ហេតុនេះ សុំបងប្អូនកុំមានការសង្ស័យ ឲ្យសោះ។ និយាយចប់ ទាញដាវខ្វាកចេញពីចង្កេះ ប្រគល់ឲ្យ ថៃ-ស៊ី ហើយបញ្ជា៖

-កានដាវរបស់យើង ដើរត្រួតពិនិត្រការផឹកស៊ី ពិធីជប់លៀងថ្ងៃនេះ អនុញ្ញាតិឲ្យរៀបរាប់តែពី មនោសញ្ចេតនា រវាងមិត្តភ័ក្រ ឬក៏វែកញែកពីចម្រៀងកំណាព្យផ្សេងៗ បើមានអ្នកណានិយាយរំលឹក ពីរឿង ចាវ-ឆាវ និងកិច្ចការយោធានៃនគរយើង អាចកាត់ទោសសម្លាប់ចោលនៅនឹងកន្លែងតែម្តង។ ឮសំដីបែបនេះ ជាង-កាន់ ភ្ញាក់ឡើងភាំង ក៏នៅស្ងៀមមិនហ៊ាននិយាយអ្វីទាំងអស់ ចូវ-យី បន្ត៖ -តាំងពី យើងដឹកនាំទ័ពមក ពុំដែលផឹកស្រាទាល់តែសោះ ថ្ងៃនេះបានជួបជុំសម្លាញ់ចាស់ បើមិន ស្រវឹងពិតជាមិនឈប់។

និយាយចប់ ក៏សើចក្អាកក្អាយ ហើយក៏ចាប់ផ្តើមគោះកែវជូនស្រា ហ៊ឹកហ៊ាក់ អ៊ូរអរពេកក្រៃ។ ទាំងអស់គ្នា ហាក់ស្រវឹងស្រៀងៗហើយ ចូវ-យី ចាប់ទាញដៃ ជាង-កាន់ ចេញទៅខាងក្រៅដើរលំហែរ ចូវ-យី សួរ៖

-យ៉ាងម៉េចដែរ មេបញ្ជាការនិងកូនទាហានរបស់យើងក្លាហានឬទេ?

ជាង-កាន់តប៖

-ពិតជាមិនខុសមែន មេទ័ពអង់អាច ពិតជាគ្មានកូនទ័ពកំសាកទេ !

ចូវ-យី ក៏នាំ ជាង-កាន់ ទៅខាងក្រោយជំរុំ ឃើញស្បៀងគរដូចភ្នំ ក៏សួរទៀត:

-លោកបងយល់ថា ស្បៀងនេះគ្រប់គ្រាន់ឬទេ?

-ពិតជាទ័ពខ្លាំង ស្បៀងគ្រប់ លោកបងពិតជាអស្ចារ្យមែន !

ជាង-កាន់ តបបែបហ៊ី ។

ចូវ-យី សើចរបៀបស្រវឹងហើយនិយាយ៖

-នឹកឃើញឆ្នាំណានោះ ដែលយើងនៅជាមួយគ្នា ទោះយល់សប្តិ ក៏ស្មានមិនដល់ថា មានថ្ងៃនេះ ទាល់តែសោះ......។

ជាង-កាន់ តបវិញ៖ វាត្រូវតែមាន ព្រោះលោកបងមានសម្ថភាពគ្រប់គ្រាន់ អស្ចារ្យ ក្លាហាន និងពូកែ វាមិនមែនជារឿងស្មានមិនដល់នោះទេ។

-ជីវិតរស់នៅ បានជួបវាសនាបែបនេះ តើមានអ្វីគួរនិយាយទៀត ជួបម្ចាស់ដែលយល់ពីខ្លួន ពិតមែនតែ ក្នុងឋានៈជាស្តេចនិងមន្ត្រី តែប្រៀបបាននឹងសាច់ឈាមតែមួយ មានបន្ទូលត្រូវតែស្តាប់ មានឧបាយកលត្រូវតែ អនុវត្តតាម បានសុខ រួមគ្នាដោះស្រាយ ទោះបីជា ស៊ូ-ឈីន ចាង-យីកើតម្តងទៀតក៏មិនអាចនិយាយបញ្ចុះបញ្ចូលយើង ឲ្យក្បត់ពីបំណងដើមបានឡើយ ។

## ដឹងតែធ្វើពើ ធ្វើមិនដឹង

សំដីរបស់ ចូវ-យី នេះគឺជាសញ្ញាសំគាល់មួយយ៉ាងច្បាស់ ធ្វើឲ្យ ជាង-កាន់ ភ័យឡើងស្លេកមុខ។ បន្ទាប់មកក៏នាំគ្នាត្រឡប់មកផឹកឯក្នុងជំរុំវិញ ចំណែក ជាង-កាន់ តែមួយម៉ាត់ ក៏មិនហ៊ានរំលឹកពីរឿងទ័ពទឹង រហូត។ យប់ជ្រៅណាស់ហើយ ជាង-កាន់ មិនអាចផន់នឹងស្រាទៀតបាន ក៏សុំលាទៅមុន ចូវ-យី ធ្វើពើជាស្រវឹងខ្លាំងសម្បើមណាស់ចាប់ទាញ ជាង-កាន់ ជាប់ហើយនិយាយៈ

-យូរណាស់ហើយ ដែលយើងខានដេករួមគ្រែជាមួយគ្នា យប់នេះ យើងដេកជាមួយគ្នា ព្រោកប្រាជ្ញ ឲ្យវាណា ណឹម្តង។

ពិតជាគ្រែមួយ សុបិនផ្សេងគ្នា គំនិតអាក្រក់ពេញខួរវៀងខ្លួន
ម្នាក់ធ្វើពើជាស្រវឹងក្អួតចាក់ដោតចាក់ទឹង
ម្នាក់ធ្វើពើជាដេកលក់ តែព្រលឹងនៅចុងសក់។ រគាំងយាមពីរបានកន្លងផុតទៅ ជាង-កាន់ ដេកម៉េ្តចនិងលក់? ងើបខ្លួនឡើងសម្លឹងមើល ឃើញចង្កៀង នៅភ្លឺនៅឡើយ ចំណែក ចុវ-យី ស្រម៉ុកឮខ្វរពេញជំរុំ ក្រឡេកទៅ ឃើញនៅលើតុមានដាក់ឯកសារមួយគំនរ ក៏ងើបក្រោះ ដើរលបៗទៅលួចមើល សុទ្ធតែជាលិខិតស្នាមទំនាក់ទំនងគ្នាទៅវិញទៅមក នៅក្នុងនោះមានលិខិតមួយដែល ចាង-យឹង,ឆាយ-ម៉ាវ សរសេរផ្ញើរមក ក៏ប្រញាប់លួចមើល ដែលមានសេចក្តីថាៈ ខ្ញុំនិងអ្នកដទៃ ដែលចុះចូលជាមួយនិង ចាវ-ឆាវ
ដោយសារមកពីស្ថានការណ៍
បង្ខំ ឲ្យតែមានឱកាស និងកាត់ក្បាលចោរក្បត់ ចាវ-ឆាវ ថ្វាយដល់ព្រះអង្គភ្លាម។

ជាំង-កាន់ លួចភ្ញាក់ព្រើត តាមការពិត ចាង-យឹង, ឆាយ-ម៉ាវ មានឧបាយកលបែបនេះតើ ក៏យក សំបុត្រនេះលាក់ក្នុងខ្លួន។

ចូវ-យី ប្រែខ្លួនហើយ ជាង-កាន់ ប្រញាប់ផ្លុំពន្លត់ភ្លើងចង្កៀង ដើរលបៗត្រឡប់មកវិញ ឮចូវ-យី មមើនិយាយថាៈ -ជឺ-យី នៅក្នុងប៉ុន្មានថ្ងៃនេះ យើងនឹងកាត់ក្បាល ចាវ-ឆាវ ឲ្យឯងមើលមិនខាន។

-អឺ.......។ ជាង-កាន់ ក៏ធ្វើពុតតាមដែរ។

-មែនណា ជឺ-យី......យើងនឹងយកក្បាលវាឲ្យឯងមើល.......។

-ថាម៉េច ឯងកំពុងនិយាយថាម៉េច? ជាង-កាន់ សួរតែ ចូវ-យី ចាប់ផ្តើមស្រម៉ុក ឡើងខ្វរទៀតហើយ។

ជាង-កាន់ ទ្រាបទៅលើខ្នើយពុតជាដេក តែត្រចៀកចាំស្តាប់សូរស័ព្ទជុំវិញខ្លួនយ៉ាងប្រុងប្រយ័ត្ន។ យាមបួនហើយ ក៏ឮសំឡេងមនុស្សដើរចូលមកហើយនិយាយដាស់តិចៗ.

-លោកមេទ័ព ! លោកមេទ័ព

-អឺ អ៊ឺ ! ចូវ-យី ត្រូវដាស់ឲ្យភ្ញាក់សួរបែបមមើមមាយ:

-អ្នកណាដេកលើគ្រែយើងហ្នឹង ?

-មិត្តសំឡាញ់របស់លោកម្ចាស់ គឺលោកជាង-កាន់ នោះអី ម្តេចបានជាប្រញាប់ភ្លេចម្ល៉េះ។ជននោះឆ្លើយ

-អាយ វីរហើ។ ចូវ-យី និយាយបែបស្តាយក្រោយ:

-ធម្មតាយើងមិនដែលផឹកស្រាសោះ លើនេះផឹកស្រាច្រើនពេក ពិតជាធ្វើឲ្យខូចការហើយ មិនដឹងជា
យើងបាននិយាយរឿងអ្វីខ្លះ?

ជននោះក៏និយាយកាត់:

-ខាងជាងប៉ីមានមនុស្សមក ។

-ស៊ីត......ចូវ-យី ធ្វើសញ្ញាព្រមាន ។ ហើយក៏ហៅ:

-ជឺ-យី ! ជឺ-យី !

ជាង-កាន់ ធ្វើពុតជាដេកលក់ ចូវ-យី ក៏ចេញប្រុចមកខាងក្រៅ ជននោះនិយាយតិចៗៈ

# ដឹងតែធ្វើពើ ធ្វើមិនដឹង

-លោកមេទ័ព ចាង និងលោកមេទ័ព ឆាយ ឲ្យខ្ញុំមករាយការណ៍ ប្រាប់លោកមេទ័ពថាៈ ឥឡូវនេះ ចាវ-ឆាវ ការពារតឹងតែងណាស់ មិនទាន់មានឱកាសធ្វើសកម្មភាពទេ។ ពាក្យខាងក្រោយរឹតតែពុតិចទៅៗ ស្តាប់ មិនច្បាស់។ មួយសន្ទុះ ចូវ-យី ក៏ត្រឡប់មកវិញ ហើយធ្វើជាហៅ ជាង-កាន់ ទៀត ជាង-កាន់ មិនខ្វីឆ្លើយ គិតតែពី យ្លុំក្បាលធ្វើពុតជាដេក
ធ្វើមិនឮ ។ ចូវ-យី ក៏ឡើងលើគ្រែវិញ ហើយក៏ចាប់ផ្តើមស្រមុកទៀត ។

ដេករហូតដល់យាមប្រាំ ជាង-កាន់ ក៏ដាស់ ចូវ-យី តិចៗ តែចូវ-យី ដេកលក់ដូចជ្រូកងាប់អីចឹង ជាង-កាន់ ក៏ទាញមួកនិ ងអាវមកពាក់ ហើយដើរសំដៅច្រកចេញ។ អ្នកយាមសួរថា ទៅណា?
ជាង-កាន ក៏រ៉ាយរ៉ាប់ប្រាប់នាយអាយ ទើបអ្នកយាមឲ្យចេញទៅ ។

ជាង-កាន់ ក៏ឡើងជិះកូនទូក ត្រឡប់ទៅជាងប៉ីជួប ចាវ-ឆាវ វិញហើយនិយាយប្រាប់ថាៈ មនុស្ស ចូវ-យី នេះរឹងរូស និងឬកធំណាស់ មិនព្រមចុះចាញ់ទេ តែចាវ-ឆាវ ស្តីបន្ទោស ជាង-កាន់ ថាៈ ខ្វះសមត្ថភាព ហើយត្រូវ តុង-អ៊ូ ពេបជ្រាយថែមទៀត ។
ជាង-កាន់ និយាយៈ

-ពិតមែនតែមិនអាចបញ្ចុះបញ្ចូល ចូវ-យី ឲ្យចុះចូល តែក៏បានស៊ើបដឹងពីរឿងអាថ៌កំបាំង ដ៏សំខាន់មួយ ដែលទាក់ទងនឹងលោកឧបរាជដែរ សូមមេត្តា ឲ្យសេនាចេញក្រៅសិន។ ចាវ-ឆាវ ក៏ដេញសេនាឆ្វេងស្តាំឲ្យចេញទៅក្រៅអស់ បន្ទាប់មក ជាង-កាន់ ប្រគល់លិខិតដែលលួចបានឲ្យទៅ ចាវ-ឆាវ ហើយក៏រ៉ាយរ៉ាប់ប្រាប់រឿងរ៉ាវ ដែលបានជួបប្រទះ ។
អានលិខិតនេះចប់ ក្តៅឆេវតែម្តងៈ

-អាចោរក្បត់ទាំងពីរនាក់នេះ ពិតជាថ្លើមធំមែន អាមមាចមិនស្គាល់ភ្លើង ហ៊ានដាក់ផែនការ ធ្វើឃាតយើងផង! ក៏បញ្ជាឲ្យកាត់ក្បាល ចាង-យឹង,ឆាយ-មៅ ភ្លាមតែម្តង ជាបន្ទាន់។

ជាបន្ទាប់មកទៀត ចូវ-យី បន្តប្រើល្បិច"ដឹងតែពើធ្វើមិនដឹង" អនុវត្តល្បិច"ចារកម្មឡងទៅវិញ" ប្រើមេទ័ពដែលចុះចូល ឆាយ-ជុង និងឆាយ-ហឺ បញ្ជូនកិច្ចការសម្ងាត់មិនពិតឲ្យ ចាវ-ឆាវ ប្រើល្បិច "ឈឺសាច់" ឲ្យ វ៉ាំង-កាយ ទៅសុំចុះចូល ។ បញ្ជូន ផា-ថុង ចូលជ្រៅតំណាក់ ចាវ-ឆាវ
អនុវត្តល្បិច"ច្រេះស៊ីដែក" រួចឆ្លៀតពេលដែលខ្យល់ត្រូវធ្លាក់ពីទិសខាងកើត ភ្លើងមួយបាច់ដុតកំទេចកងទ័ព ចាវ-ឆាវ ឲ្យឆេះឆៀម
សក់រលួយមុខ បរាជ័យរត់ប្រាស់អាយុ ទៅកន្លែងគ្មានសល់ បរាជ័យយ៉ាងធ្ងន់ធ្ងរនៅ ឈឺពី។ ឆ្លងកាត់ការ ប្រយុទ្ធនេះ កម្លាំងទ័ពរបស់ចាវ-ឆាវ ត្រូវបាក់ស្រុតតែម្តង ហើយក៏គ្មានកម្លាំងវាយសម្រុកទៅភាគ ខាងត្បូងទៀតទេ នគរទាំង៣(សាមកុក) ដែលតែងប្រឈមមុខដាក់គ្នា ត្រូវសន្មត់ថា បានចាប់ផ្តើមរក្សា ភាពស្ងៀមស្ងាត់ ឬបញ្ចប់ត្រឹមពេលនោះឯង ។

# គ្មាន តែអាចបង្កើតឲ្យមាន

គ្មាន តែអាចបង្កើតឲ្យមាន និយាយឲ្យងាយស្តាប់គឺ៖ គ្មានខ្យល់តែមានរលក គ្មានរឿងតែអាចបង្កើតឲ្យមានរឿង។ គោលគំនិត គឺខ្លាចតែសង្គមមិនច្របូកច្របល់ ទិសដៅគឺឆ្លៀតឱកាសបន្លំចាប់ត្រី (ត្រីងៀតឆ្លៀតពង) ស្នាដៃ  គឺបង្កើតបញ្ហា ។

″ ប្រឌិតរឿង″មើលពីខាងក្រៅថាជាការងាយ តែចង់សំរេចគោលបំណងរបស់ខ្លួនដោយ″ប្រឌិតរឿង″ ពិតជាលំបាកណាស់។ ការ″ប្រឌិតរឿង″ តាមក្រឡុកក្រលៀនកៀនកោះផ្សារផ្សេា ឬឌីដង បើបានសម្រេចតាមក្តីបំណង សប្បាយបានមួយគ្រាដែរ តែលទ្ធផលនៃការប្រឌិតរឿងបែបនេះយ៉ាងច្រើនណាស់ធ្វើឲ្យគូសត្រូវ រងគ្រោះរបួសខូចខាតខ្លះៗតែប៉ុណ្ណោះ.....ហើយមិនប្រាកដ មានផលប្រយោជន៍ចំពោះខ្លួនទេ។ ការ″ប្រឌិតរឿង″ ដែលមានគោលបំណងច្បាស់លាស់ គ្មានផលប្រយោជន៍សម្រាប់ខ្លួនទេនោះ គឺមិនអាចរាប់ថា
ជា ″ ល្បិចកល ″  បានឡើយ។

សុភាសិតចិនមួយសរសេរថា៖″រឿងប្រឌិត ត្រូវបញ្ចប់ត្រឹមអ្នកចេះដឹង″ បានន័យថា: រឿងប្រឌិត ដែលគ្មានការរៀបចំផែនការឲ្យបានល្អិតល្អន់ និងគ្មានការប្រែប្រួលក្រឡាប់ចាក់ ដ៏ច្រើនលើសលុបទេនោះ ពិតជា គេចមិនផុតពីក្រសៃភ្នែករបស់អ្នកចេះបានឡើយ។ ដូច្នេះ គួរនិយាយថា:″រឿងប្រឌិត″ គឺបង្កើតដោយស្នាដៃ របស់អ្នកចេះ  ទើបត្រឹមត្រូវ។

″បង្កើតបញ្ហា″ បានន័យថា៖ គឺផ្អែកលើរឿងអ្វីមួយ ដែលមានស្រាប់ហើយពង្រីកការខុសនិងត្រូវ ឲ្យកាន់តែធំធេងឡើង តែអ្វីដែលចង់និយាយនៅក្នុងល្បិចកលនេះ គឺមិនចាំបាច់ផ្អែកលើបញ្ហាដែលមានពិត ឬយោងលើមូលដ្ឋានអ្វីទាំងអស់ តែអាចបង្កើតជាបញ្ហាបាន។

ឧទាហរណ៍៖ រឿងលេងហឹតុក្កតា មើលពីខាងក្រោមឆាកទៅ ហាក់បីដូចជានៅពីខាងក្រោយវាំងននបង្កប់ទៅដោយកងទ័ពរាប់ម៉ឺន សេះរាប់ពាន់ ទាញវាំងននចេញខ្វាក គឺឃើញតែមនុស្សម្នាក់ និងរូបតុក្កតាមួយចំនួន និងខ្សែទាញតែប៉ុណ្ណោះ ។

″ រឿងប្រឌិត″ ពិតជាគួរឲ្យភ័យខ្លាចជាងអ្វីទាំងអស់ វាគ្មានរូប តែអាចមើលឃើញ វាគ្មានស្រមោល តែអាចជួបប្រទះខុសឬត្រូវចេញតែពីមាត់ សំអាងលើសំដីតែប៉ុន្មានម៉ាត់ប៉ុណ្ណោះ អាចធ្វើឲ្យមនុស្សមើលស្រាល ជីវិត អ្នកក្លាហាន អាចដោះអាវគ្រោះចេញពីខ្លួន។

ក្នុងក្បួនយុទ្ធសាស្ត្របាននិយាយថា៖ ការវាយសម្រុកដោយប្រើ″រឿងប្រឌិត″ យ៉ាងប៉ិនប្រសប់មិនបាច់ ប្រយុទ្ធ ក៏ធ្វើឲ្យសត្រូវទម្លាក់អាវុធបានដែរ។ នៅក្នុងប្រវត្តិសាស្ត្រមានភស្តុតាងច្រើនណាស់ដែលបានបញ្ជាក់ បង្ហាញពីរឿងនេះ ដូចជា សង្គ្រាមនៅទ្វីបអ៊ឺរ៉ុប ក៏ធ្លាប់កើតមានដែរនោះគឺ ″ពាក្យប្រឌិត″ ទំលាយខ្សែការពារ ម៉ាទីណូ។

បើសិនជានិយាយថា(បង្កើតបញ្ហា) គឺធ្វើឲ្យសង្គមច្របូកច្របល់នោះ បានន័យថា៖ ″ ពាក្យប្រឌិត″ គឺជាប្រភពនៃការ ″ បង្កើតបញ្ហា ″ នេះឯង។ បើ″ ប្រឌិត″ ត្រូវចេះមើលកាលៈទេសៈ ត្រូវប្រឌិតឲ្យវាសមហេតុសមផលហើយទាមទារ ″ រហ័ស″ មិនត្រូវឆ្លងកាត់ពេលវេលាសាកល្បងវែងអន្លាយទេ ដែលនិយាយថា″ ជឿមិនជឿអាចសាកល្បងចំពោះមុខ ស័ក្តិសិទ្ធិថ្ងៃក្រោយទើបដឹង″ ។

ដល់ទៅថ្ងៃក្រោយ ទំរាំតែដឹងការពិត ខ្លួនយើង(បានឆ្លងផុតសមុទ្រក្លាយជាទេវតា) បាត់ទៅហើយ។ ឈិង-ស៊ឹន, អ៊ូ-ក្វាង ពេលចាប់ផ្តើមបំផុសចលនាប្រឆាំង បានប្រឌិតដោយប្រើប្រាស់រឿងខ្មោចព្រាយបិសាច ទៅអូសទាញចិត្តប្រជារាស្ត្រ គេយកក្រណាត់ដែលសរសេរថា″ ស្តេចឈឹង-ស៊ឺន″ ញ៉ាត់ចូលទៅក្នុងពោះត្រី គឺចង់បញ្ជាក់ថា វាជារឿងព្រហ្មលិខិត ហើយបានចាត់មនុស្សឲ្យក្លែងជាខ្មោច ពាក់កណ្តាលអាធ្រាតដើរ ស្រែកថា: មហារឈ្មួររុងរឿង (ដោយសារស្តេច ឈឹង-ស៊ឺន) ថែមទៀត រួចក៏អូសទាញបានប្រជាជនដែលជឿ អបិយជំនឿយ៉ាងច្រើន ឲ្យចូលរួមក្នុងចលនានេះ។

# គ្មានតែអាចបង្កើតឲ្យមាន

ចំណែកលីវ-ប៉ាង បានប្រឌិតរឿងដោយនិយាយថា: ខ្លួនបានសម្លាប់ស្តេច ស ហើយតាំងខ្លួនជាស្តេច ក្រហម និងនិយាយថែមទៀតថា: មានឆ្អឹងជាស្តេច។ របៀបនេះ ហើយក៏បោកប្រាស់ប្រជារាស្ត្រទាំងនោះឲ្យជឿ ស្លុងទាំងងងឹតងងុលរង់ចាំដល់ពេលកំលាំងធំធាត់រឹងមាំហើយ ក៏លោតភ្លែត ពីមនុស្សដែលចូលចិត្តស្រីស្រាគ្មានទីពឹង ឡើងភ្លែតអង្គុយលើរាជបល្ល័ងតែម្តង។

បើពិនិត្យតាមសាច់រឿង គ្មានអ្វីគួរឲ្យសង្ស័យទេថា: ក្រុម លីវ-ប៉ាង ។ល។ បានធំធាត់ឡើង ដោយសារតែផ្តើមចេញពីការ ″ ប្រឌិតរឿង″ តែប៉ុណ្ណោះ។ ពួកគេចេះប្រើឱកាសតាមទំនៀមទម្លាប់នាពេលនោះ។ បើឥឡូវនិយាយពីរៀងនេះ ពិតជាគួរឲ្យអស់សំណើចណាស់តែពួកគេបាន″ ឆ្លងសមុទ្រ″ រួចផុតទៅហើយ។ តែពេលនេះ បើមានអ្នកណាម្នាក់រៀនធ្វើតាមវិធីនេះសារឡើងវិញម្តងទៀតប្រហែលជាអាចត្រូវបញ្ជូនឲ្យចូលមន្ទីរពេទ្យឆ្កួតមិនខាន។ហេតុនេះត្រូវដឹងថា:ត្រូវប្រឌិតរឿងតាមកាលៈទេសៈ បើមិនមែនអ្នកចេះ

ឬអ្នកជំនាញទេ

មិនគួរប្រថុយអនុវត្តនោះទេ។

មានរឿង "គ្មានតែអាចបង្កើតឲ្យមាន″ មួយដែលអាចចាត់ទុកថាពីមុនកម្រនឹងជួបឥឡូវក៏

មិនដែលប្រទះ រឿងនោះគឺ៖

-ចាង-យី នាសម័យ ចាន់-គួក បានរៀន ″ វិធីរាតត្បាត″ មួយគម្ពីរ

បានដឹកនាំគ្នាមួយចំនួនរត់ទៅនគរឆ ដើម្បី

ស្វែងរកលាភសក្ការៈ ព្រោះតែរកខ្សែររយៈចូលគាល់ស្តេចមិនបាន ក៏ត្រូវរស់នៅទាំងត្រដរក្នុងនគរឆ

ជីវភាពយ៉ាប់

យឺនពេកក្រៃ អ្នកដែលរត់មកតាមជាមួយទ្រាំតទៅទៀតលែងបានហើយ ក៏រអ៊ូរទាំថា៖ចង់ត្រឡប់ទៅផ្ទះវិញ។ ឃើញបែបនេះចាង-យី ក៏និយាយទៅកាន់ពួកគេថាពួកឯងកុំបារម្ភអីគ្មានចោទបញ្ហាអ្វីទាំងអស់

ណែទ្រាំប៉ុន្មានថ្ងៃទៀតទៅ

មិនមែនយើងនិយាយអួតទេក្រោយពេលដែលយើងបានជួបស្តេចហើយធានាថាពួកឯងពិតជាស៊ីមិនអស់ផឹកមិនខ្វះ បើមិនដូចពាក្យយើងថាទេ ពួកឯងវាយឲ្យបាក់ធ្មេញមុខរបស់យើងតាមសប្បាយទៅចុះ។

ពេលនោះស្តេចឆ កំពុងតែពេញស្រឡាញ់ស្រីស្នំពីររូប ម្នាក់គឺណាន-ហ្វូវ ម្នាក់ទៀតគឺជឹន-ស៊ីវ ។

ថ្ងៃមួយចាង-យី ក៏បានជួបនិងស្តេចឆ តែស្តេចឆមិនពេញចិត្តនឹងគេទាល់តែសោះ។

ចាង-យីនិយាយ៖

-ទូលបង្គំមកដល់ទីនេះយូរណាស់ដែរ ហើយព្រះអង្គមិនប្រទានកិច្ចការអ្វីតិចតួចដល់ទូលបង្គំសោះ

ប្រសិនបើ

ព្រះអង្គពិតជាមិនពេញព្រះទ័យនឹងទូលបង្គំមែន សូមតែព្រះរាជានុញ្ញាតិឲ្យទូលបង្គំចាកចេញពីទីនេះទៅចុះ ទូលបង្គំនឹងទៅនគរជីនមួយជើងសាកមើលក្រែងលរទីនោះមានឱកាសគ្រាន់បើ។

-ល្អណាស់តាមចិត្តឯងចុះ!

ស្តេចឆរបន់ឲ្យគេចាកចេញភ្លាមៗកាន់តែឆាប់កាន់តែល្អក៏ឆ្លើយយល់ព្រមភ្លាមតែម្តង។

-ពិតហើយ ទោះបីទីនោះមានឱកាសក្តី ទូលបង្គំត្រូវតែត្រឡប់មកវិញម្តងទៀត តើព្រះអង្គ

ត្រូវការអ្វីពីនគរជីនខ្លះឬទេ?

ឧទាហរណ៍៖ -ផលិតផលពិសេសនៅទីនោះពេលត្រឡប់មកវិញទូលបង្គំនិងជួយនាំយកមកថ្វាយតែម្តង។

ស្តេចឆរ សម្លឹងមើលដោយមិនសប្បាយចិត្ត និយាយយ៉ាងសោះកក្រោះ.

-មាសប្រាក់កែវកង ភ្លុកដំរីស្នែងខ្លីង នគរយើងមានមិនខ្វះ

ចំពោះរបស់របរនគរជីនគ្មានអ្វីគួរឲ្យចាប់អារម្មណ៍ទេ ។

-ព្រះអង្គពិតជាមិនចូលចិត្តនារីរូបស្រស់នៅទីនោះមែនឬ? សំដី មួយម៉ាត់នេះដូចចរន្តអគ្គីសនីឆក់អារម្មណ៍ស្តេចឆ ភ្លាម ព្រះភ័ក្រដ៏តឹងតែង ក៏ស្រាប់តែធូរខ្យុយមកវិញ ព្រះនេត្រហាក់មានពន្លឺ។

# គ្មានតែអាចបង្កើតឲ្យមាន

ប្រញ៉ាប់សួរ៖

-ថាម៉េច ឯងនិយាយពីស្អីហ្នឹង?

-ទូលបង្គំនិយាយពីនារីរូបស្រស់នៅនគរជីន។ ចាង-យី
និយាយធ្វើឫកបែបត្រឹមត្រូវហើយថែមទាំងបរិយាយដោយ
វាសវៃ ផ្ការដៃផ្ការជើងធ្វើភ្នែកទៀតផង។

-អឺពិតជាប្លែកណាស់ ស្អាតអស្ចារ្យ នារីនៅនគរជីន នគរជីន សំបូរណាស់
នារីម្នាក់ណាដែលថាមិនស្អាត
ដូចទេពអប្សរនោះ? មុខឡើងក្រហមសាច់សររលោងឡើងខ្ចីសក់ខ្មៅភ្លឺរលើបដំណើរជាទីគយគន់
សំឡេងពីរោះជាង
កណ្តឹងមាសទៅទៀត បើសិនជាផ្ការនឹងផ្កា ផ្កាពិតជារុះរោយបើផ្ទរនិងខែ
ខែពិតជាអាប់រស្មី ស្អាត...ពិតជាស្អាតណាស់......។

ព្រះនេត្ររបស់ស្តេចឆវិលវល់ទៅមកតាមដៃរៀបរាប់របស់ ចាង-យី
សូម្បីតែមាត់ក៏បិទលែងជិតទៅហើយ
រួចព្រះអង្គមានបន្ទូល៖

-ត្រូវត្រូវ ពិតជាត្រូវ នគរយើងជាតំបន់ចុងកាត់មាត់ញកដាច់ស្រយាល
យើងក៏មិនធ្លាប់ជួបប្រទះក្មេងស្រីនគរ
ជីនដែរ កុំតែបានឯងរំលឹក កុំអីយើងពិតជាភ្លេចឲ្យឈឹងតែម្តង បើអីចឹងឯងប្រញ៉ាប់ទៅធ្វើកិច្ចការហ្នឹងទៅ
ទៅនាំយកផលិតផលពិសេសទាំងនោះ ត្រឡប់មកឲ្យយើងវិញកុំខាន។

-ក៏ប៉ុន្តែ.......។

-ចាំបាច់និយាយស្អី រឿងលុយកាក់ ចាំបាច់ត្រូវតែប្រើហើយ ។

ស្តេចឆ
ក៏ប្រទានប្រាក់កាសយ៉ាងច្រើនឲ្យទៅ ចាង-យី ហើយបញ្ជាក់ថា ប្រញ៉ាប់ទៅបំពេញកិច្ចការនេះឲ្យ
រហ័សរហួន។

ចាង-យី ក៏មានចេតនាផ្សព្វផ្សាយរឿងនេះ រឿងនេះក៏បានលេចឮដល់ស្នំណាន-ហ្វូវ និងជិន-ស៊ីវ
អ្នកទាំងពីរ
មានការបារម្ភយ៉ាងខ្លាំងក៏ប្រញ៉ាប់ប្រញ៉ាល់ ចាត់មនុស្សឲ្យទៅទាក់ទងចាង-យីប្រាប់ថា៖

-ពួកខ្ញុំឮថាលោកម្ចាស់ បានទទួលបញ្ជាពីព្រះអង្គទៅទិញទំនិញពិសេសពីនគរជីន
ទើបខ្ញុំស្ទាត់មកជួប
ដើម្បីជូនសោហ៊ុយខ្លះគ្រាន់ធ្វើដំណើរតាមផ្លូវ។ ហេតុនេះចាង-យី ក៏ក្បៀសបានមួយចំនួនទៀត។
ថ្ងៃនេះត្រូវដល់ពេលលាស្តេចឆ ចេញដំណើរហើយ
តែចាង-យីធ្វើឫកដូចជាមិនដាច់អាល័យទាល់តែសោះ រួចនិយាយថា៖

-ទូលបង្គំទៅនគរជីនលើកនេះ ផ្លូវវែងឆ្ងាយណាស់ដំណើរក៏មិនសូវស្រួល
មិនដឹងថាថ្ងៃណាទើបអាចត្រឡប់មកដល់វិញទេ
ហេតុនេះ សូមព្រះអង្គព្រះមេត្តាប្រទានស្រាដល់ទូលបង្គំពីរបីកែវគ្រាន់ជាការលើកទឹកចិត្ត !

-បាន! បាន! ស្តេចឆហៅគេចាក់ស្រាឲ្យយ៉ាងរួសរាន់។ ចាង-យី
ផឹកអស់ជាច្រើនកែវមុខឡើងក្រហម ឆ្លៀតឱកាសនេះ ក៏ធ្វើឫកធ្វើពារថ្វាយបង្គំស្តេចឆ រួចស្នើសុំម្តងទៀត៖

-ទីនេះគ្មានអ្នកផ្សេងហ៊ានសុំការយោគយល់ពីព្រះអង្គទេ
សូមព្រះអង្គមេត្តាហៅអ្នកជិតជិតបំផុត ជូនស្រាដល់ទូលបង្គំខ្លះទៀត ជាការលើកទឹកចិត្តបន្ថែមឲ្យកាន់តែ
ភ្លៀវភ្លា។

## គ្មានតែអាចបង្កើតឲ្យមាន

-មិនអីទេ គ្មានបញ្ហាឲ្យតែឯងឆាប់បញ្ចប់ភារៈកិច្ចទៅបានហើយ។
ដោយយល់មុខ″ទំនិញពិសេស″ ស្ដេចឆ ក៏បានហៅស្នំជាទីស្រឡាញ់ទាំងពីរឲ្យចេញមកចាក់ស្រា
ជូនដំណើរចាង-យី។

គ្រាន់តែក្រឡេកឃើញភ័ក្រភ្លាម សូម្បីតែស្រាក៏ចាង-យីលែងហ៊ានផឹកដែរ
គ្រឹបលុតជង្គង់មុខស្ដេចឆ ក្រាបក្បាល់
ដល់ដីហើយនិយាយថា៖

-សូមព្រះអង្គសម្លាប់ទូលបង្គំចុះ ទូលបង្គំបានបោកប្រាសព្រះអង្គហើយ។

-រឿងអីទៅ ? ស្ដេចឆ ភ្ញាក់ក្រញ៉ាង ។

ចាង-យី តប ៖

-ទូលបង្គំដើរមួយចំហៀងផែនដីទៅហើយ
មិនដែលឃើញស្រីណាស្រស់ស្អាតស្មើរនឹងស្នំឯករបស់ព្រះអង្គ
ទាំងពីរនាក់នេះទេ ពីមុនទូលបង្គំបាននិយាយថានិងទៅជួយទិញ ″ ទំនិញពិសេស″ នៅនគរជីន
ដោយហេតុពុំដែលឃើញស្នំឯកទាំងពីរឥឡូវដល់បានឃើញហើយយល់ថាគឺជាការបោកប្រាស់ព្រះអង្គ
ដូច្នេះទូលបង្គំគួរតែស្លាប់ !
ឮនិយាយបែបនេះ ទើបស្ដេចឆរ បន្ធូរខ្យល់ ហើយមានបន្ទូលទៅកាន់ ចាង-យីៈ

-យើងស្មានតែរឿងស្អី! បើអីចឹងឯង មិនចាំបាច់ចេញដំណើរទេ ហើយក៏មិនបាច់បន្ទោសខ្លួនឯងដែរ
យើងក៏ដឹងដែរ
ថាក្រោមមេឃលើដីនេះ ពិតជាគ្មាននារីណាស្អាតដូចស្នំសំឡាញ់យើងទាំងពីរនេះទេ មែនឬមិនមែន?
ហើយក៏មិុចភ្នែកធ្វើមុខដាក់ស្នំទាំងពីរណាន-ហូវនិងជីន-ស៊ីនក៏ញាក់ភ្នែកសងមកវិញហើយបញ្ចេញសូរស័ព្ទៈ

-អ៊ឺ!

ចាប់ពីពេលនោះមកស្ដេចឆ ក៏បានផ្លាស់ប្ដូរឥរិយាបថចំពោះចាង-យី។
ចាង-យីក៏បានរស់នៅយ៉ាងសុខសាន្តតរៀងទៅ ៚

# ត្រីងៀតឆ្លៀតពង

ភ្លើងឆេះឆ្លៀតឆក់ប្លន់(ឬត្រីងៀតឆ្លៀតពង) មានមធ្យោបាយពីរបែបមួយគឺ ឆ្លៀតភ្លើងកំពុងតែឆាបឆេះ ធ្វើការឆក់ប្លន់ មួយទៀតគឺ ដុតភ្លើងឲ្យឆេះជាមុន ទើបធ្វើការឆក់ប្លន់តាមក្រោយ។ ឆ្លៀតឱកាសភ្លើងកំពុងតែឆាបឆេះ ហើយធ្វើការឆក់ប្លន់ គឺឆ្លៀតពេលដែលអ្នកដទៃកំពុងជួបគ្រោះអាសន្ន ទៅស្វែងរកលាភឬហៅថា៖ ត្រីងៀតឆ្លៀតពង ចំណែកដុតភ្លើងឲ្យឆេះជាមុន ហើយធ្វើការឆក់ប្លន់តាមក្រោយ គឺជាអំពើដែលប្រព្រឹត្តផ្ទាល់ដៃ ខ្លួនជាចោរ ហើយស្រែកឲ្យគេជួយចាប់ចោរ ដើម្បីសម្រេចនូវគោលបំណងឆក់ប្លន់របស់ខ្លួន។

មិនថា(ឆ្លៀតពេលភ្លើងឆេះ) ឬក៏(ដុតភ្លើងឆេះ) គឺមានគោលបំណងដូចគ្នា គឺឆក់ប្លន់អ្នកដទៃ ដើម្បីបំពេញតម្រូវការខ្លួន។ ឆ្លៀតពេលភ្លើងឆេះ បានន័យថា ៖ មិនមែនជាអំពើដែលប្រព្រឹត្តិផ្ទាល់ដៃ សកម្មភាពបែបបេះ គឺបិតក្នុងលក្ខណៈឆ្លៀតឱកាស ទង្វើឆ្លៀតឱកាស គឺពុំមែនជាអំពើរបស់កូនប្រុសឡើយ ចំពោះកូនប្រុសដើមទ្រូងប្រាំហត្ថ ធ្វើកិច្ចការអ្វីក៏ដោយ ត្រូវតែឈរលើជំហរម្ចាស់ការជានិច្ច។ ការរង់ចាំឲ្យអ្នកដទៃទៅបង្កើតឱកាសឲ្យខ្លួន វាមិនប្រសើរជាជាងការបង្កើតឱកាសឲ្យខ្លួន ដោយខ្លួនឯងនោះទេ ឬក៏ប្រើអ្នកដទៃទៅ បង្កើតឱកាសឲ្យខ្លួន។ និយាយរួម ដុតភ្លើងឲ្យឆេះ ឬឆ្លៀតពេលភ្លើងឆេះ
តែងជាអំពើដែលយកផលប្រយោជន៍របស់ខ្លួន
ទៅកសាងនៅលើទុក្ខវេទនារបស់អ្នកដទៃជានិច្ច។
វីរៈបុរសក្នុងប្រវត្តសាស្ត្រចិន អ្នកដែលរាប់ថាពូកែខាងដុតភ្លើងគឺចាង-យី អ្នកពូកែឆក់ប្លន់គួរតែដូច ខុង-ម៉េង, ចាង-យី
អាចរាប់ថា៖ ជា(សត្វអគ្គី) មួយជីវិតប្រព្រឹត្តរបស់គេ គឺពូកែខាងដុតរោល។ ដើម្បកំទេចផែនការ(សម្ព័ន្ធភាព) នគរទាំង
ប្រាំមួយ ចាង-យី ឲ្យតែទៅដល់ទីណា ទីនោះពិតជាត្រូវតែមានភ្លើងឆេះ ចាង-យី បោកប្រាសនគរឈី,ឆរ នគរឈ្យូ,ភរ
នគរយាន,បំភ័យនគរចាវ,គំរាមនគរហាង,កុហកនគរឃ្មួយ, គ្រាន់តែសំអាង លើ(អណ្តាតភ្លើង)
របស់ខ្លួនប៉ុណ្ណោះ ធ្វើឲ្យ
ស្តេចនគរទាំងប្រាំមួយនេះ ឆេះឆ្មៀមសក់រលួយមុខបរាជ័យ យ៉ាងជូរចត់។ បានជួយស្តេចឈីន
ធ្វើការឯកភាពប្រទេសចិន
នាសម័យនោះ។

ខុង-ម៉េង (ជូកឺលៀង) ពិតមែនតែត្រូវផ្តល់កេរ្តិ៍ឈ្មោះថាជាអ្នកនយោបាយដ៏កំពូល តែទុននយោបាយនៃការចាប់ផ្តើម
របស់គាត់ គឺបានមកពីការ(ឆក់ប្លន់) ប៉ុណ្ណោះ។ ឆ្នាំនោះ ខុង-ម៉េង ត្រូវ ចាវ-ឆាវ ដេញដល់ទីទាល់ច្រកហើយក៏រត់ទៅ
ជ្រកកោនជាមួយស៊ុនឈាន បន្ទាប់មកបានអុចអាលឲ្យមានសង្គ្រាមភាគខាងត្បូងនិងភាគខាងជើង ហើយឆ្លៀតពេល
ដែលចូវ-យី ដុតកំទេចឈឺពី(ទីក្រុងមួយ) និងពេលដែលចាវ-ឆាវ កំពុងរត់ប្រាស់ អាយុ ខុងម៉េង ក៏ឆ្លៀត (ប្លន់) យកខេត្ត
លី-ចូវ, ឆាង-សា, វូ-ជីន, កួយ-យ៉ាង, លីង-ជីងា ។ល។ ធ្វើឲ្យចូវ-យីង ខឹងដាច់ក្បាលដាច់កន្ទុយ។
ដូច្នេះយើងថា អំពើ(ឆ្លៀតឱកាសភ្លើងកំពុងឆេះដើម្បីឆក់ប្លន់) ពិតជាមធ្យោបាយដ៏ចាំបាច់ដែលអាចកសាងនឹងសម្រេច

ត្រីវៀតផ្ដៀតពង
កិច្ចការធំៗបាន។ រាប់ពាន់ឆ្នាំកន្លងទៅ ចាប់ពីរជ្ជកាលចូវមក តើមានស្ដេចអង្គណាដែលថា
មិនពឹងលើការ(ប្លន់) ដើម្បី
កសាងរាជបល្ល័ង្គខ្លួននោះ? ប្លន់បានល្អ ក្លាយជាស្ដេច ជាព្រះរាជា ប្លន់បែបល្ងង់ខ្លៅ នឹងក្លាយជាជនក្បត់
ជាចោរព្រៃ
នេះហើយហៅថា ចាញ់ជាកញ្ជះ ឈ្នះជាចៅហ្វាយ គឺចង់ចង្អុលសំដៅលើលទ្ធផលនៃ
សកម្មភាពឆក់ប្លន់នេះឯង។
ហេតុតែអ្នករៀនសូត្រ ស្លាប់មិនបានស្រណុក ពីព្រោះមកតែពីភ្នែករបស់គេភ្លឺថ្លាហួសហេតុ ទីនេះគ្មានពួកគេ
អ្នកដែលប្លន់ធំ
និងមានកិត្តិយសធំ ដើម្បីទប់ទល់ នឹងការឆក់ប្លន់របស់អ្នកដ៏ទៃចំពោះខ្លួន
ក៏ចេញច្បាប់ដើម្បីការពារប៉ុណ្ណោះ។ បើតាមពាក្យ
សំដីមួយឃ្លា ដែលសៀវប៉ែកណាក់និយាយបញ្ជាក់ គឺថាៈ ចក្រពត្តិនិយម អាចធ្វើអំពើល្អ
តែក៏អាចធ្វើអំពើអាក្រក់ដែរ តែជានិច្ច
ជាកាលគឺមិនធ្វើអំពើឲ្យខុសនោះទេ ពីព្រោះទោះគេធ្វើកិច្ចការអ្វីក៏ដោយ តែងមានគោលការណ៍របស់វា
គេវៃយើងដោយផ្អែក
លើគោលការណ៍ អាណានិគម!
យល់នូវចំនុចអស់នេះ ពិតជាអាចយល់យ៉ាងច្បាស់នូវអត្ថន័យនៃពាក្យ (ឆក់ប្លន់) បានគ្រប់
គ្រាន់ហើយ។
(ប្រវត្តិពិត) ឆ្នាំចុងក្រោយនៃរជ្ជកាលម៉េង-លីវ វាយសម្រុកចូលរាជធានី ស្ដេចចុង-ជិន
បានចងករសម្លាប់ខ្លួននៅ
ភ្នំមៃសាន លី-ជីសេង បានគ្រប់គ្រង និងប្លន់យករាជតំណាក់ រួចក៏តាំងខ្លួនថាជាស្ដេច ចាប់បាន
ឈឹង-យានយាន ដែលជា
ប្រពន្ធរបស់មេទ័ពម៉េង ឈ្មោះអ៊ូ-សានក្វយ ព្រមទាំងគំរាមឪពុកអ៊ូ-សានក្វយ
ឲ្យបញ្ចុះបញ្ចូល អ៊ូ-សានក្វយ ឲ្យចុះចាញ់ ។
អ៊ូ-សានក្វយ ជាមេទ័ពនគរម៉េងដ៏ល្បីល្បាញ ទទួលបញ្ជារការពារព្រំដែន
ការពារការឈ្លានពានរបស់ពួកជនជាតិម៉ាន់(ដែល
យើងទម្លាប់ហៅថាម៉ានជូ) ថ្ងៃនេះទទួលបានសំបុត្ររបស់ឪពុក ដឹងថាទ័ពម៉េងទទួលការ បរាជ័យទៅហើយ
ក៏មានបំណង
សុំចុះចាញ់ដែរ កំពុងតែសរសេរសាសុំចុះចាញ់ ស្រាប់តែ ឮសេនា ឆ្វេងស្ដាំស្រែកប្រាប់ថា
មានក្មេងមកពីរាជធានី។
សានក្វយ ក៏ហៅឲ្យចូលមកជួបភ្លាម ហើយប្រញាប់សួរៈ
-លី-ជីសេង បានវាយចូលរាជធានី តើផ្ទះសំបែងរបស់យើងយ៉ាងម៉េចហើយ?
ក្មេងឆ្លើយៈ
-ត្រូវរឹបអូសអស់ហើយ។
សានក្វយមិនចាប់អារម្មណ៍ទេ ក៏និយាយបន្តៈ
-មិនអីទេ ចាំដល់ពេលយើងត្រឡប់ទៅវិញ គេនឹងប្រគល់ឲ្យយើងវិញហើយ ចុះឪពុកយើង
គាត់យ៉ាងម៉េចដែរ?
-ត្រូវឃុំខ្លួនហើយ? ក្មេងឆ្លើយ.
-ក៏គ្មានបញ្ហាដែរ ថ្ងៃក្រោយគង់តែត្រូវដោះលែងទេ ។

ត្រីរង្វៀតឆ្លៀតពង

សាន-ក្វយនៅតែនិយាយរបៀបធម្មតា:

-ចុះចំណែកប្រពន្ធយើងវិញ ?

សំនួរនេះក្មេងត្រូវសួរឲ្យភាំងតែម្តង នៅអេះអុញនិយាយមិនចេញ ឃើញសភាពបែបនេះ សានក្វយក៏កើតការសង្ស័យ

ហើយប្រញាប់សួរដេញដោលៈ

-នាងយ៉ាងម៉េចហើយ ឯងនិយាយមកចុះ យើងមិនបន្ទោសឯងទេ ក្មេងក៏ប្រាប់:

-អ្នកស្រីត្រូវ លី-ជីសេង ដណ្តើមយកទៅបាត់ហើយ។

-អាថោកទាប! សានក្វយបោះជក់ប្រុសទៅដី ទាញដាវចេញខ្វាកពោរពេញដោយកំហឹង កាប់ផ្ទងឮស្វូ(ផែស) ជ្រុងតុមួយត្រូវកាប់ឲ្យដាច់ រួចហើយក៏ស្រែកជេរតែម្តង:

-គំនំធំបែបនេះ ម្តេចមិនសងសឹក? សម្លាប់ លី-ជីសេង មិនបានយើងពិតជាពុំមែនជាកូនប្រុសទេ។

តាមកំហឹង សឹងថាទៅប្រយុទ្ធប្តូរស្លាប់រស់ជាមួយ លី-ជីសេង ភ្លាមតែម្តង តែដោយកម្លាំងខ្សោយទ័ពនៅតិច ក៏មិនហ៊ានធ្វើអ្វីផ្តេសផ្តាស។

ស្របពេលជាមួយគ្នានោះ ស្តេចស៊ុន-ជី នៃនគរម៉ាន់ឆេង ទើបឡើងគ្រងរាជ្យ ដោយមូលហេតុទើបមាន

៧ព្រះវស្សា ដូច្នេះរាល់កិច្ចការតូចធំរបស់នគរ ត្រូវប្រគល់ឲ្យលោកម្ចាស់ តួ-អឺអាយ ជាអ្នកសម្រេច តួ-អឺអាយ ឃើញប្រទេសចិនមានសភាពច្របូកច្របល់ជាច្រើនឆ្នាំមកហើយ តែងមានបំណងចូលឈ្លានពាន តែទាស់ត្រឹមអ៊ូ-សានក្វយនៅការពារព្រំដែន ហេតុនេះ ក៏នៅសម្ងំស្ងៀមមិនហ៊ានធ្វើ អ្វីផ្តេសផ្តាស។

ពេលនេះក្នុងចិត្ត អ៊ូ-សានក្វយ ប្រញាប់ចង់សងសឹកខ្លាំងណាស់ ក៏សំរេចចិត្តថា នឹងទៅខ្ចីកងទ័ពឆេង ឲ្យជួយ លែងខ្វល់ថាអ្នកណាជាមិត្តឬក៏ជាសត្រូវអីទៀតហើយ រួចក៏ចេញដំណើរទៅជួប តួ-អឺអាយ ផ្ទាល់តែម្តង។ តួ-អឺអាយសួរៈ

-លោកមេទ័ពអញ្ជើញមកដោយផ្ទាល់ តើមានកិច្ចការអីជួយណែនាំឬ?

មិនឲ្យវែងឆ្ងាយទេ អ៊ូ-សានក្វយ និយាយត្រង់តែម្តង:

-នគរម៉េង និងនគរឆេង ធ្លាប់រស់នៅដោយសុខសាន្ត ជាអ្នកជិតខាងគ្នាយូរយាណាស់មកហើយ ឆ្នាំមួយនោះ នគរឆេងមានសង្គ្រាមផ្ទៃក្នុង នគរម៉េងក៏ធ្លាប់បានផ្តល់ទ័ពឲ្យជួយដែរ

ពេលនេះនគរម៉េងជួបគ្រោះ

អាសន្ន ចោរព្រៃរាតត្បាតគ្រប់ទីកន្លែង រាជធានីត្រូវទទួលរងគ្រោះ ព្រះរាជាត្រូវធ្វើអត្តឃាត គំនុំនេះ មានទំហំធំប៉ុនមេឃ

តែពេលនេះនគរយើងនៅសល់ទ័ពតិច បញ្ហាការក៏ខ្សត់

ចង់វាយបកទៅលើពួកចោរព្រៃវិញ តែគ្មានលទ្ធភាព

ដូច្នេះ សូមយល់ក្នុងនាមជានគរជិតខាង សូមលោកមេត្តាជួយផ្តល់ទ័ពឲ្យជួយផងចុះ។

ឮសំដីបែបនេះ ពិតជាត្រូវចំនុចដែលខ្លួនគិត លួចសប្បាយក្នុងចិត្តឥតឧបមា គិតថា ពិតជាឱកាសដែលមិនងាយនឹងជួប ក្នុងចិត្តពិតមែនតែគិតបែបនេះ តែមាត់បែរជាបដិសេធ ជ្រួញចិញ្ចើមទើបនិយាយ:

-នគរលោកម្ចាស់កើតសង្គ្រាមផ្ទៃក្នុង ក្នុងនាមនគរជិតខាងយើងគួរតែជួយ ប៉ុន្តែនគរយើងតូច កងទ័ព យើងតិច

យើងយល់ថា ពិតជាមិនអាចជួយអ្វីដល់លោកបានទេ ថាមិនត្រូវ ថ្ងៃក្រោយបែរជាត្រូវមានបញ្ហាចំពោះនគរខ្លួនទៀតផង រឿងនេះពិតជាគួរឲ្យសោកស្តាយណាស់ ព្រោះយើងមានបំណងជួយដែរតែគ្មានសមត្ថភាព។ អ៊ូ-សានក្វយនិយាយ:

-រឿងនេះ មិនចាំបាច់បារម្ភដល់ម្លឹងពេកទេ ពួកចោរព្រៃពិតមែនតែមានគ្នាច្រើន ច្រើនតែមនុស្ស តែមិនប្រយោជន៍ទេ ឲ្យតែលោកយល់ព្រមផ្តល់ទ័ពជួយ រឿងអីដែលថាមិនទទួលបានជោគជ័យ ។

តែទោះជាយ៉ាងណាក៏ តូ-អ៊ីអាយ នៅតែមិនយល់ព្រមដែរ។ ទោះបីជា អ៊្វ-សានក្វយ អង្វរម្ដងហើយម្ដងទៀតយ៉ាងណាក្ដី តូ-អ៊ីអាយ នៅតែធ្វើមិនដឹងមិនឮ ជជែកពិភាក្សា ពិភាក្សាជជែក ថ្ងៃណាក៏មិនបានលទ្ធផល។ ដឹង អីតូ-អ៊ីអាយ បានរៀបចំទ័ពជាសម្ងាត់ ត្រៀមខ្លួនដើម្បីចេញប្រយុទ្ធជាស្រេចរៀបចំផែនការប្រយុទ្ធបានចប់សព្វគ្រប់ហើយ ទើបធ្វើបែបជាទើបភ្ញាក់រលឹកហើយ ប្រាប់អ៊្វ-សានក្វយថា៖

-បើលោកមេទ័ពមានសំណូមពរ ឲ្យជួយបែបនេះហើយ នគរយើងក៏មិនអាចមិនបង្ខំចិត្តទទួលយក
ការលំបាកនេះដែរ យើងនឹងឲ្យទ័ពចេញជួយ។

-អ៊្វ-សានក្វយ ឮនិយាយបែបនេះ សប្បាយចិត្តពេកក្រៃ អរគុណដ៏ជ្រាលជ្រៅបំផុតចំពោះតូ-អ៊ីអាយ
ដែលបានជួយផ្ដល់ជំនួយនេះ ហើយក៏ប្រមែប្រមូលកងទ័ពដែលសេសសល់របស់ខ្លួន
រួមកម្លាំងគ្នាវាយសម្រុកចូល តាមច្រកព្រំដែន សាន-ហាយ ហើយធ្វើដំណើរសំរុកទៅមុខតែម្ដង។

ធ្វើដំណើរមកដល់វាលថ្មមួយកន្លែង
ក៏ទើបប្រទះប្រយុទ្ធជាមួយកងទ័ពក្បត់ទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ
ក្នុងប៉ុន្មានប៉ុណ្ណោះ ក៏វាយសម្រុក ចូលដល់រាជធានី លី-ជីសេង ក៏បោះបង់រាជធានីចោល ហើយរត់គេចខ្លួនកងទ័ពឆេងក៏ដណ្ដើមយកបានរាជតំណាក់ ហើយក៏តាំងខ្លួនធ្វើជាស្ដេចតែម្ដង ចាប់ពីពេលនោះមក ទឹកដីដ៏ល្អផូរផង់ត្រូវធ្លាក់ក្នុងកណ្ដាប់ដៃរបស់ជនជាតិម៉ាននាពេលនោះតែម្ដង។

បង្ក្រាបពួកចោរព្រៃអស់ហើយ កងទ័ពឆេង ក៏បង្វែរលំពែងមកចាក់សម្លាប់ទ័ពម៉េង
និងមន្ត្រីម៉េងវិញម្ដង
ធ្វើការសម្លាបរង្គាលនៅ យ៉ាងចូរ លាងឈាម នៅជាទីង ចំពោះមន្ត្រីម៉េងដែលសេសសល់ អ្នកដែលត្រូវទិញទឹកចិត្ត គឺទិញទឹកចិត្ត អ្នកដែលត្រូវសម្លាប់ គឺសម្លាប់ ប្រជាជនចិនដែលជួបប្រទះភាពខ្លោចផ្សា
និងពាក់លីជីវិត យ៉ាងសន្ធឹកសន្ធាប់នាសម័យនោះ ពិតជាមិនដែលមានក្នុងប្រវត្តិសាស្ត្រចិនកន្លងមកឡើយ៕

# វាយពីលិច បញ្ឆោតពីកើត

ការប្រើល្បិចដើម្បីឈ្នះ នៅក្នុងក្បួនយុទ្ធសាស្ត្រ បានសរសេរថា៖˝ ប្រកាសថាវាយពីកើត តាមពិតគឺវាយពីលិច˝ គោលបំណងរបស់វា នៅត្រង់បង្វែរគោលដៅរបស់សត្រូវ ធ្វើឲ្យសត្រូវធ្វេសប្រហែល ខ្វះការប្រុងប្រយ័ត្ន រួចធ្វើការវាយសម្រុក នៅពេលដែលសត្រូវគ្មានការការពារ និងនឹកស្មានមិនដល់។ ចំពោះ កិច្ចការអ្វីមួយក៏ដោយ ដើម្បីកំចាត់ចោលកម្លាំងរាំងចំពោះមុខ បន្ថយនូវការខូចខាតរបស់ខ្លួន ត្រូវតែរិះរកមធ្យោបាយ បំបែកកម្លាំងសត្រូវកុំឲ្យប្រមូលផ្តុំបាន ឬធ្វើឲ្យឆន្ទះថយចុះ ទើបអាចឆ្លៀតឱកាសវាយសម្រុក សំរេចជោគជ័យតាមគោលបំណង ។

ល្បិចកលហ៍នេះ មានមធ្យោបាយច្រើនបែបណាស់ ឬមួយក៏ប្រឌិតពាក្យមិនពិត បង្កើតពាក្យចរចាម អារាម បង្កើនភាពខ្លាចរអាររបស់សត្រូវចំពោះយើង ធ្វើឲ្យឆន្ទះច្របូកច្របល់ ឬក៏ចេតនារៀបចំក្បួនវាយលុក ធ្វើឲ្យ កម្លាំងរបស់សត្រូវបែបខ្ញែក កាត់បន្ថយការការពារ តែរាល់សកម្មភាពនិងគោលបំណងរបស់ខ្លួន ត្រូវលាក់ការណ៍ឲ្យជិតបំផុត រាល់ពេលវេលា ត្រូវតែបិតក្នុងភាពម្ចាស់ការជានិច្ច។(លាក់ការណ៍និងម្ចាស់ការ) គឺជា គោលការណ៍ចាំបាច់បំផុតក្នុងការអនុវត្តកិច្ចការ មិនចេះលាក់ការណ៍ បានន័យថា មិនចេះការពារខ្លួនឯង ឲ្យតែហ៊ានកម្រើកខ្លួនបន្តិច ពិតជាត្រូវទទួលការគៀបសង្កត់ភ្លាម ទោះជានៅក្នុងសមរភូមិប្រយុទ្ធ ក្នុងសមរភូមិ ពាណិជ្ជកម្ម ក្នុងកិច្ចការនយោបាយ ឬក៏ក្នុងជីវិតរស់នៅរបស់មនុស្សក្តី ល្បិចថា វាយពីកើតហើយវាយពីលិចនេះ គោលបំណងរបស់វាគឺការបញ្ចៀសភាពធ្ងន់ធ្ងរ ទទួលយកនូវភាពធូស្រាល រឿងបែបនេះ ពេលណាក៏អាចជួបប្រទះ  ទីណាក៏អាចអនុវត្តបាន  តែក៏មានអ្នកខ្លះ  អនុវត្តទៅបែរជាស្រោចគល់ទៅវិញ។

សម័យចាន់-គួក  នគរជាច្រើនធ្វើសង្គ្រាមជាមួយគ្នាមុន គ.ស ៤៧៥ ដល់ គ.ស ២២១ នគរឈីមានឧបរាជមួយរូបឈ្មោះ ម៉ឹង-ឆាងជីង ក្រោយពីបានរត់គេចខ្លួនចេញពីការឃុំឃាំងរបស់នគរឈីនស្តេចឈីន បានប្រឌិតពាក្យមិនពិតផ្សព្វផ្សាយថា៖ ឧបរាជម៉ឹង ចង់ដណ្តើមអំណាចពីស្តេចឈីស្តេចឈី ស្មានថាជាការពិត ក៏បានដកសិទ្ធិពីឧបរាជរូបនេះ ហើយនិរទេសខ្លួនឲ្យទៅរស់នៅស្រែចំការកូនចៅលោឧបរាជម្នាក់ឈ្មោះ ហ្វឹង-នៀន គឺជាមនុស្សដែលសម្បូរទៅដោយល្បិច មានបំណង ទាមទារនាទីឧបរាជអោយលោកម្ចាស់ម៉ឹងវិញ ក៏រត់ទៅនគរឈីនសុំគាល់ស្តេចឆាវ ហើយទូលថា៖ លោកឧបរាជ ម៉ឹង ត្រូវដកហូតតំណែងហើយ ព្រះអង្គគួរតែយកមនុស្សនេះមកប្រើប្រាស់។ ស្តេចឈីនឮហើយត្រេកអរណាស់ ក៏ចាត់មនុស្សអោយទៅទទួលលោកម៉ឹងដោយសំងាត់ ហ្វឹង-នៀនក៏ផ្ញើដំណឹងនេះអោយលោកម្ចាស់ម៉ឹងបានដឹង ដើម្បីត្រៀមខ្លួនជាមុន ហើយក៏ត្រឡប់ទៅនគរឈីវិញ សុំចូលគាល់ស្តេចឈីម្តងទៀត រួចទូលថា៖ ក្រាបទូលព្រះអង្គ នគរឈីនបានចាត់មនុស្សឲ្យមកទទួលលោកម្ចាស់ម៉ឹង ជាសម្ងាត់ហើយ បើមនុស្សនេះក្លាយជាមន្ត្រីរបស់នគរឈីន ពិតជាមានផលអាក្រក់ចំពោះនគរយើងខ្លាំងណាស់។ ឮបែបនេះ ស្តេចឈី ក៏ចាត់កម្លាំងឲ្យទៅស៊ើបការមើល តើរឿងនេះពិតឬមិនពិត?

គឺពិតជាមានរឿងបែបនេះមែន

នឹកឃើញពី ទេពកោសល្យរបស់មនុស្សនេះ ពិតជាមិនត្រូវឲ្យសត្រូវយកទៅប្រើប្រាស់ឡើយ ហើយក៏សួរទៅលោក ហ្វឹង-នៀន  ថាតើគួរធ្វើយ៉ាងម៉េច?

ហ្វឹង-នៀន  ក៏ប្រាប់:

-ជាការងាយទេ ប្រគល់តំណែងអោយគេវិញទៅជាការស្រេច បន្ថែមអំណាចខ្លះទៀត ដើម្បីពង្រឹងទឹកចិត្តឲ្យគេហ្នឹង គាត់ជាជនជាតិយើង ហើយជាខ្សែរលោហិតក្សត្រទៀត ជឿថាដាច់ខាតមិនសុខចិត្តទៅបំរើសត្រូវឡើយ។

# វាយពិលិច បញ្ឆោតពីកើត

ព្រះសណ្ដាប់ទៅ ក៏យល់ថាសមហេតុផលដែរ ក៏យល់ស្របតាមយោបល់លោកហ្វឹង-នៀន រួចស្ដេច ឈី ក៏ចេញរាជបញ្ជា ប្រគល់តំណែងឧបរាជដល់លោកម្ចាស់ម៉ឹងភ្លាមតែម្ដង។

ល្បិចកលនេះ ពិតជាធ្វើបានល្អណាស់ តែសំដីប៉ុន្មានម៉ាត់របស់ហ្វឹង-នៀន ប៉ុណ្ណោះ អាចធ្វើឲ្យលោក ម៉ឹង-ផានជីង ដែលកំពុងបិតក្នុងគ្រោះកាច ក្លាយមកទទួលបានជោគល្អវិញយ៉ាងងាយ។

មានរឿងនិទានមួយទៀតរឹតតែពិសេស នោះគឺរឿង (ឈឺន-ផឹង រកវិធីរំដោះ លីវ-ប៉ាង) ។

(ប្រវត្តិពិត) លីវ-ប៉ាង និង ស៊ាង-យី ចែកផ្លូវគ្នាវាយសម្រុកចូលក្រុងហាន់យ៉ាង នៅចំពោះមុខទាំងអស់គ្នាស្ដេចឈ្យូបានប្រកាសថា៖ អ្នកដែលវាយចូលដល់ក្រុងមុនគេ ត្រូវប្រទានតំណែងជាស្ដេច។ លីវ-ប៉ាង បានវាយចូលទៅដល់មុន តែអំណាចធំ បែរជាធ្លាក់ទៅក្នុងកណ្ដាបើដៃរបស់ស៊ាង-យីទៅវិញ ចំណែកខ្លួនបែរជាត្រូវទទួលការ កៀបសង្កត់ ផ្លាស់ប្ដូរការប្រទាន ដោយតែងតាំង លីវ-ប៉ាងជាស្ដេច ហាន-ជុង ប្រចាំការនៅណានជីន(ខេត្តស៊ានស៊ី)។

មន្ត្រីហ្វាន់ជីន ពិតជារអារនឹងលីវ-ប៉ាងណាស់ ច្រើនដងហើយដែលរកមធ្យោបាយសម្លាប់ លីវ-ប៉ាងចោល បានរកលេសមិនឲ្យពេលនេះលីវ-ប៉ាង ទៅទទួលតំណែងនៅ ហាន-ជុង បានឡើយ ដោយទុកលីវ-ប៉ាង នៅហាន់-យ៉ាង យកលេសថា៖ នៅជួយកិច្ចការសិន ការពិតគឺជាការឃុំខ្លួនដោយវិធីត្រជាក់ ប៉ុណ្ណោះ។

ឯលីវ-ប៉ាង វិញពិតជាប្រញ៉ាប់ចង់គេចចេញពីមាត់ខ្លានេះខ្លាំងណាស់ ក៏សួរចាងលៀងថា៖ មានមធ្យោបាយអី ចាងលៀងក៏រត់ទៅរក ឈីន-ភីង,ឈីន-ភីង ក៏ខ្សឹបដាក់ត្រចៀក ចាងលៀង,ចាងលៀង ស្ដាប់បណ្ដើរងក់ក្បាល

បណ្ដើរ ទះដៃហើយសើច លើកមេដៃឡើងហើយសរសើរថា៖ ពិតជាល្បិចពិសេសមែន។

ស្អែកឡើងឈីន-ភីង ថ្វាយយោបល់ទៅស៊ាង-យី ថា: ឲ្យចាត់ហ្វាន់- ចឹន ទៅកាន់ក្រុង ភឹន-ឈឹង បង្ខំឲ្យ ស្ដេចវ៉ៃ ប្រញ៉ាប់រើទៅនៅលីង-ចូវ។ មុនធ្វើដំណើរ ហ្វាន់-យ៉ាង បានផ្ដែផ្ដាំបញ្ហាបីដល់ស៊ាង-យី ទី១, មិនត្រូវចាកចេញពីហាន់-យ៉ាង ទី២,ប្រើប្រាស់ហាង-ស៊ឹង ឡើងវិញ បើមិនប្រើត្រូវសម្លាប់ចោល មិនត្រូវអោយអ្នកដ៏ទៃយកទៅប្រើប្រាស់ជាដាច់ខាត ទី៣,មិនត្រូវអោយ លីវ-ប៉ាង ត្រឡប់ទៅហាន-ជុងវិញទេ។ ស៊ាង-យី ទទួលយល់ព្រមហើយទើប ហ្វាន់-ចឹន ចេញដំណើរ ។

រំលងមិនយូរប៉ុន្មាន ឈីន-ភឹង ឡើងមានយោបល់ម្ដងទៀត និយាយថា៖

សេដ្ឋកិច្ចរបស់នគរកំពុងតែមានការខ្វះខាត បច្ចុប្បន្ន កងទ័ពដែលប្រចាំការនៅហាន់-យ៉ាង នេះមានរាប់សិបម៉ឺននាក់នៅដេកស៊ីគ្មានការងារធ្វើ យកល្អគួរតែអោយរាល់ស្ដេចក្រាញ់ទាំងអស់វិលត្រឡប់ទៅកន្លែងដើមគ វិញ ធ្វើបែបនេះ ទើបអាច កាត់បន្ថយនូវការចំណាយបាន........។

ស៊ាង-យី យល់ព្រម ហើយក៏ចេញបញ្ជា អោយស្ដេចក្រាញ់ទាំងអស់ដែលទើបតែងតាំងថ្មី កំណត់រយៈពេលប្រាំថ្ងៃយ៉ាងយូរ ត្រូវត្រឡប់ដល់ទីតាំងរៀងៗខ្លួនវិញ។ តែចំពោះ លីវ-ប៉ាង ដាច់ខាតមិនអោយធ្វើដំណើរទៅទេ។

លីវ-ប៉ាង ភ្ញាក់ផ្អើលពេកក្រៃ យល់ឃើញថា ស៊ាង-យី ពិតជាមានបំណងអាក្រក់ចំពោះខ្លួនហើយក៏ប្រញ៉ាប់ទៅជួប ចាង-លៀង ពិគ្រោះយោបល់ ចាង-លៀងជ្រួញចិញ្ចើម ហើយក៏នឹកឃើញល្បិចមួយភ្លាមប្រាប់អោយ លីវ-ប៉ាង ចូលគាល់ហើយសុំច្បាប់ ស៊ាង-យី ទៅសួរសុខទុក្ខឪពុកម្ដាយបងប្អូនឯស្រុកកំណើតហើយនិងបង្រៀនថា ត្រូវធ្វើយ៉ាងនោះ។

ស្ដេចស៊ាង-យី មើលលិខិតរបស់ លីវ-ប៉ាង ចប់ហើយគិតមួយសន្ទុះធំ ទើបមានបន្ទូល៖

-ឯងចង់ត្រឡប់ទៅស្រុកកំណើតសួរសុខទុកឪពុកម្ដាយ អំពើនេះពិតជាកតញ្ញូសចំពោះអ្នកមានគុណហើយ តែខ្លាចតែពុំមែនចេញពីទឹកចិត្តរបស់ឯងនោះទេ ឬមួយក៏មកពីយើងទុកឯងនៅហាន់យ៉ាងនេះក៏កើតមាន គំនិតបែបនេះឡើង?

លីវ-ប៉ាង បញ្ចេញទឹកមុខគួរអោយអាណិត ហើយឆ្លើយ៖

-ឪពុកម្ដាយទូលបង្គំចាស់ណាស់ទៅហើយ គ្មានអ្នកនៅថែទាំទេ ទូលបង្គំតែងតែបារម្ភចំពោះ

គាត់គ្រប់ពេលវេលា តែដោយហេតុព្រះអង្គទើបឡើងគ្រងរាជ្យ កិច្ចការក៏មមាញឹក ហេតុនេះទើបទូលបង្គំមិនហ៊ានរំខានព្រះអង្គ តែពេលនេះឃើញថា គ្រប់ស្តេចក្រាញ់បានអនុញ្ញាតិឲ្យវិលត្រឡប់បើទៅកន្លែងចាស់គ្រប់គ្នាអស់ហើយ អាចសប្បាយជួបជុំគ្រួសារ ចំណែកទូលបង្គំត្រូវទុកអោយនៅទីនេះម្នាក់ឯង មិនដឹងជាពេលណា.ឆ្នាំណា ទើបអាចជួប មុខអ្នកមានគុណបាននោះ? និយាយដល់ត្រឹមនេះស្រាប់តែយំតែម្តង។

ពេលនេះ ចាង-លៀង ក៏ចេញជួយសម្តែង:

-មិនត្រូវអោយគេទៅស្រុកកំណើតជួបជុំគ្រួសារទេ សុខចិត្តបញ្ជូនគេឲ្យទៅហាន់-ជុង វិញប្រសើរជាងហើយចាត់មនុស្សទៅទទួលយកក្រុមគ្រួសារគេទាំងអស់មកទីនេះធ្វើជាឈ្លើយ ដើម្បីការពារកុំឲ្យគេនឹកស្រម័យកើតគំនិតផ្តេសផ្តាសបាន។

ស៊ាង-យី ឮនិយាយបែបនេះ ក៏ងក់ក្បាល់ហើយមានបន្ទូល:

-ឯងនិយាយត្រូវណាស់ មូលហេតុដែលយើងមិនឲ្យគេទៅ ហាន់-ជុងវិញ ពីព្រោះតែខ្លាចគេកើតចិត្ត មានគំនិតផ្តេសផ្តាសនេះឯង។

ឈីន-ភីង ក៏ឆ្លៀតឱកាសនេះចេញសម្តែងដែរ:

-ព្រះអង្គបានប្រទាន លីវ-ប៉ាង ជាស្តេចក្រាញ់ហាន់-ជុង បានប្រកាសពេញព្រះនគរទៅហើយ ប្រជារាស្ត្រសព្វមុខមន្ត្រីអ្នកណាក៏ដឹងដែរ បើមិនឲ្យគេឡើងកាន់តំណែង ខ្លាចតែគេលួចសើចយំព្រះអង្គមិនខាន ហើយគេនឹងនាំគ្នានិយាយថា ព្រះអង្គគ្រាន់តែឡើងសោយរាជ្យភ្លាម មានបន្ទូលមិនពិតភ្លាមតែម្តង បែបនេះខ្លាចក្រែងថ្ងៃក្រោយ រាល់រាជបញ្ជាមិនត្រូវទទួលបានការគោរពអឺចេះក៏ម្យ៉ាងដែរ គឺធ្វើតាមសំដីរបស់ ចាង-លៀង ទៅយកគ្រួសាររបស់លីវ-ប៉ាង មកធ្វើជាឈ្លើយទុកនៅហាន់-យ៉ាង បញ្ជូនលីវ-ប៉ាង ទៅហាន់-ជុង វិញ ទី១,អាចរក្សានូវព្រះបន្ទូលពិតរបស់ព្រះអង្គទី២,អាចជាគំនាបចំពោះ លីវ-ប៉ាង មិនឲ្យធ្វើអ្វីផ្តេសផ្តាសបាន បែបនេះ មិនប្រើទាំងសងខាងទេឬ ?

ស្តេចស៊ាង-យី ត្រិះរិះយ៉ាងយូរ ទើបមានបន្ទូលទាំងមិនអស់ចិត្ត:

-បានជាគ្រប់គ្នានិយាយបែបនេះទៅហើយ ស្តាប់ទៅក៏សមហេតុផលដែរ ល្អ យើងអនុញ្ញាតិឯងទៅ ទទួលតំណែងនៅហាន់-ជុង តែមិនអនុញ្ញាតិឯងទៅស្រុកកំណើតទេ ហើយថ្ងៃស្អែកគឺចេញដំណើរតែម្តង។

ឮបន្ទូលនេះលីវ-ប៉ាង ពិតជាត្រេកអររកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ តែបែរជាបញ្ចេញទឹកមុខគួរឲ្យ អាណិត នៅក្រាបសំពះមិនព្រមងើប នៅតែបន្តរទាមទារសុំទៅស្រុកកំណើតសាកសួរសុខទុក្ខគ្រួសារ ពេលនេះ ស៊ាង-យី ហាក់កើតចិត្តអាណិតដែរ ក៏លួងលោម:

-ឯងទៅហាន់-ជុង តាមសម្រួលទៅ យើងពិតជានាំយកក្រុមគ្រួសារឯងមកទីនេះ ចិញ្ចឹមថែរក្សាឲ្យ បានល្អបំផុត ពេលឯងទៅដល់ទីនោះបំពេញកិច្ចការបានចប់សព្វគ្រប់ហើយ ចាំចាត់មនុស្សមកទទួលពួកគាត់ ធ្វើបែបនេះមិនរាប់ថាអកតញ្ញូទេ។

ពេលនេះទើប លីវ-ប៉ាង បង្ខំចិត្តងើបឡើង ហើយក៏អរគុណចំពោះព្រះគុណដ៏ធំធេងរបស់ស៊ាង-យី ។

ត្រឡប់ទៅបន្ទាយវិញ ដាក់បញ្ជាដល់មេទ័ពកូនទាហានទាំងអស់ដកបង្គោលប្រមូលជុំរុំចេញដំនើរភ្លាម ប្រៀបបាននឹងខ្លាកំណាចដែលត្រូវដោះលែងឲ្យវិលត្រឡប់ទៅភ្នំ ក៏ធ្វើដំណើរយ៉ាងគគ្រឹកគគ្រេងទៅហាន់-ជុងវិញ។

# បញ្ឆោតខ្លា ចេញពីភ្នំ

ល្បិច(បញ្ឆោតខ្លាចេញពីភ្នំ) អាចធ្វើការពន្យល់ពីរបែប: មួយគឺបញ្ឆោតខ្លាឲ្យចាកចេញពីព្រៃជ្រៅ ដេញឲ្យចេញវាល ហើយធ្វើការបាញ់សម្លាប់តែម្តង ពីរគឺ ដេញខ្លាឲ្យរត់ចេញឆ្ងាយ ទើបទៅចាត់ការពពួកឆ្កែចចក កញ្ជ្រោងដែលសំអាងលើអំណាចខ្លា ដើររាតត្បាតរាល់ថ្ងៃនោះចេញ។ បើអនុវត្តចំពោះមនុស្សវិញ គឺត្រូវបញ្ឆោតមនុស្សដែលគ្រោះថ្នាក់និងសំខាន់បំផុត ចេញឲ្យផុតពីមូលដ្ឋានដែលជាទីតាំឫសគល់ ធ្វើឲ្យគេបាត់បង់លទ្ធភាពតបត ទើបចាត់ការគេជាបណ្តើរៗ ឬមួយក៏បំបែក មនុស្សសំខាន់នៅក្បែរខ្លួនគេឲ្យឃ្លាតចេញឆ្ងាយ កាត់បន្ថយកម្លាំងពិត ទើបទៅចាត់ការបណ្តើរៗ។

ហាងហ្វី និយាយថា៖ មូលហេតុដែលខ្លាអាចបង្ក្រាបឆ្កែបាន(ដោយសារក្រញ៉ាំ) បើធ្វើឲ្យឆ្កែរប្រើក្រញ៉ាំវិញនោះ ខ្លាពិតជាត្រូវឆ្កែបង្ក្រាបវិញមិនខាន ។ នេះគឺជាសំដីមួយឃ្លារដែលងាយយល់បំផុត។ ល្បិចកលនេះ ប្រើប្រាសនៅក្នុងការដណ្តើមអំណាចប្រជែងយកផលប្រយោជន៍ច្រើនបំផុត អាចនិយាយថា មានតាំងពីអតីតកាលមកម្លេះ បច្ចុប្បន្នរឹតតែខ្លាំងក្លា មួយជំនាន់ខ្លាំងជាងមួយជំនាន់ ហើយរឹតតែប្លែកអស្ចារ្យ។

ដណ្តើមអំណាច គឺជាមធ្យោបាយ ដើម្បីទាញយកផលប្រយោជន៍ ដើម្បីផលប្រយោជន៍ ទើបជាគោលបំណងពិតនៃការដណ្តើមអំណាច មិនដែលមានមនុស្សភ្លើណាដែលមិនមែនដើម្បីផលប្រយោជន៍ ហើយទៅប្រឹងដណ្តើមអំណាចនោះទេ ក៏ពុំដែលជួបប្រទះថា(ផលប្រយោជន៍)ដែលគ្មានការគាំពារពីអំណាចអាចថិតថេរបាន យូរអង្វែងដែរ។ ដើម្បីសម្រេចគោលបំណងសំរាប់ប្រើ ទោះបីនៅក្នុងខ្លួនមានអាវុធពិសេសបែបណាក៏ដោយ ក៏គ្មាន ទីសម្រាប់ប្រើវាដែរ ជួបប្រទះរឿងដែលក្តៅក្រហាយ តើមានលទ្ធភាពឯណាបញ្ចេញកំហឹងបាន? ពេលដែរជាងថៃកុង មានអំណាចនៅក្នុង
ដៃ អាចសម្លាប់ អាចប្រទានសក្តិតាមចិត្តចង់ ពេលដែលគ្មានអំណាច គ្រាន់តែជា កូនឈ្នួញលក់អំបិលតែប៉ុណ្ណោះ។

នៅលើលោកយើងនេះ មនុស្សសាមញ្ញជាច្រើនដែលមានអំណាច ស្លាបមាន់របស់គេក្លាយជាព្រួញផ្លុយទៅវិញអ្នកក្លាហានជាច្រើនដែលថ្លោះធ្លោយដាវទិព្វបានក្លាយជាកាំបិតពេជ្ឈឃាត ហេតុនេះ ម្នាក់ៗអាងអំណាចក៏ដណ្តើមរាល់កិច្ចការតែងយកភាពខ្លាំងដើម្បីប្រលងប្រជែង កេងចិត្តប្រវ័ញ្ចថ្លើមនិយាយដើមវាយប្រហារ ក្រឡុកទាល់តែម្នាក់ៗក្លាយជាសត្វខ្លា ម្នាក់ៗទៅជាព្រានព្រៃ។

(បញ្ឆោតខ្លាចេញពីភ្នំ) គឺជាល្បិចមួយនៃការសម្លាប់ខ្លា គោលបំណងរបស់វា នៅត្រង់បន្ថយកម្លាំងតបតរបស់សត្រូវ បន្ថយនូវភាពគ្រោះថ្នាក់ចំពោះខ្លួនឯង។

នៅក្នុងប្រវត្តិសាស្ត្រចិន អ្នកដែលប្រើប្រាស់ល្បិចបញ្ឆោតខ្លាចេញពីភ្នំ ដែលល្បីឈ្មោះជាងគេគឺ ឈីន ភីង គេបានប្រើល្បិចពិសេសទាំងប្រាំមួយជួយដល់ស្តេចលីវ ប៉ាង សុទ្ធតែជាល្បិចបញ្ឆោតខ្លាចេញពីភ្នំ ល្បិចទាំងប្រាំមួយនោះគឺ ទី១,បំបែកបំបាក់មន្ត្រីសំខាន់ផុង លីមៃ ។ល។ ឲ្យបែកចេញពីស្តេចឆដើម្បីកាត់បន្ថយ កម្លាំងពិត។ ទី២,អុជអាលហ្វាន់ចិនឲ្យក្តៅក្រហាយរត់ចោលស្តេច ធ្វើឲ្យស្តេចឆឯកកោ។ ទី៣,ពេលយប់បញ្ចេញ នារីពីរពាន់នាក់រំដោះលីវ ប៉ាង ឲ្យរួចផុតពីការឡោមព័ទ្ធនៅវិញយ៉ាង។ ទី៤,ឲ្យលីវ ប៉ាង តែតាំងហាង ស៊ីង ជាស្តេចក្រាញ់ ប្រើប្រាស់គេទៅប្រយុទ្ធដណ្តើមទឹកដី។ ទី៥,ឲ្យលីវ ប៉ាង ក្លែងធ្វើជាទៅកំសាន្តនៅយឺន ម៉ុង តាមចាប់ហាងស៊ីងមកវិញ។ ទី៦,បំបែកការឡោមព័ទ្ធនៅប៉ាយតឹង រំដោះជីវិតលីវ ប៉ាង ឲ្យរួច

## បញ្ឆោតខ្លាចេញពីភ្នំ

ផុតពីសាច់ក្តី ស្លាប់។ ល្បិចកលទាំងប្រាំមួយនេះ សុទ្ធសឹងជាល្បិចបញ្ឆោតខ្លាចេញពីភ្នំ ហើយឈីន ភីងធ្វើបានល្អណាស់ ។

សម័យឈុន ឈីវ ជិន ជួងកុង ក៏បានប្រើល្បិចនេះសម្លាប់ប្អូនបង្កើតរបស់ខ្លួន ថៃ ស៊ូ ទាន់ដែរ។

(ប្រវត្តិពិត) ចុងឆ្នាំនៃរជ្ជការចូវ ជិន វូកុង បានរៀបអភិសេកជាមួយនាងជាង ស៊ី ហើយប្រសូត្របាន បុត្រពីរអង្គ បុត្រច្បងព្រះនាមអ៊ូ ស៊ឺន បុត្របន្ទាប់ព្រះនាម ទាន់។

បុត្រព្រះនាមទាន់ មានរូបស្អាតសង្ហា និង ស្វាហាប់អស្ចារ្យ ម្ចាស់ក្សត្រីជាង ស៊ី ស្រឡាញ់គេណាស់។ ជាញឹកញាប់នៅចំពោះមុខព្រះភ័ក្រព្រះអង្គ ម្ចាស់ក្សត្រីតែងមានបន្ទូលអាក្រក់ ពីបុត្រច្បង សរសើរបុត្របន្ទាប់ថាឆ្លាតវាងវៃ ព្រមទាំងឲ្យយោបល់ថា៖ គួរផ្លាស់ប្តូរឲ្យ ទាន់ ជាអ្នកស្នងរាជ្យវិញ តែ វូ កុង បែរជាមានបន្ទូលថា៖

បុត្រមានតូចមានធំ មិនត្រូវធ្វើឲ្យច្របូកច្របល់ទេ ម្យ៉ាងអ៊ូ ស៊ឺន ក៏មិនដែលមានកំហុសអ្វីដែរ បើ យោងតាមច្បាប់ធ្វើតាមទម្លាប់គឺ គឺធ្វើតាមមហេសីមិនកើតទេ។ ហើយក៏ប្រកាស តែងតាំងអ៊ូ ស៊ឺនជាអ្នកស្នង រាជ្យសម្បត្តិ ចំណែកទាន់ បានប្រគល់ខេត្តតូចមួយឲ្យគ្រប់គ្រង។

ពេលវូ កុង សោយទីវង្គត អ៊ូ ស៊ឺន ក៏ស្នងរាជ្យបន្តរ ព្រះនាមជឺន ជួងកុង ម្ចាសក្សត្រីឃើញទាន់ បានគ្រប់គ្រងកូនខេត្តមួយ ហើយគ្មានអំណាច មិនសប្បាយក្នុងព្រះទ័យ ទាល់តែសោះ ក៏មានបន្ទោលទៅកាន់ ជួង កុង។

ថ្ងៃនេះឯងស្នងរាជ្យឪពុក ប្អូនប្រុសបបានគ្រប់គ្រងដីតែប៉ុន្មានរយលីប៉ុណ្ណោះ រស់នៅក្នុងខេត្ត តូចមួយ ហើយនៅចុងកាត់មាត់ញកទៀត តើឯងដាច់ចិត្តដែរឬអី?

ជួង កុងមានបន្ទូលសួរ:

តាមយោបល់ព្រះមាតា តើគួរធ្វើយ៉ាងណា?

ចាំបាច់មាតានិយាយឬ? ក្នុងបន្ទូលរបៀបស្តីប្រដៅ ម្ចាស់ក្សត្រីស៊ឹបន្តរ:

ឲ្យគេគ្រប់គ្រងទីក្រុងធំមួយទៅ យកល្អឲ្យទីក្រុងជឺ អី តែម្តងទៅ ។

ជួង កុង ប្រញ៉ាប់មានបន្ទូលប្រាប់មាតាវិញ៖

ជឺ អ៊ីជាកន្លែងគ្រោះថ្នាក់ ព្រះបិតាបានផ្តែផ្តាំហើយថា មិនត្រូវឲ្យអ្នកណាគ្រប់គ្រងទាំងអស់ ក្រៅពីកន្លែងនេះ កន្លែងណាក៏បានដែរ។

បើអីចឹង ប្រគល់រាជធានីឲ្យគេគ្រប់គ្រងក៏បាន។ ម្ចាស់ក្សត្រីមានបន្ទូល។ ព្រះសណ្តាប់ហើយ ជួង កុងនៅស្ងៀមមិនចេញវាចារ សញ្ជឹងគិតយ៉ាងយូរ ទេក៏មិនឆ្លើយ

អឺក៏មិនថា។ ពេលនេះម្ចាស់ក្សត្រីខ្ញាល់ ហើយរលាស់ដៃអាវ មានបន្ទូលទាំងច្រឡោត:

បើឯងនៅតែមិនយល់ព្រម និរទេសចេញពីនគរតែម្តងទៅ ឲ្យវាស្រឡះស្រឡៃងតែម្តងទៅ។

មិនហ៊ាន! មិនហ៊ាន។ ជួង កុង ប្រញ៉ាប់សុំទោសហើយមានបន្ទូល:

បុត្រសូមគោរពតាមរាជបញ្ជា។

ស្អែកឡើង ជួបជុំគ្នាឯរាជវាំង ប្រកាសតែងតាំងឲ្យទាន់ គ្រប់គ្រងរាជធានី លោកម្ចាស់ជី ជូ ឡើងថ្លែង៖ មេឃមិនអាចមានព្រះអាទិត្យពីរ ប្រជារាស្ត្រមួយមិនអាចមានម្ចាស់ពីរ រាជធានីជាកន្លែងសំខាន់ណាស់ដីធំទូលាយប្រជារាស្ត្រច្រើន ទាំងកិច្ចការនយោបាយនិងយោធាមិន នៅក្រោមព្រះរាជាវាំងឡើយ។ ហើយព្រះអង់ម្ចាស់ទាន់ គឺជាបុត្រសំឡាញ់របស់ម្ចាស់ក្សត្រី បើប្រគល់រាជធានីដ៏ធំនេះអោយទៅគេ ប្រៀបបាននគរមួយមានស្តេចពីរអង្គដោយ មិនដឹងខ្លួន ថ្ងៃណាមួយការស្រលាញ់ធ្វើឲ្យមានអំនូតលទ្ធផលចុងក្រោយ ពិតជាមិនអាចស្មានបាននោះឡើយ ។

ជូ កុងមានបន្ទូលទាំងបង្ខំព្រះទ័យ:

ឈប់និយាយទៅធ្វើនេះគឺតាមបញ្ជារបស់ព្រះមាតា។ តៀនឲ្យប្រកាសតែងតាំង ទាន់

គ្រប់គ្រង់រាជធានីជាបន្ទាន់។
មុនទៅទទួលតំណែង ទាន់បានយាងទៅរាជតំណាក់ដើម្បីសុំលា ម្ចាស់ក្សត្រីដេញសេនាឆ្វេងស្តាំចេញក្រៅ រួចប្រាប់ទាន់ថា:
ការតែងតាំងលើកនេះពិតជាធ្វើដោយបង្ខំណាស់ថ្ងៃក្រោយពិតជាមានការប្រែប្រួលបុត្រត្រូវគិតគូរជាមុនឲ្យ ហើយក្រោយដល់រាជធានីត្រូវប្រមូលទ័ពសន្សំស្បៀង
ត្រូវប្រុងប្រយ័ត្នគ្រប់ពេលវេលា ឲ្យតែមានឱកាស មាតានឹងធ្វើផ្ទៃក្នុងឲ្យបុត្រ លុះគ្រាតែផ្តួលរំលំ អ៊ូ ស៊ី បាន ទើបសមតាមបំណងប្រាថ្នាជាតិនេះរបស់មាតា។
ទាន់ ទទួលរាជបញ្ជា ចេញពីទីក្រុង ពេញដោយអំនួតទៅទទួលតំណែងចៅហ្វាយខេត្ត ស៊ីពីនិងប៉ៃពី ដែលនៅជិត ក៏បានមកចូលរួមអបអរសាទរ ថៃ ស៊ូទាន់បានប្រាប់
នាក់ទាំងពីរ: ទឹកដីដែលលោកទាំងពីគ្រប់គ្រង គឺនៅក្នុងការត្រួតត្រារបស់យើង ចាប់ពីពេលនេះតទៅ រាល់ពន្ធអាករត្រូវតែយកមកបង់ឲ្យកន្លែងយើង កម្លាំងទ័ពត្រូវគោរពតាមបញ្ជារយើងមិនត្រូវជំទាស់ទេ។
អ្នកទាំងពីរដឹងថា ព្រះអង្គម្ចាស់ទាន់ គឺជាបុត្រសម្លាញ់របស់ម្ចាស់ក្សត្រី មានសង្ឃឹមថាអាចគ្រងរាជ ទៀតផង ថែមទាំងឃើញឬកពារអង់អាចការចេះដឹងដ៏ពិសេស ពិតហើយគឺមិនហ៊ានប្រឆាំងទេ ថែមទាំងពេញចិត្តនឹងស្តាប់តាមបញ្ជាណាស់។
ចាប់ពីពេលនោះមកព្រះអង្គម្ចាស់ទាន់ បានបង្ហាត់ហ្វឹកហ្វឺនកងទ័ពដោយយកចិត្តទុកដាក់ បន្ថែមការតែងតាំងយកលេសចូលលុកលុយតំបន់ អ៊ី និង ម៉ាវ យាន នៅក្បែរ
នោះទឹកដីត្រួតត្រាកាន់តែធំទៅៗ ជារៀងរាល់ថ្ងៃកម្លាំងកាន់តែរឹងមាំឡើងមិនឈប់ឈរ។
ផ្នែកចារកម្មបានយករឿងនេះមករាយការណ៍ ជួង កុងសើចហើយមិនតប នៅក្នុងសាវនាការ ស្រាប់តែឮមន្ត្រីម្នាក់ស្រែក:
ត្រូវតែប្រញាប់កំចាត់ព្រះអង្គទាន់ចោល។ ជួង កុងងើបភក្រ័សម្លឹងមើល គឺលោកម្ចាស់កុង ជីលីទេតើ ក៏សួរ: បញ្ហានេះលោកម្ចាស់មានយោបល់យ៉ាងណាដែល?
កុង ជីលីតប:
តាំងពីដើមមក អ្នកដែលតែងតាំងជាមន្ត្រីស៊ីវិល មិនត្រូវសួរនាំពីកិច្ចការយោធា ហ៊ានតែរើសទ័ពផ្ទាល់ខ្លួល ត្រូវសម្លាប់គ្មានការលើកលែង ឥឡូវនេះព្រះអង្គអាងអំណាច
មាតា សំអាងលើការឹងមាំរបស់រាជធានី ហ្វឹកហាត់ កងទ័ពទាំងយប់ទាំងថ្ងៃ
បើមិនមានបំណងដណ្តើមរាជបល្ល័ង្គទេ តើដើម្បីស្អីទៅវិញ? សូមព្រះអង្គ ប្រទានសិទ្ធិដល់ ទូលបង្គំ នាំទ័ពទៅបង្ក្រាបឲ្យទាន់ពេវេលា
ជៀសវៀងមានគ្រោះថ្នាក់ទៅថ្ងៃក្រោយ។តែទាន់មិនទាន់មានសកម្មភាពក្បត់នៅឡើយទេ។ ជួង កុងតប កុង ជីលីពោលពាក្យ ទាំងក្តៅក្រហាយ:
តំបន់ពីរត្រូវកាន់កាប់ សកម្មភាពបែបនេះមិនហៅថាក្បត់ទេឬ? ទឹកដីរបស់នគរ ម្តេចនឹងអាចឲ្យ ផ្ដេ់ ស្រេចតែចិត្តនុះ។
ជួង កុងសើច:
ទាន់ គឺជាបុត្រសម្លាញ់របស់ព្រះមាតា ជាបងប្អូនបង្កើតរបស់យើង គេថាសុខចិត្តបាត់បង់ទឹកដី មិនត្រូវ ធ្វើឲ្យល្អក់កករមនោសញ្ចេតនា រវាងបងនិងប្អូន កូននឹងម្តាយនោះទេ។
កុង ជីលីតប:
ទូលបង្គំមិនមែនខ្លាចបាត់បងទឹកដីនោះទេ គឺខ្លាចបាត់បង់នគរតែម្តង
កម្លាំងព្រះអង្គម្ចាស់ទាន់រីកធំធេងជារៀងរាល់ថ្ងៃ បើសិនជានៅតែទ្រាំអនុគ្រោះតទៅទៀត ខ្លាចតែដល់ពេលកើត
រឿងឡើង គ្មានលទ្ធភាព នឹងបង្ក្រាបនោះទេ ពេលនេះព្រះអង្គអនុគ្រោះព្រះអង្គម្ចាស់ទាន់

# បញ្ឆោតខ្លាចេញពីភ្នំ

ថ្ងៃក្រោយព្រះអង្គម្ចាស់ទាន់ មិនប្រាកដជាអនុគ្រោះចំពោះព្រះអង្គវិញឡើយ។
មិនត្រូវនិយាយផ្ដេសផ្ដាសទេ! ។ មិនចាំ កុង ជីលី និយាយចប់ទេ ព្រះអង្គក៏ឃាត់គេឲ្យឈប់និយាយ
ហើយមានបន្ទូល:
យើងចេះគិតគូរពីរឿងនេះហើយ! ហើយប្រកាសបិទសវនាការតែម្ដង។ កុង ជីលី ចេញមកដល់
ក្រៅក៏និយាយទៅកាន់លោកម្ចាស់ជី ជូ:
ព្រះអង្គប្រកាន់មនោសញ្ចេតនាបែបនេះ ពិតជាធ្វើឲ្យខូចកិច្ចការនគរហើយ ខ្ញុំបារម្ភណាស់។
ជី ជូប្រាប់ទៅវិញ:
ព្រះអង្គជាស្ដេចដ៏ល្អ តែប្រកបដោយមធ្យោបាយគ្រប់បែបយ៉ាង ពិតជាមិនប្រហែលពីរឿងនេះទេ
ប៉ុន្តែនៅចំពោះមុខមន្ត្រីជាច្រើនបែបនេះ គិតជាមិនទៅគាល់ព្រះអង្គផ្ទាល់
តែម្ដងទៅ ព្រះអង្គពិតជាមានបន្ទូលការ ពិតប្រាប់លោកម្ចាស់ហើយ។ តាមការផ្ដល់យោបល់របស់លោកម្ចាស់
ជី ជូ លោកម្ចាស់កុង ជីលី ក៏បានចូលទៅ គាល់ព្រះអង្គឯរាជតំណាក់។
ព្រះអង្គក៏សួរថា តើមានការអ្វី?
កុងជីលីក៏និយាយ:
¬ទូលបង្គំមកនេះ
ក៏ព្រោះតែរឿងពីព្រឹកមិញនេះថ្ងៃដែលព្រះអង្គស្នងរាជ្យអ្នកណាក៏ដឹងដែលថាមិនមែនជាគំនិតរបស់ម្ចាស់ក្សត្រីនោះទេ ម្ចាស់ក្សត្រីគឺផ្អែកតែខាងព្រះអង្គម្ចាស់ទាន់
ប៉ុណ្ណោះ។ បច្ចុប្បន្ន អំពើពាលត្បាតវាតទីរបស់ព្រះអង្គម្ចាស់ទាន់
ពិតជាផែនការដណ្ដើមអំណាចហើយប្រសិនបើផ្ទៃក្នុងឲ្យដៃទៀតរដ្ឋប្រហារមួយនឹងផ្ទុះឡើងពេលនោះខ្លាចក្រែងតែ......។
ជួងកុងមានបន្ទូលកាត់:
¬រឿងនេះ បើយើងធ្វើឲ្យផ្ទុះឡើងមុន ពិតជាប៉ះពាល់ដល់កិត្តិយសម្ចាស់ក្សត្រីហើយ។
¬ព្រះអង្គមិនដែលឮរឿងចូវកុង កំចាត់ គាន់ឆាយ ទេឬ? ត្រូវកំចាត់
តែមិនកំចាត់បែជាត្រូវគាន់ឆាយកំចាត់វិញ។ ដល់ពេលនោះ ទោះបីបើជាស្ដាយក្រោយក៏វាហួស
ពេលទៅហើយ។ កុងជីលីនិយាយ។
ជួងកុង ដកដង្ហើមវែង ហើយមានបន្ទូល:
¬អារឿងនេះយើងបានគិតគូររួចទៅហើយ
ទាន់ពិតមែនតែមានផែនការដណ្ដើមអំណាចព្រះមាតាពិតជាចេញមុខការពារ
ហើយនឹងត្រូវអ្នកខាងក្នុងនិងក្រៅរិះគន់ថែមទៀត
គេនឹងនិយាយថា:
យើងមិនគិតពីមនោសញ្ចេតនាបងប្អូនជេរថាយើងនេះជាកូនអកតញ្ញូហេតុនេះហើយបានជាពេលនេះយើងបានតែធ្វើគរធ្វើថ្លង់ប៉ុណ្ណោះ
ស្រេចតែគេចង់ធ្វើអីតាមចិត្តទៅចុះដល់ពេលឃើញថាមានសកម្មភាពក្បត់ច្បាស់លាស់ ហើយ
ពេលនោះទើបអាចផ្ដន្ទាទោសគេជាចំហរតែម្ដង។ពេលនេះ កុងជីលីទើបយល់
ពីគំនិតរបស់ព្រះអង្គ និយាយថា:
¬ព្រះអង្គពិតជាមានគំនិតគិតវែងឆ្ងាយមែន មន្ត្រីទាំងអស់ពិតជាមិនស្មើរឡើយ ក៏ប៉ុន្តែខ្លាចបណ្ដែតបណ្ដោយ
យូរទៅកម្លាំងព្រះអង្គម្ចាស់ទាន់កាន់តែរឹកមាំទៅពេលនោះពិត
ជាលំបាកហើយយល់ល្អ គួររកមធ្យោបាយអុជអាលឲ្យគេបញ្ចេញសកម្មភាពពេលនេះតែម្ដងទៅ
ទើបមានលេសបង្ក្រាបគេបានទាន់ពេលវេលា។
សំដីនេះពិតជាត្រូវនឹងចំនុចជួងកុង កំពុងគិតក៏ប្រញាប់សួរ:

## បញ្ឆោតខ្លាចេញពីភ្នំ

¬តើមានផែនការល្អយ៉ាងណា?

¬កុងជីលី ក៏និយាយលំអិតបន្ថែម:

¬ព្រះអង្គម្ចាស់ខានទៅសួរសុខទុក្ខនគរចូវយូរណាស់ហើយ ដោយសារតែមូលហេតុរឿងព្រះអង្គម្ចាស់ទាន់ពេលនេះធ្វើជាទៅសួរសុខទុក្ខព្រះអង្គចូវធានជីទៅហាក់ដូចជាទុកឱកាសឲ្យគេរួចពន្យុះឲ្យគេបង្កើតរឿងនាំទ័ពសំរុកចូលមកចំណែកទូលបង្គំនឹងលាក់ខ្លួនត្រៀមរង់ចាំគេក្បែរ
រាជធានីរង់ចាំឲ្យគេនាំទ័ពចេញមកផុតនឹងឆ្លៀតឧកាសវាយសំរុកកាន់កាប់ទីតាំងមូលដ្ឋានរបស់គេតែម្តងនៅពេលនោះព្រះអង្គត្រលប់បកក្រោយវិញហើយ ហើយវាយ
បកពីខាងក្រោយមកវិញទៀត ពេលនោះទោះជាគេចេះហោះ ក៏ហោះមិនរួចដែរ។

ព្រះសណ្តាប់ចប់ ព្រះអង្គម្ចាស់ជួងកុង ងក់ក្បាលសសើរ:

¬ពិតជាល្បិចល្អវិសេសមែន!

កុងជីលី ក៏សុំលា ដកដង្ហើមហើយគិតថា:

¬លោកម្ចាស់ជីជូ ពិតជាទាយមិនខុសមែន!

ព្រឹកថ្ងៃបន្ទាប់ជួងកុង ក៏ដាក់បញ្ជារក្លែងក្លាយមួយប្រគល់សិទ្ធិឲ្យលោកម្ចាស់ជីជូដឹកនាំកិច្ចការនគរជំនួសចំណែកព្រះអង្គត្រូវធ្វើដំណើរទៅកាន់នគរចូវ
គាល់ព្រះអង្គ ចូវធានជី។

ម្ចាស់ក្សត្រីទទួលបានដំណឹងនេះ គិតថាឱកាសមកដល់ហើយក៏ប្រញាប់ផ្ញើសំបុត្រប្រាប់ព្រះអង្គម្ចាស់ថៃស៊ូទាន់ ណាត់ថា នៅដើមខែ៥ ឲ្យធ្វើការវាយសំរុកចុះ។

ពេលនេះគឺចុងខែ៤ទៅហើយកុងជីលី
បានរៀបចំកម្លាំងមួយចំនួនលាក់ខ្លួនតាមផ្លូវសំខាន់ៗជាមុនរួចជាស្រេច ចាប់បានអ្នកនាំសារហើយក៏សំលាប់ចោលរួចបញ្ជូនសំបុតនោះ
ទៅឲ្យព្រះអង្គម្ចាស់ជួងកុងទត:

មនុស្សសាងអំពើអ្វីពិតជាត្រូវទទួលផលនោះ ជួងកុងមានបន្ទូល។

ហើយក៏ចាត់មនុស្សជំនិតឲ្យក្លែងថាជាជំនិតរបស់ព្រះមហាក្សត្រីផ្ញើសំបុត្រឲ្យថៃស៊ូទាន់រួចរង់ចាំទទួលសំបុត្រឆ្លើយតបមកវិញសំបុត្រឆ្លើយតបបញ្ជាក់ថាត្រូវតែធ្វើ
សកម្មភាពវាយលុកនៅថ្ងៃទី៥ ជាកំណត់សូមឲ្យលើកទន់ជ័យពណ៌សក្នុងទីក្រុងដើម្បីជាសញ្ញា។

ទទួលបានសំបុត្រជួងកុង ត្រេកអរណាស់ ក៏មានបន្ទូល:

¬ភស្តុតាងមាននៅទីនេះគ្រប់គ្រាន់ហើយ
ចាំមើលតើគេប្រកែកយ៉ាងម៉េចទៀតរួចក៏ប្រញ៉ាប់ចូលគាល់ព្រះមាតាទូលថាប្រញ៉ាប់ទៅគាល់ព្រះរាជាចូវម្ចាស់ក្សត្រីក៏ធ្វើជាគួរសម
ហើយផ្តាំផ្ញើប៉ុន្មានម៉ាត់ដែរទៅ។ ជួង កុង ក៏នាំទ័ពយ៉ាងគគ្រឹកគគ្រេង ធ្វើដំណើរទៅកាន់នគរចូវ
ពេលនេះកុងជីលីក៏បានរៀបចំកម្លាំងលាក់ខ្លួនត្រៀមស្ទាក់ជាស្រេចក្បែរទីក្រុង
រង់ចាំទទួលខ្លាចុះពីលើភ្នំ។

ក្រោយទទួលបានសំបុត្ររាយការណ៍ជាសំងាត់របស់ម្ចាស់ក្សត្រីយ៍ហើយ
ព្រះអង្គម្ចាស់ទាន់តៀមខ្លួនជាស្រេចរួចក៏បញ្ជូនបុត្រកុងស៊ុនវ៉ាទៅខ្ចីទ័ពពីនគរវេ
ចំណែកព្រះអង្គម្ចាស់ដឹកនាំកូនថៅផ្ទាល់ប្រាប់ថាជួងកុងត្រូវចេញពីនគរត្រូវតែខ្លួនត្រឡប់ទៅជួយពិនិត្រកិច្ចការ ហេតុនេះក៏រៀបចំសេះលើកទង់ជ័យធ្វើដំណើរសំដៅទៅ
រាជវាំងដោយសៀងបៀង។

ពេលនេះកម្លាំងបង្កប់របស់កុងជីលីក្នុងសំលៀកបំពាក់ស៊ីវិលបានបន្លំខ្លួនពេញទាំងទីក្រុងទៅហើយក៏ដុតភ្លើងជាសញ្ញានៅក្នុងក្រុងកម្លាំងដែលនៅខាងក្រៅគ្រាន់តែឃើញភ្លើង

## បញ្ឆោតខ្លាចេញពីភ្នំ

សញ្ញាក៏វាយសំរុកចូលតែម្តងកាន់កាប់ទីក្រុងទាំងមូលភ្លាម
រួចចេញសេចក្តីប្រកាសផ្សព្វផ្សាយដល់ប្រជារាស្ត្រវែកមុខមាត់ក្បត់របស់ព្រះអង្គម្ចាស់ថៃស៊ូទាន់
នាពេលនោះតែម្តង។
ថៃស៊ូទាន់ដឹកនាំទ័ពដល់ពាក់កណ្តាលផ្លូវក៏ទទួលដំណឹងថាទីក្រុងត្រូវបាត់បង់ទៅហើយក៏ជ្រួលច្របល់
ក្នុងចិត្តជាខ្លាំង បញ្ជាទ័ពឲ្យបកក្រោយភ្លាម រង់ចាំខាងក្រៅក្រុងវាយបកទៅវិញ។
ក៏ប៉ុន្តែទឹកចិត្តកងទ័ពកំពុងស្ថិតក្នុងភាពរំជើបរំជួលហើយគ្រប់គ្នាកំពុងខ្សឹបខ្សៀវគ្នាទៅវិញទៅមកយោបល់រា
ប់រយពាន់ ម្នាក់ៗនិយាយថា: ថៃស៊ូទាន់មានគំនិតមិនល្អ ចង់ដណ្តើមអំណាច។
ការពិតកំលាំងបង្កប់របស់កុងជីលីបានបន្លំខ្លួនចូលក្នុងជួរទ័ពរួចជាស្រេចហើយផ្សព្វផ្សាយរឿងនេះតែមួយប៉
ព្រិចភ្នែកប៉ុណ្ណោះ រឿងនេះត្រូវផ្សាយផ្អើលឈូលក្នុងជួលកងទ័ពក្នុង១យប់ប៉ុណ្ណោះ
ទាហ៊ានក៏រំសាយខ្លួនអស់ពាក់កណ្តាល
ថៃស៊ូទាន់ពិតជាជ្រួលច្រល់មែនទែនហើយដឹកនាំទ័ពសេសសល់សំដៅទៅយានអ៊ី
នឹកថានឹងប្រមូលសេះផ្តុំទ័ពនៅទីនោះឡើងវិញ។ តែស្មានមិន
ដល់ថាជួងកុង បានកាន់កាប់យានអ៊ីបាត់ទៅហើយ
ដូចនេះមិនអាចរុលទៅមុខទៀតបានទេត្រូវបង្វិលត់ទៅកាន់តំបន់ដែលនៅក្រោមការត្រួតត្រារបស់ខ្លួននៅកុង
ឈឹងវិញ រួចបិទទ្វាក្រុងទាំងអស់ដើម្បីការពារខ្លួនក៏ប៉ុន្តែកម្លាំងទ័ពរបស់ជួងកុង និងកុងជីលី
បានដេញយ៉ាងប្រកិតកូនក្រុងដ៏តូចមួយនេះតើអាចទប់ទល់នឹងការវាយសង្គ្រប់ផ្ទប់ទាំងសងខាងរបស់កងទ័ព
ដ៏ធំនេះបានឬទេ? ពេលនេះ
ទាន់ដឹងថាខ្លួនបានដើរដល់ទីបញ្ចាប់ហើយដកដង្ហឹមវែងយ៉ាងអស់សង្ឃឹម:
នេះសុទ្ធសឹងតែមកពីមាតាទាំងអស់
តើមានមុខមាត់ឯណាទៅជួបមុខបងប្រុសនោះ។រួចក៏ធ្វើអត្តឃាតតែម្តងទៅ។
ជួងកុងក៏ឆែកយកសំបុត្រទៅមករបស់ថៃស៊ូទាន់និងម្ចាស់ក្សត្រីផ្ញើរទៅរាជធានីប្រាប់ឲ្យលោកម្ចាស់ជីជួ
ប្រគល់សំបុត្រនេះឲ្យទៅ ម្ចាស់ក្សត្រី ហើយឲ្យជូនម្ចាស់ក្សត្រីទៅរស់នៅជនបទ។
គ្រាន់តែឃើញសំបុត្រភ្លាម អៀនខ្មាស់ឥតឧបមា ក៏យល់ថាគ្មានមុខទៅជួបកូនប្រុសទៀតទេ
ហើយក៏ប្រញ៉ាប់រើតវ៉ាន់ចេញពីរាជតំណាក់ភ្លាម៕

# ខ្ចីកាំបិតសម្លាប់មនុស្ស

ខ្ចីកាំបិតសម្លាប់មនុស្ស មានន័យថា: នៅពេលខ្លួនគ្មានមធ្យោបាយ ឫក៏ពេលត្រូវទទួលការកំណត់ ពីបរិយាកាស ដែលមិនអាចអនុវត្តន៍ គោលបំណងខ្លួនឯង ដោយផ្ទាល់ដៃបាន ក៏ប្រើប្រាស់អ្នកដទៃ ទៅសម្លាប់អ្នកដទៃជំនួសវិញ ដោយអនុវត្តន៍តាមផែនការ និងគំនិតរបស់ខ្លួន នេះហៅថាខ្ចីកាំបិតសម្លាប់មនុស្ស។

សម្លាប់មនុស្សពិតជាសាហាវយង់ខ្នង តែនៅលើលោកយើងនេះក៏មានមនុស្សជាច្រើនគួរតែស្លាប់ តែក៏មានមនុស្សជាច្រើនត្រូវស្លាប់ដោយអយុត្តិធម៌។ សម្លាប់មនុស្ស តាមពិតមិនចាំបាច់និយាយដល់អ្វីដែលហៅថា មនុស្សធម៌ យុត្តិធម៌ ឬ អយុត្តិធម៌ នោះទេ ហើយក៏មិនចាំបាច់ដឹងថា អ្នកដែលត្រូវសំលាប់ ជាអ្នកណា អ្នកនោះគួរឬមិនគួរសម្លាប់។ និយាយឲ្យខ្លី អ្នកដែលប្រឆាំងគឺស្លាប់ អ្នកដែលដើរតាមគឺរស់។ នេះជាគោលការណ៍សាមញ្ញបំផុត នៃប្រវត្តិសាស្ត្រ នយោបាយ លើពិភពលោកកន្លងមក។

ការសម្លាប់មនុស្ស បែងចែកនូវភាពល្ងង់ខ្លៅ និងភាពឆ្លាតវៃ។ អ្នកបាញ់អ្នកកាប់សំលាប់មនុស្សនៅៗ មើលទៅដូចជាអ្នកក្លាហានអឺចឹង តែយូរឆាប់អ្នក ក្លាហាននោះពិតជាគេចមិផុតពីសំណាញ់ច្បាប់ឡើយ មនុស្សឆ្លាតដែលសម្លាប់មនុស្ស គេមិនចាំបាច់ធ្វើឲ្យប្រលាក់ឈាមឆ្អាបជាប់នឹងដៃខ្លួនឯងឡើយ គេនឹងប្រើប្រាស់ ល្បិចកល ក្នុងរូបភាពច្បាប់ ប្រើអ្នកដ៏ទៃឲ្យធ្វើការកាប់សម្លាប់ដោយចំហរតែម្តង។ គេថា: សម្លាប់មនុស្សឃើញ លោហិតមិនរាប់ថា ជាអ្នកក្លាហានឡើយ។ ធ្វើបែបនេះមិនគ្រាន់តែសំរេចបានគោលបំណងប៉ុណ្ណោះទេ គឺរូបគេនោះត្រូវរស់ក្នុងរបាំងមុខមនុស្សធម៌ មានក្លិនក្រអូប ដូចជាបាន លាបប្រេងម្សៅឲ្យកាន់តែស្រស់ប្រិមប្រិយ៍ ថែមទៀតផង។

ក្នុងប្រវត្តិសាស្ត្រចិន ក្នុចំណោមមនុស្សឆ្លាតដែលសំលាប់មនុស្ស ឈីន ខ្វៃ ជាមនុស្សឆ្លាតក្នុងភាពល្ងង់ខ្លៅ។ គេបានប្រើពាក្យ(ប្រហែល) សម្លាប់មេទ័ព ស្មោះត្រង់ យៀក ហ្វី ចោលនឹងបានរក្សារាជបល្ល័ង្គ កៅស៊ុង ជាបណ្តោះអាសន្ន ចំណែកខ្លួនបែរជាត្រូវទទួលរង់ការជេរត្មេះ តិះដៀលពីអ្នកជំនាន់ក្រោយថា ជាជនក្បត់ ជាតិ យ៉ាងអាសោចកេរ៍។

សម្លាប់មនុស្សរាងឆ្លាតបន្តិចរាប់ថាចាវ ឆាវ ទៅចុះនៅពេលដែលសំលាប់ អឺឆុង ខ្ចីដៃរបស់លីពាវ។ ពេលដែលសម្លាប់យ៉ាងសីវ បានយកលេសដាក់ទោសថា (បំផុសបំភ័យដល់ទឹកចិត្តកងទ័ព)។ គឺសម្លាប់យ៉ាងពេញមុខពេញមាត់តែម្តង មិនចាំបាច់លាក់លៀមពីមុខពីក្រោយឡើយ។ ពិតមែនតែជាលេស តែក៏ជាលេសមួយ ដ៏សមហេតុផលដែរ។ តាមការពិត ក្នុងលោកនេះគ្មានអ្នកក្លាហានណា ដែលថាមិនសំលាប់ មនុស្សឡើយ ចាវ ឆាវ ប្រើល្បិចសម្លាប់មនុស្សហើយអាចសំដែងឆាកល្ខោន (ឆ្មាយំអាណិតកណ្តុរ) យ៉ាងគួរឲ្យ កំសត់ទៀតផង នេះហើយហៅថាអ្នកក្លាហានក្នុងភាពក្រឡេចក្រឡុច។

# ខ្ទីកាំបិតសម្លាប់មនុស្ស

(ប្រវត្តិសាស្ត្រពិត) ក្នុងសម័យ ចាន់គួក
(ប្រទេសជាច្រើនបានធ្វើសង្គ្រាមរវាងគ្នានិងគ្នាមិនឈប់ឈរ(មុនគស២២១ដល់៤៧៥) ជាមួយនិង យីហ្វាន់ម៉ា
ជាងស៊ីង ហ្វីហាន់ ព រួមគ្នាដឹកនាំកិច្ចការនគរ។ ឆ្នាំដដែល យីហ្វាន់
ទទួលព្រះរាជបញ្ជាឲ្យចេញច្បាំងនឹងនគរអ៊ូ ទទួលបានជ័យជំនះទាំងស្រុង ចាប់បានឆ្លើយសឹក
យ៉ាងសន្ធឹកសន្ធាប់ ស្តេចឈូ ពេញចិត្តណាស់បានប្រទានសំភារៈសឹកដែលរឹបអូសបាន ឲ្យទៅ យីហ្វាន់
ពាក់កណ្ដាល ហើយរាល់កិច្ចការតូចធំ តែងតែពិគ្រោះគ្នាជាមួយ
មេទ័ពរូបនេះជានិច្ច។

ចំណែកហ៊ុយហ្វីជី ក៏កើតក្ដីឈ្នានីស ក៏រួមគំនិតជាមួយម៉ាជាស៊ី រៀបចំគំរោងដាក់អន្ទាក់យីហ្វាន់តែម្ដង
គេទៅជួបលោកឧបរាជក៏និយាយ ថាៈ
លោកមេទ័ពយី មានបំណងអញ្ជើញលោកឧបរាជចូលរួមក្នុងពិធីជប់លៀងមួយ ក៏ពឹងឲ្យខ្ញុំជួយ
អញ្ជើញលោកម្ចាស់ មិនដឹងជាលោកម្ចាស់យល់ព្រម
អញ្ជើញទៅដែលឬទេ?
លោកឧបរាជប្រញ៉ាប់តបៈ
បើលោកមេទ័ពអញ្ជើញហើយ រឿងអ្វីដែលថាមិនទៅនោះ?
ហ៊ុយហ្វីជី ក៏រត់ទៅនិយាយជាមួយ យីហ្វាន់ ម្ដង
លោកឧបរាជមានបំណងចង់មកសប្បាយផឹកស្រាជាមួយលោកមេទ័ព
មិនដឹងថាលោកមេទ័ពយល់ព្រមធ្វើជាម្ចាស់កម្មវិធីដែរឬទេ?
មេទ័ពយីហ្វាន់ មិនដឹងថានេះជាអន្ទាក់ដែលបានរៀបចំជាមុននោះឡើយ ក៏ប្រញ៉ាប់ឆ្លើយទាំងសោមនស្សៈ
ខ្ញុំជាកូនចៅ បានលោកឧបរាជ ផ្ដល់កិត្តិយសបែបនេះ ពិតជាសំណាងធំហើយ ប្រសើរណាស់
ស្អែកនេះខ្ញុំនឹងរៀបចំពិធីដើម្បីទទួលលោកឧបរាជ
ឲ្យសាកសមបំផុត សូមលោកម្ចាស់ ហ៊ុយ ជួយផ្ដល់ដំណឹងនេះ ដល់លោកឧបរាជផងចុះ។

ហ៊ុយ ហ្វីជី សួរបន្ថែម
បើលោកឧបរាជបានជាអញ្ជើញមកហើយ តើលោកមេទ័ពប្រុងជូនអំណោយអ្វីដល់គាត់?
យីហ្វាន់ តបៈ
រឿងនេះពិតជាធ្វើឲ្យខ្ញុំពិបាកហើយ មិនដឹងថាលោឧបរាជចូលចិត្តអ្វីដែលទៅ?
តាមខ្ញុំដឹង អឺ.............។ ហ៊ុយ ហ្វីជី ធ្វើជាឈប់បន្តិចហើយតបៈ

ក្នុងនាមជាឧបរាជ ចំពោះមាសពេជ្រកែវកង ភ្លុកដំរី ស្រីស្រស់ស្អាតក៏មិនជាចាំបាច់ប៉ុន្មានដែរ តាមខ្ញុំយល់
បើសិនជាចំពោះសំភារៈសឹក ប្រហែលជាគាត់
ចូលចិត្តច្រើនជាង ម្យ៉ាងគាត់ក៏ធ្លាប់បង្ហើបឲ្យខ្ញុំដឹងផងដែរថាៈ គាត់ពេញចិត្តនឹងសំភារៈសឹក
ដែលព្រះរាជាប្រទានដល់លោកមេទ័ពកាលឈ្នះសង្គ្រាមនោះ
លោកឧបរាជមកចូល រួមក្នុងពិធីនេះគឺមានចិត្តចង់មើលអាវុធទាំងនោះ តែប៉ុណ្ណោះ។

ជាមួយគ្នានោះ យីហ្វាន់ក៏ឲ្យសេនា ជញ្ជូនអាវុធទាំងនោះចេញមក។
ហ៊ុយហ្វីជីក៏បានជួយជ្រើសរើសអាវុធចំនួន មួយរយក្នុងចំណោមនោះ ហើយប្រាប់
យីហ្វាន់ថាៈ -ប៉ុណ្ណឹង សមល្មមហើយ
លោកយកអាវុទាំងនេះរៀបចំទុកដាក់ក្បែរមាត់ទ្វារចូលទៅនៅពេលដែល លោកឧបរាជអញ្ជើងមកដល់
ពិតជាប្រទះភ្នែក

ហើយនិងសួរនាំអំពីអាវុធទាំងនេះ ឲ្យតែគេរំលឹកសួរ
លោកម្ចាស់ត្រូវតែឆ្លៀតឱកាសជូនជាអំណោយដល់គាត់ម្តងទៅ ប្រសិនជារបស់ផ្សេងពីនេះ ខ្លាចតែ
លោកឧបរាជ មិនទទួលទេ។

យី ហ្វាន់ ជឿទាំងស្រុងមិននឹកស្មានថា នេះជាល្បិចទាល់តែសោះរួចក៏ឲ្យសេនារៀបចំអាវុធទាំងនោះ
ក្បែរមាត់ទ្វារចូលពាសពេញ ហើយគ្រប់យ៉ាងត្រឹមត្រូវ។
ថ្ងៃបន្ទាប់ មេទ័ពយីហ្វាន់ បានរៀបចំពិធីជប់លៀងដ៏អធឹកអធមមួយ ហើយក៏ពឹង ហ៊្វយ ហ៊្វជី
ឲ្យទៅអញ្ជើងលោកឧបរាជ លោកឧបរាជក៏រៀបចំខ្លួនដើម្បីចេញដំណើរ
តែត្រូវ ហ៊ុយ ហ៊្វជី ឃាត់:
លោកម្ចាស់ថ្មីៗនេះ យីហ្វាន់ ហាក់ដូចជាមានអំនួតខ្លាំងណាស់ការរៀបចំពិធីជប់លៀងលើកនេះ
ក៏មិនដឹងដោយមូលហេតុអ្វី ចិត្តមនុស្សពិបាកយល់ ដូចនេះលោកម្ចាស់គួររង់ចាំបន្តិចសិនចាំខ្ញុំទៅសើបមើល
សភាពការណ៍ជាមុន ហើយចាំលោកម្ចាស់អញ្ជើញទៅតាមក្រោយចុះ។ ធ្វើបែបនេះទើបទទួលបានសុវត្ថិភាព
តើយ៉ាងម៉េចដែរ?
ប្រសើរណាស់ឯងទៅមើលៗ!
ហ៊ុយ ហ៊្វជី ក៏ធ្វើដំណើរចេញទៅ ដើរក្រលេចមើលទីប្រជុំជនពីរជុំ ក៏បត់មកវិញធ្វើជារត់យ៉ាងត្រហេបត្រហប
ដកដង្ហើមស្ទើរមិនដល់គ្នារួចរាយការណ៍ជូនលោកឧបរាជ
ទាំរញ៉ើរញ៉ៃ:
វិះតែខូចការ ខ្ញុំសើបដឹងថា នៅមាត់ទ្វារច្រកចូលមានលាក់អាវុធយ៉ាងសន្ធឹកសន្ធាប់ណាស់ បើលោកម្ចាស់
អញ្ជើញទៅពិតជាជាប់អន្ទាក់ របស់ យី ហ្វាន់ ហើយ។
លោកឧបរាជស្តាប់ហើយ ហាក់រារែកក្នុងចិត្ត ក៏និយាយថា:
ដូចជាមិនសមសោះ ខ្ញុំនិងលោកមេទ័ពយី មិនដែលមានទំនាស់អ្វីនិងគ្នាទេ

មិនអាចទៅជាអញ្ចឹងទេដឹង?
តែ ហ៊ុយ ហ៊្វជី បែរជាឆ្លៀតឱកាសអុចអាលបន្ថែម:
ក្រោយពីយីហ្វាន់ ចេញច្បាំងឈ្នះនគរអ៊ូ បានទទួលការស្រឡាញ់ពីព្រះអង្គដ៏លើសលប់ គេក៏កើតមាន
ចិត្តលោបលន់ ចង់ដណ្តើមដំណែងរបស់លោកម្ចាស់
ជាយូរមកហើយ រឿងនេះមន្ត្រីតូចធំអ្នកណាក៏ដឹងដែរតែលោកម្ចាស់ខ្លួនឯងប៉ុណ្ណោះមិនដឹង
ខ្ញុំនិងលោកម្ចាស់ម៉ាជាស៊ី មើលឃើញថា មុននិងក្រោយ បញ្ហាបែបនេះ
នឹងកើតឡើងមិនខាន សាកគិតមើល ពេលវាយឈ្នះនគរអ៊ូ ទ័ពអ៊ូកំពុងច្របូកច្របល់ យីហ្វាន់មាន
លទ្ធភាពគ្រប់គ្រាន់តាមសម្លាប់សត្រូវរហូតទីបញ្ចាប់
អាចកំទេចនគរអ៊ូឲ្យសូន្យបាន ហេតុអ្វីក៏ចាប់យកតែឈ្លើយ សឹកនិងអាវុធមួយចំនួន
ក៏ដកថយត្រឡប់មកវិញ?
ឮថា: ពេលនេះយីហ្វាន់ បានទទួលសំណូកជាច្រើនពីនគរអ៊ូ ហើយមានកិច្ចព្រមព្រៀងសម្ងាត់ទៀតផង
ដូច្នេះហើយ ត្រូវតែបង្ខំទ័ពឲ្យត្រលប់ក្រោយ។
ដូច្នេះតាមការសន្និដ្ឋាន យីហ្វាន់ ពិតជាមានឧបាយកលមិនធម្មតាទេ ពិតជាមានបំណងអាក្រក់
និយាយមិនទៀង.............ប្រសិនបើមនុស្ស នេះដណ្តើម
អំណាចបាននគរឈូយើង ពិតជាមានគ្រោះអាសន្នធំហើយ។

ហ៊ុយហ៊្វជីនិយាយរៀបរាប់ដូចទឹកធ្លាក់ពីលើភ្នំ ដូចជារឿងនេះមានពិតអឺងចឹង
ធ្វើឲ្យចិត្តលោកឧបរាជច្រួលច្របល់ មិនប្រាកដក្នុងខ្លួន តែលោកឧបរាជនៅតែមិនទាន់ជឿ

# ខ្ទីភាំបិតសម្លាប់មនុស្ស

ក៏បញ្ជាឲ្យកូនចៅជំនិតទៅសើបមើលម្ដងទៀត។ មួយ សន្ទុះធំ កូនចៅជំនិតនោះក៏ត្រលប់មកវិញ
ហើយរាយការណ៍ថា: ពិតជាមានរឿងអឹងចឹងមែន
នៅក្បែមាត់ទ្វារចូលពិតជាមានលាក់អាវុធយ៉ាងច្រើនពិតមែន។

ពិតជាថ្លើមធំមែន។ លោកឧបរាជខឹងក្រោធតែម្ដង ក៏ចាត់ឲ្យសេនាទៅហៅលោកម៉ាជាស៊ីមកជួប
រ៉ៃរាប់ប្រាប់រឿងទាំងនេះ ហើយសួរថា
គួរដោះស្រាយយ៉ាងណា?
នេះជាអន្ទាក់ដែលម៉ាជាស៊ី រួមគំនិតជាមួយ ហ៊ុយ ហ៊្វយជី រៀបចំឡើង ស្ដាប់លោកឧបរាជនិយាយចប់
ក៏ឆ្លៀតឱកាសសំអុយបន្ថែមតែម្ដង:
យីហ្វាន់ មានគំនិតក្បត់យូរមកហើយ បានលួចរួមដៃជាមួយពួកត្រកូលធំៗទាំង៣ នៅរាជធានីដើម្បី
ធ្វើការដណ្ដើមអំណាច សំណាងហើយដែលថ្ងៃនេះ
រកឃើញអំពើក្បត់ទោសទាន់ បើយឺតពេលតែបន្តិច ពិតជាគ្រោះអាសន្នធំហើយ។
គួរឲ្យក្ដៅក្រហាយមែន ! លោកឧបរាជទេះតុផាំងស្នើរបាក់:
យើងត្រូវតែសម្លាប់វាចោល!

ជាបន្ទាន់ជាមួយគ្នានោះ លោកឧបរាជក៏សុំយោបល់ទៅស្ដេចឈូ។
ហើយក៏បញ្ជាឲ្យមេទ័ព ម៉ា ជាស៊ី នាំទ័ពឡោមព័ទ្ធដំណាក់ យីហ្វាន់ តែម្ដង។

ពេលនេះយី ហ្វាន់ ទើបដឹងថា: ខ្លួនធ្លាក់ក្នុងអន្ទាក់របស់ ហ៊ុយហ៊្វជី ទៅហើយ
ចង់និយាយបកស្រាយក៏មិនទាន់ ហើយក៏គ្មានអ្នកណាជឿរដែរ អ្វីៗគឺវា
ហួសពេលទៅហើយ មានតែផ្លូវម្យ៉ាងគត់ សំរាប់ជ្រើសរើស គឺត្រូវបិទភ្នែកស្លាប់ទាំងអយុតិធម៌ គិតហើយ
ដកដង្ហើមយ៉ាងវែង រួចក៏ទាយដាវមកបញ្ចប់ជីវិត ខ្
លួនឯងតែម្ដងទៅ៕